ព្រះវិន័យ

# សង្ឃកម្មកថា

ភាគ ២

សម្រាប់សាលាធម្មវិន័យ

ថ្នាក់ឯក

បណ្ណាល័យ
BUDDHIST INSTITUTE
LIBRARY

២៨១.
៩២

ភ្នំពេញ
ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ
ព.ស ២៥៣៩

## ស្នាដៃនេះ

កើតឡើងពីកិច្ចសហការគ្នា រវាង
**ពុទ្ធសាសនបណ្ឌិត្យ** និង **បណ្ណាល័យអេឡិចត្រូនិចខ្មែរ**
ក្នុងគោលបំណងយ៉ាងមុតមាំដើម្បីថែរក្សា ការពារ កុំឲ្យបាត់បង់តទៅទៀត
ព្រមទាំងផ្សព្វផ្សាយស្នាដៃ-ឯកសារទាំងនេះ
សម្រាប់សាធារណជនប្រើប្រាស់ដោយមិនគិតកម្រៃ។

សូមថ្លែងអំណរគុណដល់
**អង្គការរីហ្សូ កូស៊ី-កៃ  វិទ្យាស្ថានបើកទូលាយ**
**ករុណាខ្មែរ និង មូលនិធិខ្មែរសម្រាប់ការសិក្សា**
ដែលបានគាំទ្រគម្រោងការស្នាដៃនេះ សម្រាប់ទុកក្នុងបណ្ណាល័យអេឡិចត្រូនិច។

Buddhist Institute of Ministry of Cult and Religion and eLibrary of Cambodia have made a cooperative effort to digitalize books and manuscripts in order to preserve our Cambodian literary heritage. This will promote and provide easy, instant access, free of charge to the public and future generations to come.

A sincere thank you to our generous supporters: Rissho Kosei-Kai, Open Institute, Karuna Cambodia and Cambodian Education Excellence Foundation, who made this endeavor possible.

www.budinst.gov.kh    www.elibraryofcambodia.org

២៤១.៩២

# ព្រះវិន័យ

# សង្ឃកម្មកថា

**ភាគ ២**

សម្រាប់សាលាធម្មវិន័យ ថ្នាក់ឯក

ព្រះឃោសធម្ម **ម៉ីុខ - សែស** ( ចន្ទធម្មោ )

រៀបរៀង

**ក្រោមព្រះបរមរាជូបត្ថម្ភ**

បោះពុម្ពឡើងវិញ ចំនួន ៣.៥០០ ច្បាប់

តាមច្បាប់បោះពុម្ពគ្រាទី ២

( ក្រសួងធម្មការ )

INSTITUT BOUDDHIQUE

LIBRARY
BUDDHIST INSTITUTE
៧៩៣៩/៩៦

ភ្នំពេញ

ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ

ព.ស ២៥៣៨ គ.ស ១៩៩៥

# វិញ្ញាបនី

សង្ឃកម្មកថា ភាគទី ២ នេះ មានលំដាប់លេខទំព័ររៀងតភ្ជាប់គ្នាពីភាគទី ១ មក ទោះបីចែកជា ២ ភាគ ក៏ទុកដូចជាសៀវភៅតែ ១ ភាគ បើលោកអ្នកសិក្សាត្រូវការនឹងដេរជាសៀវភៅក្របរឹងរួមភាគទី ១ នឹងភាគទី ២ នេះ ឲ្យជា១ភាគ ក៏ងាយណាស់ មិនទាស់ឆ្គងអ្វីទេ គ្រាន់តែក្រាស់ធ្ងន់បន្តិចប៉ុណ្ណោះ ។

សៀវភៅនេះ មានសារប្រយោជន៍ដ៏សំខាន់ណាស់ ដល់ព្រះភិក្ខុសង្ឃគ្រប់វត្តក្នុងកម្ពុជរដ្ឋ គួរតែឲ្យមានគល់វត្ត ពុំគួរខាន ព្រោះជាគោលជាអាយុជីវិតនៃសង្ឃកម្មផ្សេង ៗ ដែលព្រះភិក្ខុសង្ឃត្រូវតែប្រតិបត្តិ តាមលំអានព្រះវិន័យ ជាឫសគល់នៃព្រះពុទ្ធសាសនា ដែលព្រះភិក្ខុសង្ឃតែងតែមានសេចក្តីងឿងឆ្ងល់ ឬកាន់ប្រឡំខ្លះ រឿយ ៗ មកហើយ ដោយហេតុគ្មានគម្ពីរនេះសម្រាប់សិក្សាឲ្យយល់ជាក់ច្បាស់ ។ ពីនេះតទៅមុខ ព្រះភិក្ខុសង្ឃគ្រប់វត្តនឹងមានការចេះដឹងយល់ច្បាស់ លែងមានសេចក្តីងឿងឆ្ងល់សង្ស័យអំពីសង្ឃកម្មទាំង ៤ យ៉ាង ហើយនឹងអាចធ្វើសង្ឃកម្មមានរបៀបត្រូវគ្នាតែបែបមួយ ព្រោះមានសៀវភៅសង្ឃកម្មកថានេះជាគោលហើយ ជាលាភប្រសើរណាស់ ។

សម្តេចព្រះមហាសុមេធាធិបតី ជួន-ណាត

ប្រធានគណៈកម្មការរៀបរៀងធម៌វិន័យ

## មាតិកានុក្រម

# ញត្តិចតុត្ថកម្ម

ទំព័រ


| | | |
|---|---|---|
| ញត្តិចតុត្ថកម្ម មានឋាន ៧ | | ១១៩ |
| និស្សារណា | ការបណ្ដេញ | ១១៩ |
| តជ្ជនីយកម្ម | អំពើគួរដល់ការគម្រាម | ១១៩ |
| សម្មតិ | ការសន្មតិភិក្ខុអ្នកទូន្មានភិក្ខុនី | ១៣៤ |
| ទាន | ការឲ្យបរិវាសទាន | ១៤០ |
| បរិវាស មាន ៣ | | ១៤១ |
| សុទ្ធន្តបរិវាស មាន ២ | | ១៦៦ |
| វិធីសូមនឹងវិធីឲ្យនូវសុទ្ធន្តបរិវាស | | ១៦៩ |
| សមោធានបរិវាស មាន ៣ យ៉ាង | | ១៧៩ |
| ការសួរអន្តរាបត្តិ | | ១៨១ |
| អគ្ឃសមោធានបរិវាស | | ២០២ |
| លក្ខណៈនៃការសូត្រសូមនឹងការឲ្យនូវអគ្ឃសមោធាន | | ២០៣ |
| មិស្សកសមោធានបរិវាស | | ២១៥ |
| និគ្គហៈ | ការសង្កត់សង្កិន | ២២០ |
| សមនុភាសនា | ការសូត្រសមនុភាសនកម្ម | ២២១ |
| អធិប្បាយសិក្ខាបទទាំង ១១ | | ២២២ |
| សង្ឃភេទសិក្ខាបទ | | ២២២ |
| ភេទានុវត្តកសិក្ខាបទ | | ២២៦ |
| ទុព្វចជាតិកសិក្ខាបទ | | ២២៨ |
| កុលទូសកសិក្ខាបទ | | ២២៩ |
| អរិដ្ឋសិក្ខាបទ | | ២៣១ |
| បណ្ឌកាលីសិក្ខាបទ ជាសិក្ខាបទទី១០ក្នុងសង្ឃាទិសេសកណ្ឌ ភិក្ខុនីវិភង្គ | | ២៣៣ |

សិក្ខាបទ ទី ១១ . . . . . . . . . . . . . . . . . . . . ២៣៩

សិក្ខាបទ ទី ១២ . . . . . . . . . . . . . . . . . . . . ២៤០

សិក្ខាបទ ទី ១៣ . . . . . . . . . . . . . . . . . . . . ២៤១

សិក្ខាបទ ទី ៦ នៃតុវដ្តវគ្គ បាចិត្តិយកណ្ឌ ភិក្ខុនីវិភង្គ . . . . . . . . . ២៤៤

ឧក្ខិត្តានុវត្តិកសិក្ខាបទ ជាសិក្ខាបទទី៣នៃបារាជិកកណ្ឌ ភិក្ខុនីវិភង្គ . . . . . . . . ២៤៥

នាយឈ្មួញពីរនាក់ . . . . . . . . . . . . . . . . . . . . ២៤៩

ពុទ្ធានុញ្ញាតបព្វជ្ជានិងឧបសម្បទា ដោយត្រៃសរណគមន៍ . . . . . . . . . ២៥៤

ពុទ្ធានុញ្ញាតឧបសម្បទា ដោយញត្តិចតុត្ថកម្ម . . . . . . . . . . . . ២៥៥

អព្ភាន ការរាប់រកឬហៅរក . . . . . . . . . . . . . . . ២៥៨

អព្ភាន របស់ឯកាហបរិវាស . . . . . . . . . . . . . . . ២៥៩

អព្ភាន របស់សុទ្ធន្តបរិវាស . . . . . . . . . . . . . . . ២៦៣

អព្ភាន របស់ឱធានសមោធានបរិវាស . . . . . . . . . . . . ២៦៧

អព្ភាន របសអគ្ឃសមោធានបរិវាស . . . . . . . . . . . . . ២៧៥

អព្ភាន របសអប្បដិច្ឆន្នមានត្ត . . . . . . . . . . . . . . . ២៨០

# ញត្តិចតុត្ថកម្ម

ញត្តិចតុត្ថកម្ម មានឋាន ៧ គឺ ឱសារណា ១ និស្សារណា ១ សម្មតិ ១ ទាន ១ និគ្គហ ១ សមនុភាសនា ១ កម្មលក្ខណា ១ ។

និស្សារណា ការបណ្តេញ ។ បណ្តេញក្នុងទីនេះ សំដៅយកកម្ម ៧ ប្រការ គឺ តជ្ជនីយកម្ម ១ និយស្សកម្ម ១ បព្វាជនីយកម្ម ១ បដិសារណីយកម្ម ១ ឧក្ខេបនីយកម្ម ព្រោះមិនឃើញអាបត្តិ ១ ឧក្ខេបនីយកម្ម ព្រោះមិនសំដែងអាបត្តិ ១ ឧក្ខេបនីយកម្ម ព្រោះមិនលះបង់ទិដ្ឋិអាក្រក់ ១ ; កម្មទាំង ៧ ប្រការនេះ ដែលសង្ឃបានធ្វើដល់ភិក្ខុអ្នកប្រព្រឹត្តខុសទាស់នឹងសេចក្តីរៀបរយ ក្នុងព្រះពុទ្ធសាសនា ហៅថា និស្សារណា ការបណ្តេញ ។

តជ្ជនីយកម្ម អំពើគួរដល់ការគម្រាម ។ មានរឿងក្នុងកម្មក្ខន្ធកៈថា សម័យនោះ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋីទៀបក្រុងសាវត្ថី ។ សម័យនោះឯង ពួកបណ្ឌុកនឹងលោហិតកភិក្ខុ ជាអ្នកធ្វើនូវការបង្កហេតុ, ធ្វើនូវជម្លោះ, ធ្វើនូវការទាស់ទែង, ធ្វើនូវតិរច្ឆានកថា, ធ្វើនូវអធិករណ៍ក្នុងសង្ឃ ដោយ

១១៦៩ កំចូលទៅរកពួកភិក្ខុឯទៀត ដែលជាអ្នកធ្វើនូវការបង្កហេតុ, ធ្វើនូវជម្លោះ, ធ្វើនូវការទាស់ទែង, ធ្វើនូវពិវាទកថា, ធ្វើនូវអធិករណ៍ក្នុងសង្ឃ (ដូចខ្លួនដែរ) ហើយនិយាយយ៉ាងនេះថា លោកអ្នកមានអាយុទាំងឡាយ មិនត្រូវឲ្យភិក្ខុនុះផ្ចាលផ្ចាញ់ពួកលោកបានទេ ចូរលោកពល់គ្នាប្រឹងដេញចំហឹងចុះ ព្រោះពួកលោកសុទ្ធតែជាអ្នកប្រាជ្ញ ជាអ្នកវាងវៃ ជាពហុស្សូត ជាអ្នកអង់អាច ជាងភិក្ខុនោះ កុំខ្លាចភិក្ខុនោះឲ្យសោះ ព្រោះយើងពល់គ្នាក៏ជាបក្ខពួករបស់លោកទាំងឡាយដែរ ។ ដោយហេតុនោះ ការបង្កហេតុដែលមិនធ្លាប់កើត ក៏កើតឡើងបាន ដែលកើតស្រាប់ហើយ ក៏រើងរឹតតែចំរើនច្រើនឡើង ។ បានជាពួកភិក្ខុដែលមានសេចក្ដីប្រាថ្នាតិច ក៏នាំគ្នាក្រាបបង្គំទូលព្រះមានព្រះភាគ, ព្រះអង្គទ្រង់ត្រាស់បង្គាប់ឲ្យសង្ឃធ្វើ តជ្ជនីយកម្ម ដល់ពួកបណ្ឌុកភិក្ខុនិងលោហិតកភិក្ខុ ។ ត្រូវធ្វើយ៉ាងនេះ ៖ ត្រូវសង្ឃចោទពួកបណ្ឌុកភិក្ខុនិងលោហិតកភិក្ខុជាមុន លុះចោទរួចហើយត្រូវរំលឹក លុះរំលឹករួចហើយត្រូវលើកឡើងនូវអាបត្តិ លុះលើកឡើងនូវអាបត្តិហើយ ភិក្ខុអ្នកឈ្លាសប្រតិពល ត្រូវផ្ដៀងសង្ឃថា ៖

សុណាតុ មេ ភន្តេ សង្ឃោ ឥមេ បណ្ឌុក-លោហិតកា ភិក្ខូ អត្តនា ភណ្ឌនការកា កលហ-ការកា វិវាទការកា ភស្សការកា សង្ឃេ អធិ-

ករណការកា យេបិចញ្ញេ ភិក្ខូ ភណ្ឌនការកា កលហការកា វិវាទការកា ភស្សការកា សង្ឃេ អធិករណការកា តេ ឧបសង្កមិត្វា ឯវំ វទន្តិ មា ខោ តុម្ហេ អាយស្មន្តោ ឯសោ អជេសិ ពលវា ពលវំ បដិមន្តេថ តុម្ហេ តេន បណ្ឌិតតរា ច ព្យត្តតរា ច ពហុស្សុតតរា ច អលមត្តតរា ច មា ចស្ស ភាយិត្ថ មយំបិ តុម្ហាកំ បក្ខា ភវិស្សាមាតិ ។ តេន អនុប្បន្នានិ ចេវ ភណ្ឌនានិ ឧប្បជ្ជន្តិ ឧប្បន្នានិ ច ភណ្ឌនានិ ភិយ្យោភាវាយ វេបុល្លាយ សំវត្តន្តិ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ បណ្ឌុកលោហិតកានំ ភិក្ខូនំ តជ្ជនីយកម្មំ ករេយ្យ ឯសា ញត្តិ ។

សុណាតុ មេ ភន្តេ សង្ឃោ ឥមេ បណ្ឌុកលោហិតកា ភិក្ខូ អត្តនា ភណ្ឌនការកា ។ បេ ។ សង្ឃេ អធិករណការកា យេបិចញ្ញេ ភិក្ខូ ភណ្ឌនការកា ។ បេ ។ សង្ឃេ អធិករណការកា តេ ឧបសង្កមិត្វា ឯវំ វទន្តិ មា ខោ តុម្ហេ អាយស្មន្តោ ឯសោ អជេសិ ពលវា ពលវំ បដិមន្តេថ តុម្ហេ តេន បណ្ឌិតតរា ច ព្យត្តតរា ច ពហុស្សុតតរា ច អល-

មត្តតរា ច មា ចស្ស ភាយិត្ថ មយំបិ តុម្ហាកំ បក្ខា ភវិស្សាមាតិ ។ តេន អនុប្បន្នានិ ចេវ ភណ្ឌនានិ ឧប្បជ្ជន្តិ ឧប្បន្នានិ ច ភណ្ឌនានិ ភិយ្យោភាវាយ វេបុល្លាយ សំវត្តន្តិ ។ សង្ឃោ បណ្ឌុកលោហិតកានំ ភិក្ខូនំ តជ្ជនីយកម្មំ ករោតិ យស្សាយស្មតោ ខមតិ បណ្ឌុកលោហិតកានំ ភិក្ខូនំ តជ្ជនីយកម្មស្ស ករណំ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។

ទុតិយម្បិ ឯតមត្ថំ វទាមិ ។ សុណាតុ មេ ភន្តេ សង្ឃោ ឥមេ បណ្ឌុកលោហិតកា ភិក្ខូ អត្តនា ភណ្ឌនការកា ។ បេ ។ សង្ឃេ អធិករណការកា យេបិ ចញ្ញេ ភិក្ខូ ភណ្ឌនការកា ។ បេ ។ សង្ឃេ អធិករណការកា តេ ឧបសង្កមិត្វា ឯវំ វទេន្តិ មា ខោ តុម្ហេ អាយស្មន្តោ ឯសោ អជេសិ ពលវា ពលវំ បដិមន្តេថ តុម្ហេ តេន បណ្ឌិតតរា ច ព្យត្តតរា ច ពហុស្សុតតរា ច អលមត្តតរា ច មា ចស្ស ភាយិត្ថ មយំបិ តុម្ហាកំ បក្ខា ភវិស្សាមាតិ ។ តេន អនុប្បន្នានិ ចេវ ភណ្ឌនានិ ឧប្បជ្ជន្តិ ឧប្បន្នានិ ច ភណ្ឌ-

នានិ ភិយ្យោភាវាយ វេបុល្លាយ សំវត្តន្តិ ។ សង្ឃោ បណ្ឌុកលោហិតកានំ ភិក្ខូនំ តជ្ជនីយកម្មំ ករោតិ យស្សាយស្មតោ ខមតិ បណ្ឌុកលោហិតកានំ ភិក្ខូនំ តជ្ជនីយកម្មស្ស ករណំ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។

តតិយម្បិ ឯតមត្ថំ វទាមិ ។ សុណាតុ មេ ភន្តេ សង្ឃោ ឥមេ បណ្ឌុកលោហិតកា ភិក្ខូ អត្តនា ភណ្ឌនការកា ។ បេ ។ សង្ឃេ អធិករណការកា យេបិចញ្ញេ ភិក្ខូ ភណ្ឌនការកា ។ បេ ។ សង្ឃេ អធិករណការកា តេ ឧបសង្កមិត្វា ឯវំ វទេន្តិ មា ខោ តុម្ហេ អាយស្មន្តោ ឯសោ អជេសិ ពលវា ពលវំ បដិមន្តេថ តុម្ហេ តេន បណ្ឌិតតរា ច ព្យត្តតរា ច ពហុស្សុតតរា ច អលមត្ថតរា ច មា ចស្ស ភាយិត្ថ មយំបិ តុម្ហាក បក្ខា ភវិស្សាមាតិ ។ តេន អនុប្បន្នានិ ចេវ ភណ្ឌនានិ ឧប្បជ្ជន្តិ ឧប្បន្នានិ ច ភណ្ឌនានិ ភិយ្យោភាវាយ វេបុល្លាយ សំវត្តន្តិ ។ សង្ឃោ បណ្ឌុកលោហិតកានំ ភិក្ខូនំ តជ្ជនីយកម្មំ ករោតិ យស្សាយស្មតោ ខមតិ បណ្ឌុកលោហិតកានំ ភិក្ខូនំ

តជ្ជនីយកម្មស្ស ករណំ សោតុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។

កតំ សង្ឃេន បណ្ឌុកលោហិតកានំ ភិក្ខូនំ តជ្ជនីយកម្មំ ខមតិ សង្ឃស្ស តស្មា តុណ្ហី ឯវមេតំ ធារយាមិ ។

"បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្ដាប់ពាក្យខ្ញុំ ពួកបណ្ឌុកភិក្ខុនិងលោហិតកភិក្ខុនេះ ជាអ្នកធ្វើនូវការបង្កហេតុ, ធ្វើនូវជម្លោះ, ធ្វើនូវការទាស់ទែង, ធ្វើនូវពិវាទកថា, ធ្វើនូវអធិករណ៍ក្នុងសង្ឃដោយខ្លួនឯង ក៏ចូលទៅរកពួកភិក្ខុឯទៀតដែលជាអ្នកធ្វើនូវការបង្កហេតុ, ធ្វើនូវជម្លោះ, ធ្វើនូវការទាស់ទែង, ធ្វើនូវពិវាទកថា, ធ្វើនូវអធិករណ៍ក្នុងសង្ឃ (ដូចខ្លួនដែរ) ហើយនិយាយយ៉ាងនេះថា លោកអ្នកមានអាយុទាំងឡាយ មិនត្រូវឲ្យភិក្ខុនុះផ្ដាលផ្ដាញ់ពួកលោកបានទេ ចូរលោកពល់គ្នាប្រឹងជជែកឲ្យពេញទំហឹងចុះ ព្រោះពួកលោកសុទ្ធតែជាអ្នកប្រាជ្ញ, ជាអ្នកវាងវៃ, ជាពហុស្សូត, ជាអ្នកអង់អាច ដាក់ភិក្ខុនោះ កុំខ្លាចភិក្ខុនោះឲ្យសោះ ព្រោះយើងពល់គ្នាក៏ជាបក្សពួករបស់លោកទាំងឡាយដែរ ។ ដោយហេតុនោះ ការបង្កហេតុដែលមិនធ្លាប់កើតឡើង ក៏កើតឡើងបាន ដែលកើតឡើងស្រាប់ហើយ ក៏រឹងរឹតតែចំរើនច្រើនឡើង, បើតជ្ជនីយកម្មមានកាលដ៏សមគួរដល់សង្ឃហើយ សង្ឃគប្បីធ្វើនូវតជ្ជនីយកម្ម ដល់

ពួកបណ្ឌុកភិក្ខុនិងលោហិតកភិក្ខុ នេះហៅថា ញត្តិ ។

បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំ ពួកបណ្ឌុកភិក្ខុនិងលោហិតកភិក្ខុនេះ ជាអ្នកធ្វើនូវការបង្កហេតុដោយខ្លួនឯង ។ បេ ។ ធ្វើនូវអធិករណ៍ក្នុងសង្ឃ ក៏ចូលទៅរកពួកភិក្ខុឯទៀត ដែលជាអ្នកធ្វើនូវការបង្កហេតុ ។ បេ ។ ធ្វើនូវអធិករណ៍ក្នុងសង្ឃ (ដូចខ្លួនដែរ) ហើយនិយាយយ៉ាងនេះថា លោកអ្នកមានអាយុទាំងឡាយមិនត្រូវឲ្យភិក្ខុនុ៎ះផ្តួលផ្តាញ់ពួកលោកបានទេ ចូរលោកពល់គ្នាប្រឹងដដែកឲ្យពេញទំហឹងចុះ ព្រោះពួកលោកសុទ្ធតែជាអ្នកប្រាជ្ញ, ជាអ្នកវាងវៃ, ជាពហុស្សូត, ជាអ្នកអង់អាច ជាងភិក្ខុនោះ កុំខ្លាចភិក្ខុនោះឲ្យសោះ ព្រោះយើងពល់គ្នាក៏ជាបក្ខពួករបស់លោកទាំងឡាយដែរ ។ ដោយហេតុនោះ ការបង្កហេតុដែលមិនធ្លាប់កើតឡើង ក៏កើតឡើងបាន ដែលកើតឡើងស្រាប់ហើយ ក៏រឹងរឹតតែចំរើនច្រើនឡើង ។ (ឥឡូវ) សង្ឃធ្វើនូវតជ្ជនីយកម្ម ដល់ពួកបណ្ឌុកភិក្ខុនិងលោហិតកភិក្ខុ, ការធ្វើនូវតជ្ជនីយកម្ម ដល់ពួកបណ្ឌុកភិក្ខុនិងលោហិតកភិក្ខុ គាប់ចិត្តដល់លោកអ្នកមានអាយុអង្គណា លោកអ្នកមានអាយុអង្គនោះ ត្រូវស្ងៀម មិនគាប់ចិត្តដល់លោកអ្នកមានអាយុអង្គណា លោកអ្នកមានអាយុអង្គនោះ ត្រូវនិយាយឡើង ។

ខ្ញុំពោលនូវសេចក្តីនេះ អស់វារៈជាគំរប់ពីរដងទៀត ៖ បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំ ពួកបណ្ឌុកភិក្ខុនិងលោហិតក-

ភិក្ខុនេះ ជាអ្នកធ្វើនូវការបង្កហេតុ ដោយខ្លួនឯង ៗ បេ ៗ ធ្វើនូវអធិករណ៍ក្នុងសង្ឃ ក៏ចូលទៅរកពួកភិក្ខុឯទៀត ដែលជាអ្នកធ្វើនូវការបង្កហេតុ ៗបេៗ ធ្វើនូវអធិករណ៍ក្នុងសង្ឃ (ដូចខ្លួនដែរ) ហើយនិយាយយ៉ាងនេះថា លោកអ្នកមានអាយុទាំងឡាយ មិនត្រូវឲ្យភិក្ខុនុះផ្តួលផ្តាញ់ពួកលោកបានទេ ចូរលោកកាល់គ្នាប្រឹងដដែកឲ្យពេញទំហឹងចុះ ព្រោះពួកលោកសុទ្ធតែជាអ្នកប្រាជ្ញ, ជាអ្នកវាងវៃ, ជាពហុស្សុត, ជាអ្នកអង់អាចជាងភិក្ខុនោះ កុំខ្លាចភិក្ខុនោះឲ្យសោះ ព្រោះយើងរាល់គ្នាក៏ជាបក្ខពួករបស់លោកទាំងឡាយដែរ ៗ ដោយហេតុនោះ ការបង្កហេតុ ដែលមិនធ្លាប់កើតឡើង ក៏កើតឡើងបាន ដែលកើតឡើងស្រាប់ហើយ ក៏រឹងរឹតតែចំរើនច្រើនឡើង ៗ (ឥឡូវ)សង្ឃគប្បីធ្វើនូវតជ្ជនីយកម្មដល់ពួកបណ្ឌុកភិក្ខុនិងលោហិតកភិក្ខុ, ការធ្វើនូវតជ្ជនីយកម្មដល់ពួកបណ្ឌុកភិក្ខុនិងលោហិតកភិក្ខុ គាប់ចិត្តដល់លោកអ្នកមានយុអង្គណា លោកអ្នកមានអាយុអង្គនោះត្រូវស្ងៀម មិនគាប់ចិត្តដល់លោកអ្នកមានអាយុអង្គណា លោកអ្នកមានអាយុអង្គនោះ ត្រូវនិយាយឡើង ៗ

ខ្ញុំពោលនូវសេចក្តីនេះអស់វារៈជាគំរប់បីដងទៀត៖ បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំ ពួកបណ្ឌុកភិក្ខុនិងលោហិតកភិក្ខុនេះ ជាអ្នកធ្វើនូវការបង្កហេតុដោយខ្លួនឯង ៗបេៗ ធ្វើនូវអធិករណ៍ក្នុងសង្ឃ ក៏ចូលទៅរកពួកភិក្ខុឯទៀត ដែលជាអ្នកធ្វើនូវការបង្កហេតុ ៗបេៗ ធ្វើនូវអធិ-

ករណ៍ក្នុងសង្ឃ (ដូចខ្លួនដែរ) ហើយនិយាយយ៉ាងនេះថា លោកអ្នកមានអាយុទាំងឡាយ មិនត្រូវឲ្យភិក្ខុនុះផ្ដួលផ្ដាញ់ពួកលោកបានទេ ចូរលោកកាល់គ្នាប្រឹងដដែកឲ្យពេញទំហឹងចុះ ព្រោះពួកលោកសុទ្ធតែជាអ្នកប្រាជ្ញ, ជាអ្នកវាងវៃ, ជាពហុស្សូត, ជាអ្នកអង់អាច ជាងភិក្ខុនោះ កុំខ្លាចភិក្ខុនោះឲ្យសោះ ព្រោះយើងកាល់គ្នាក៏ជាបក្ខពួករបស់លោកទាំងឡាយដែរ ។ ដោយហេតុនោះ ការបង្កហេតុដែលមិនធ្លាប់កើតឡើង ក៏កើតឡើងបាន ដែលកើតឡើងស្រាប់ហើយ ក៏រីងរឹតតែចំរើនច្រើនឡើង ។ (ឥឡូវ) សង្ឃធ្វើនូវតជ្ជនីយកម្ម ដល់ពួកបណ្ឌកភិក្ខុនឹងលោហិតកភិក្ខុ, ការធ្វើនូវតជ្ជនីយកម្មដល់ពួកបណ្ឌកភិក្ខុនឹងលោហិតកភិក្ខុ គាប់ចិត្តដល់លោកអ្នកមានអាយុអង្គណា លោកអ្នកមានអាយុអង្គនោះ ត្រូវស្ងៀម មិនគាប់ចិត្តដល់លោកអ្នកមានអាយុអង្គណា លោកអ្នកមានអាយុអង្គនោះ ត្រូវនិយាយឡើង ។

តជ្ជនីយកម្ម សង្ឃបានធ្វើដល់ពួកបណ្ឌកភិក្ខុនឹងលោហិតកភិក្ខុហើយ ការធ្វើនោះគាប់ចិត្តដល់សង្ឃ ព្រោះហេតុនោះបានជាសង្ឃស្ងៀម, ខ្ញុំចាំទុកនូវរឿងនេះ ដោយអាការស្ងៀមយ៉ាងនេះ" ។

ភិក្ខុដែលសង្ឃបានធ្វើតជ្ជនីយកម្មហើយ ត្រូវប្រព្រឹត្តវត្ត ១៨ ប្រការដូចតទៅនេះគឺ

១- ន ឧបសម្បាទេតព្វំ មិនត្រូវឲ្យឧបសម្បទាដល់កុលបុត្រ,

២- ន និស្សយោ ទាតព្វោ មិនត្រូវឲ្យនិស្ស័យដល់ភិក្ខុឬសាមណេរ,

៣- ន សាមណេរោ ឧបដ្ឋាបេតព្វោ មិនត្រូវឲ្យសាមណេរបំរើខ្លួន,

៤- ន ភិក្ខុនោវាទកសម្មតិ សាទិតព្វា មិនត្រូវត្រេកអរនឹងការសន្មតិឲ្យជាអ្នកទូន្មានភិក្ខុនី,

៥- សម្មតេនបិ ភិក្ខុនិយោ ន ឱវទិតព្វោ បើទុកជាបានការសន្មតិអំពីសង្ឃរួចហើយ ក៏មិនត្រូវទូន្មានភិក្ខុនីដែរ.

៦- យាយ អាបត្តិយា សង្ឃេន តជ្ជនីយកម្មំ កតំ ហោតិ សា អាបត្តិ ន អាបជ្ជិតព្វា សង្ឃបានធ្វើតជ្ជនីយកម្មដោយអាបត្តិណា មិនគប្បីឲ្យត្រូវអាបត្តិនោះទៀតឡើយ,

៧- អញ្ញា វា តាទិសិកា ឬអាបត្តិដទៃប្រហែលគ្នានឹងអាបត្តិនោះ ក៏មិនគប្បីឲ្យត្រូវដែរ,

៨- តតោ វា បាបិដ្ឋតរា ឬក៏អាបត្តិដែលធ្ងន់ជាងអាបត្តិនោះ ក៏មិនគប្បីឲ្យត្រូវដែរ;

៩- កម្មំ ន គរហិតព្វំ មិនត្រូវតិះដៀលតជ្ជនីយកម្ម,

១០- កម្មិកា ន គរហិតព្វា មិនត្រូវតិះដៀលពួកភិក្ខុអ្នកធ្វើតជ្ជនីយកម្ម,

១១- ន បកតត្តស្ស ភិក្ខុនោ ឧបោសថោ ឋបេ-តព្វោ មិនត្រូវហាមឧបោសថ ដល់ភិក្ខុជាបកតត្ត,

១២- ន បវារណា ឋបេតព្វា មិនត្រូវហាមបវារណា ដល់ភិក្ខុជាបកតត្ត,

១៣- ន សវចនីយំ កាតព្វំ មិនត្រូវធ្វើជាអ្នកមានមាត់ពាក្យ (ក្នុងអធិករណ៍នោះ),

១៤- ន អនុវាទោ បដ្ឋបេតព្វោ មិនត្រូវទទួលនាទីជាធំក្នុងវត្ត,

១៥- ន ឱកាសោ ការេតព្វោ មិនត្រូវឲ្យធ្វើឱកាស គឺមិនត្រូវសូមឱកាសភិក្ខុណាមួយ ដែលមានទោសកំហុស ដើម្បីចោទភិក្ខុនោះ

១៦- ន ចោទេតព្វោ មិនត្រូវចោទគេ (ដោយវត្ថុដោយអាបត្តិ),

១៧- ន សារេតព្វោ មិនត្រូវរំលឹក (ទោសអ្នកដទៃ),

១៨- ន ភិក្ខូ ភិក្ខូហិ សម្បយោជេតព្វំ មិនត្រូវប្រកបពួកភិក្ខុឲ្យឈ្លោះនឹងពួកភិក្ខុដទៃគ្នា ។

តជ្ជនីយកម្មដូចបាននិយាយហើយនេះ ហៅថា និស្សារណា (ការបណ្តេញ) ក្នុងញត្តិចតុត្ថកម្មកថានេះ ។

ចំណែកកម្មទាំង៦ដូចបានរាយឈ្មោះខាងដើមបន្ទាប់អំពីតជ្ជនីយកម្មនោះ មិនបានស្រង់យកមករៀបរៀងក្នុងទីនេះទេ ព្រោះមានទំនងបែបបទវិធីសូត្រញត្តិចតុត្ថកម្មវាចាស្រដៀងគ្នានឹងតជ្ជនីយកម្មនេះដែរ តែ

សូមបញ្ជាក់ថា កម្មទាំង៦នោះ ហៅថា និស្សារណា ដែរ ។

ឱសារណា ការហៅចូលមក ។ ហៅចូលមកក្នុងទីនេះ សំដៅយកការរម្ងាប់នូវកម្មទាំង ៧ ប្រការ មានតជ្ជនីយកម្មជាដើមនោះឯង ។ គឺការរម្ងាប់នូវតជ្ជនីយកម្មនោះ មានសេចក្តីថា ពួកបណ្ឌុកភិក្ខុនិងលោហិតកភិក្ខុ ដែលសង្ឃបានធ្វើតជ្ជនីយកម្មហើយ ប្រព្រឹត្តវត្តត្រឹមត្រូវ សម្យបរោម ប្រព្រឹត្ត នូវអំពើគួរដល់ការរលាស់ចេញចាកទោស ទើបចូលទៅរកភិក្ខុទាំងឡាយនិយាយអង្វរលួងលោមសូមទោសគ្រប់ប្រការ សាកសួរថា ត្រូវប្រតិបត្តិដូចម្តេចតទៅទៀត ? ទើបពួកភិក្ខុក្រាបបង្គំទូលព្រះមានព្រះភាគ , ព្រះអង្គទ្រង់អនុញ្ញាតឲ្យសង្ឃរម្ងាប់តជ្ជនីយកម្មដល់ពួកបណ្ឌុកភិក្ខុនិងលោហិតកភិក្ខុ ឯវិធីដែលរម្ងាប់នោះដូច្នេះ ៖ ត្រូវពួកបណ្ឌុកភិក្ខុនិងលោហិតកភិក្ខុនោះចូលទៅរកសង្ឃ ដណ្តប់ឧត្តរាសង្គឆៀងស្មាម្ខាង ថ្វាយបង្គំបាទានៃភិក្ខុចាស់ ៗ អង្គុយច្រហោងផ្គងអញ្ជលីឡើងសូត្រសូមថា មយំ ភន្តេ សង្ឃេន តជ្ជនី-យកម្មកតា សម្មា វត្តាម លោមំ បាតេម នេត្ថារំ វត្តាម តជ្ជនីយកម្មស្ស បដិប្បស្សទ្ធឹ យាចាម ។

"បពិត្រព្រះសង្ឃដ៏ចំរើន យើងទាំងឡាយដែលសង្ឃបានធ្វើតជ្ជនីយកម្ម ហើយ បានប្រព្រឹត្តវត្តត្រឹមត្រូវ សម្យបរោម ប្រព្រឹត្តនូវអំពើគួរដល់ការរលាស់ចេញចាកទោស, (ឥឡូវ) សូមនូវការរម្ងាប់(បំបាត់)នូវតជ្ជនីយ

កម្ម'' (សូត្រ៣ដង) ។ ភិក្ខុអ្នកឈ្លាសប្រតិពលត្រូវផ្ទៀងសង្ឃថា:

សុណាតុ មេ ភន្តេ សង្ឃោ ឥមេ បណ្ឌុកលោហិតកា ភិក្ខូ សង្ឃេន តជ្ជនីយកម្មកតា សម្មា វត្តន្តិ លោមំ បាតេន្តិ នេត្ថារំ វត្តន្តិ តជ្ជនីយកម្មស្ស បដិប្បស្សទ្ធឹ យាចន្តិ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ បណ្ឌុកលោហិតកានំ ភិក្ខូនំ តជ្ជនីយកម្មំ បដិប្បស្សម្ភេយ្យ ឯសា ញត្តិ ។

សុណាតុ មេ ភន្តេ សង្ឃោ ឥមេ បណ្ឌុកលោហិតកា ភិក្ខូ សង្ឃេន តជ្ជនីយកម្មកតា សម្មា វត្តន្តិ លោមំ បាតេន្តិ នេត្ថារំ វត្តន្តិ តជ្ជនីយកម្មស្ស បដិប្បស្សទ្ធឹ យាចន្តិ សង្ឃោ បណ្ឌុកលោហិតកានំ ភិក្ខូនំ តជ្ជនីយកម្មំ បដិប្បស្សម្ភេតិ យស្សាយស្មតោ ខមតិ បណ្ឌុកលោហិតកានំ ភិក្ខូនំ តជ្ជនីយកម្មស្ស បដិប្បស្សទ្ធិ សោ តុណ្ហាស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។

ទុតិយម្បិ ឯតមត្ថំ វទាមិ ។ សុណាតុ មេ ភន្តេ សង្ឃោ ។ បេ ។ យស្សាយស្មតោ ខមតិ បណ្ឌុកលោហិតកានំ ភិក្ខូនំ តជ្ជនីយកម្មស្ស បដិប្បស្សទ្ធិ

សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។

ទុតិយម្បិ ឯតមត្ថំ វទាមិ ។ សុណាតុ មេ ភន្តេ សង្ឃោ ។ បេ ។ យស្សាយស្មតោ ខមតិ បណ្ឌក-លោហិតកានំ ភិក្ខូនំ តជ្ជនីយកម្មស្ស បដិប្បស្សទ្ធិ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។

បដិប្បស្សទ្ធំ សង្ឃេន បណ្ឌកលោហិតកានំ ភិក្ខូនំ តជ្ជនីយកម្មំ ខមតិ សង្ឃស្ស តស្មា តុណ្ហី ឯវមេតំ ធារយាមិ ។

*បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំ ពួកបណ្ឌកភិក្ខុនិងលោហិតកភិក្ខុនេះ សង្ឃបានធ្វើតជ្ជនីយកម្មហើយ ប្រព្រឹត្តត្រឹមត្រូវ សម្មបរោម ប្រព្រឹត្តនូវអំពើគួរដល់ការរលាស់ចេញចាកទោស សូមនូវការរម្ងាប់នូវតជ្ជនីយកម្ម បើបដិប្បស្សទ្ធិកម្មមានកាលដ៏សមគួរដល់សង្ឃហើយ សង្ឃគប្បីរម្ងាប់នូវតជ្ជនីយកម្ម ដល់ពួកបណ្ឌកភិក្ខុនិងលោហិតកភិក្ខុ នេះហៅថា ញត្តិ ។*

*បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំ ពួកបណ្ឌកភិក្ខុនិងលោហិតកភិក្ខុនេះ សង្ឃបានធ្វើតជ្ជនីយកម្មហើយ ប្រព្រឹត្តត្រឹមត្រូវ សម្មបរោម ប្រព្រឹត្តនូវអំពើគួរដល់ការរលាស់ចេញចាកទោស សូមនូវការរម្ងាប់នូវតជ្ជនីយកម្ម (ឥឡូវ) សង្ឃរម្ងាប់តជ្ជនីយកម្ម ដល់ពួក*

បណ្ឌុកកិត្តិនឹងលោហិតកកិត្តិ ការរម្ងាប់នូវតជ្ជនីយកម្ម ដល់ពួកបណ្ឌុកកិត្តិនឹងលោហិតកកិត្តិ គាប់ចិត្តដល់លោកអ្នកមានអាយុអង្គណា លោកអ្នកមានអាយុអង្គនោះត្រូវស្ងៀម មិនគាប់ចិត្តដល់លោកអ្នកមានអាយុអង្គណា លោកអ្នកមានអាយុអង្គនោះត្រូវនិយាយឡើង ។

ខ្ញុំពោលនូវសេចក្តីនេះជាគំរប់ពីរដងទៀត ៖ បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំ ។ បេ ។ ការរម្ងាប់នូវតជ្ជនីយកម្មដល់ពួកបណ្ឌុកកិត្តិនឹងលោហិតកកិត្តិ គាប់ចិត្តដល់លោកអ្នកមានអាយុអង្គណា លោកអ្នកមានអាយុអង្គនោះត្រូវស្ងៀម, មិនគាប់ចិត្តដល់លោកអ្នកមានអាយុអង្គណា លោកអ្នកមានអាយុអង្គនោះ ត្រូវនិយាយឡើង ។

ខ្ញុំពោលនូវសេចក្តីនេះជាគំរប់បីដងទៀត ៖ បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំ ។បេ។ ការរម្ងាប់នូវតជ្ជនីយកម្មដល់ពួកបណ្ឌុកកិត្តិនឹងលោហិតកកិត្តិ គាប់ចិត្តដល់លោកអ្នកមានយុអង្គណា លោកអ្នកមានអាយុអង្គនោះត្រូវស្ងៀម មិនគាប់ចិត្តដល់លោកអ្នកមានអាយុអង្គណា លោកអ្នកមានអាយុអង្គនោះ ត្រូវនិយាយឡើង ។

តជ្ជនីយកម្ម សង្ឃបានរម្ងាប់ហើយ ដល់ពួកបណ្ឌុកកិត្តិនឹងលោហិ-តកកិត្តិ, ការរម្ងាប់នោះគាប់ចិត្តដល់សង្ឃ ព្រោះហេតុនោះបានជាសង្ឃស្ងៀម, ខ្ញុំចាំទុកនូវរឿងនេះ ដោយអាការស្ងៀមយ៉ាងនេះ" ។

ការរម្ងាប់នូវតជ្ជនីយកម្ម ដោយញត្តិចតុត្ថកម្មវាចា ដូចបាននិយាយ

មកនេះ ហៅថា ឧសារណា (ការហៅចូលមក) ក្នុងញត្តិចតុត្ថកម្មថា នេះ ។

ការរម្ងាប់នូវកម្មទាំង ៦ ជាលំដាប់នៃតជ្ជនីយកម្មនេះ មិនបានស្រង់យកមករៀបរៀងក្នុងទីនេះទេ ព្រោះមានទំនងបែបបទប្រហែលគ្នានឹងការរម្ងាប់នូវតជ្ជនីយកម្មនេះដែរ គ្រាន់តែបញ្ជាក់ថា ការរម្ងាប់នូវកម្មទាំង ៦ នោះក៏ហៅថា ឧសារណា ដែរ ។

សម្មុតិ ការសន្មតិ ។ សន្មតិក្នុងទីនេះ សំដៅយកភិក្ខុនោវា-ទកសម្មតិ ការសន្មតិនូវភិក្ខុឲ្យជាអ្នកឱវាទភិក្ខុនី ដូចមានរឿងក្នុងសិក្ខាបទទី ១ នៃឱវាទវគ្គ បាចិត្តិយកណ្ឌ ភិក្ខុវិភង្គថា សម័យនោះព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋីជិតក្រុងសាវត្ថី ។ សម័យនោះឯង ភិក្ខុជាថេរៈទាំងឡាយនាំគ្នាឱវាទពួកភិក្ខុនី តែងបាននូវចីវរ បិណ្ឌបាត សេនាសនៈ និងគិលាន-ភេសជ្ជៈជាច្រើន, ពួកឆព្វគ្គិយភិក្ខុដឹងហេតុនោះហើយ មានបំណងចង់បានលាភដូច្នោះ ក៏នាំគ្នាចូលទៅរកពួកភិក្ខុនី និយាយប្រលោមល្បួងទាក់ទាញពួកភិក្ខុនី ឲ្យទៅស្តាប់ឱវាទខ្លួន ។ ពួកភិក្ខុនីក៏នាំគ្នាចូលទៅរកពួកឆព្វគ្គិយភិក្ខុ ដើម្បីស្តាប់ឱវាទ ។ ពួកឆព្វគ្គិយភិក្ខុនោះ ធ្វើនូវធម្មីកថាបន្តិចបន្តួចសួចស្តើង ច្រើនតែនិយាយពាក្យតិរច្ឆានកថាមានប្រការផ្សេង ៗ ហើយបញ្ជូនពួកភិក្ខុនីឲ្យត្រឡប់ទៅវិញ ។ ពួកភិក្ខុនី

នាំគ្នាចូលទៅក្រាបបង្គំគាល់ព្រះមានព្រះភាគ។ ព្រះអង្គទ្រង់សាកសួរអំពីឱវាទរបស់ភិក្ខុ តើនឹងមានសារប្រយោជន៍ទូលំទូលាយល្មមជាផ្លូវប្រតិបត្តិបានឬទេ ? ពួកភិក្ខុនីក្រាបបង្គំទូលអំពីឱវាទនោះថា ពុំសូវមានសារប្រយោជន៍ប៉ុន្មានទេ ព្រោះពួកឆព្វគ្គិយភិក្ខុធ្វើធម្មីកថាបន្តិចបន្តួចស្តួចស្តើង ច្រើនតែនិយាយពាក្យតិរច្ឆានកថា ឥតប្រយោជន៍ ហើយបញ្ជូនឲ្យត្រឡប់មកកាន់លំនៅវិញ ។ ព្រះមានព្រះភាគទ្រង់ព្រះតម្រិះថា អំពើរបស់ភិក្ខុទាំងនោះ នាំមិនឲ្យចំរើនក្នុងធម្មវិន័យ ទើបទ្រង់រកឧបាយនឹងបិទផ្លូវ មិនឲ្យពួកភិក្ខុប្រព្រឹត្តអំពើដូច្នោះទៀត ទើបទ្រង់អនុញ្ញាតថា អនុជានាមិ ភិក្ខវេ ភិក្ខុនោវាទកំ សម្មន្និតុំ "ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតនូវការសន្មតិនូវភិក្ខុឲ្យជាអ្នកទូន្មានឬប្រដៅភិក្ខុនី" ។ ត្រូវសន្មតយ៉ាងនេះ ៖ ត្រូវអង្វរភិក្ខុនោះជាមុន លុះអង្វររួចហើយ ភិក្ខុអ្នកឈ្លាសប្រតិពលត្រូវផ្ទៀងសង្ឃថា :

សុណាតុ មេ ភន្តេ សង្ឃោ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ (ឥត្ថន្នាមំ) ភិក្ខុំ ភិក្ខុនោវាទកំ សម្មន្នេយ្យ ឯសា ញត្តិ ។

សុណាតុ មេ ភន្តេ សង្ឃោ សង្ឃោ (ឥត្ថន្នាមំ) ភិក្ខុំ ភិក្ខុនោវាទកំ សម្មន្នតិ យស្សាយស្មតោ ខមតិ (ឥត្ថន្នាមស្ស) ភិក្ខុនោ ភិក្ខុនោវាទកស្ស សម្មតិ

សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។

ទុតិយម្បិ ឯតមត្ថំ វទាមិ ។ បេ ។ តតិយម្បិ ឯតមត្ថំ វទាមិ ។បេ។ សុណាតុ មេ ភន្តេ សង្ឃោ សង្ឃោ (ឥត្ថន្នាមំ) ភិក្ខុំ ភិក្ខុនោវាទកំ សម្មន្នតិ យស្សាយស្មតោ ខមតិ (ឥត្ថន្នាមស្ស) ភិក្ខុនោ ភិក្ខុនោវាទកស្ស សម្មុតិ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។

សម្មតោ សង្ឃេន (ឥត្ថន្នាមោ) ភិក្ខុ ភិក្ខុនោវាទកោ ខមតិ សង្ឃស្ស តស្មា តុណ្ហី ឯវមេតំ ធារយាមិ។

"បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំ បើសម្មតិកម្ម មានកាលដ៏សមគួរដល់សង្ឃហើយ សង្ឃគប្បីសន្មតនូវភិក្ខុ (ឈ្មោះនេះ) ឲ្យជាអ្នកទូន្មានភិក្ខុនី នេះហៅថា ញត្តិ ។

បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំ សង្ឃសន្មត នូវភិក្ខុ ( ឈ្មោះនេះ ) ឲ្យជាអ្នកទូន្មានភិក្ខុនី ការសន្មតិភិក្ខុ (ឈ្មោះនេះ ) ឲ្យជាអ្នកទូន្មានភិក្ខុនី គាប់ចិត្តដល់លោកអ្នកមានអាយុអង្គណា លោកអ្នកមានអាយុអង្គនោះត្រូវស្ងៀម មិនគាប់ចិត្តដល់លោកអ្នកមាន អាយុអង្គណា លោកអ្នកមានអាយុអង្គនោះត្រូវនិយាយឡើង ។

ខ្ញុំពោលនូវសេចក្តីនេះជាគំរប់ពីរដងទៀត ។ បេ ។ ខ្ញុំពោលនូវ

សេចក្ដីនេះជាគំរប់បីដងទៀត ៖ បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្ដាប់ពាក្យខ្ញុំ សង្ឃសន្មតនូវភិក្ខុ ( ឈ្មោះនេះ ) ឲ្យជាអ្នកទូន្មានភិក្ខុនី ការសន្មតិនូវភិក្ខុ ( ឈ្មោះនេះ ) ឲ្យជាអ្នកទូន្មានភិក្ខុនី គាប់ចិត្តដល់លោកអ្នកមានអាយុអង្គណា លោកអ្នកមានអាយុអង្គនោះត្រូវស្ងៀម មិនគាប់ចិត្តដល់លោកអ្នកមានអាយុអង្គណា លោកអ្នកមានអាយុអង្គនោះត្រូវនិយាយឡើង ។

ភិក្ខុ ( ឈ្មោះនេះ ) សង្ឃបានសន្មតហើយឲ្យជាអ្នកទូន្មានភិក្ខុនី ការសន្មតិនោះគាប់ចិត្តដល់សង្ឃ ព្រោះហេតុនោះបានជាសង្ឃស្ងៀម ខ្ញុំចាំទុកនូវរឿងនេះ ដោយអាការស្ងៀមយ៉ាងនេះ”

លំដាប់នោះ ព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទថា យោ បន ភិក្ខុ អសម្មតោ ភិក្ខុនិយោ ឱវទេយ្យ បាចិត្តិយំ “ភិក្ខុណាមួយដែលសង្ឃមិនបានសន្មតហើយ ទូន្មានភិក្ខុនីត្រូវអាបត្តិបាចិត្តិយៈ” ។

ដែលទ្រង់អនុញ្ញាតឲ្យសង្ឃសន្មតដោយញត្តិចតុត្ថកម្មវាចា ព្រមទាំងបញ្ញត្តសិក្ខាបទជាអាបត្តិបាចិត្តិយៈនេះ ដើម្បីបិទផ្លូវមិនឲ្យភិក្ខុខ្លះទូន្មានភិក្ខុនី លុះតែបានសន្មតអំពីសង្ឃទើបទូន្មានបាន ។

សម័យនោះឯង ពួកភិក្ខុជាថេរៈបានសន្មតអំពីសង្ឃហើយ ក៏នាំគ្នាឲ្យឱវាទភិក្ខុនី កើតលាភសក្ការៈ គឺបច្ច័យ ៤ ជាច្រើន , ពួកឆព្វគ្គិយ-ភិក្ខុបានដឹងបានឃើញដូច្នោះហើយ ក៏នាំគ្នាចេញទៅក្រៅសីមា សន្មត

ក្តីគ្នាហើយចូលទៅរកភិក្ខុនី ប្រាប់ថាខ្លួនបានសន្មតអំពីសង្ឃសព្វគ្រប់ហើយ គួរនឹងឲ្យឱវាទភិក្ខុនីបាន ។ ពួកភិក្ខុនីក៏នាំគ្នាចូលទៅរកពួកឆព្វគ្គិយភិក្ខុដើម្បីស្តាប់ឱវាទ ។ ពួកឆព្វគ្គិយភិក្ខុក៏ធ្វើធម្មីកថាបន្តិចបន្តួចស្តួចស្តើង ច្រើនតែនិយាយពាក្យតិរច្ឆានកថាឥតប្រយោជន៍ ក៏បញ្ជូនឲ្យត្រឡប់ទៅវិញដូចរឿងមុនដែរ ។ ពួកភិក្ខុនីនោះ ចូលទៅក្រាបបង្គំគាល់ព្រះមានព្រះភាគ. ព្រះអង្គទ្រង់សាកសួរអំពីឱវាទរបស់ភិក្ខុ តើមានប្រយោជន៍យ៉ាងណាខ្លះ ? ពួកភិក្ខុនីក្រាបបង្គំទូលអំពីឱវាទរបស់ពួកឆព្វគ្គិយភិក្ខុ ថាមានប្រយោជន៍ស្តួចស្តើង ច្រើនតែពាក្យតិរច្ឆានកថាឥតប្រយោជន៍ ទើបព្រះអង្គទ្រង់អនុញ្ញាតឲ្យសន្មតនូវភិក្ខុប្រកបដោយអង្គ ៨ ឲ្យជាអ្នកទូន្មានភិក្ខុនី, អង្គ ៨ នោះគឺ

១- សីលវា ហោតិ បាតិមោក្ខសំវរសំវុតោ វិហរតិ អាចារគោចរសម្បន្នោ អណុមត្តេសុ វជ្ជេសុ ភយទស្សាវី សមាទាយ សិក្ខតិ សិក្ខាបទេសុ ភិក្ខុអ្នកមានសីល បានសង្រួមតាមព្រះបាតិមោក្ខសំវរៈ បរិបូណ៌ដោយអាចារៈនិងគោចរៈ ឃើញភ័យក្នុងទោសគ្រាន់តែបន្តិចបន្តួច សមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ ។

២- ពហុស្សុតោ ហោតិ សុតធរោ សុតសន្និចយោ យេ តេ ធម្មា អាទិកល្យាណា មជ្ឈេកល្យាណា

បរិយោសានកល្យាណា សាត្ថំ សព្យញ្ជនំ កេវលបរិ-
បុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ អភិវទន្តិ តថារូបាស្ស ធម្មា
ពហុស្សុតា ហោន្តិ ធតា វចសា បរិចិតា មនសានុបេ-
ក្ខិតា ទិដ្ឋិយា សុប្បដិវិទ្ធា ជាអ្នកមានពុទ្ធវចនៈច្រើន ទ្រទ្រង់នូវ
ពុទ្ធវចនៈ សន្សំទុកនូវពុទ្ធវចនៈ ធម៌ទាំងឡាយណាល្អខាងដើម ល្អត្រង់
កណ្តាល ល្អខាងចុង តែងប្រកាសនូវព្រហ្មចរិយធម៌ ព្រមទាំងអត្ថ ព្រម
ទាំងព្យញ្ជនៈ ដ៏បរិសុទ្ធ បរិបូណ៌ទាំងអស់ ធម៌ទាំងឡាយមានសភាព
ដូច្នោះ ភិក្ខុនោះបានដឹងដោយច្រើន បានទ្រទ្រង់ បានចាំស្ទាត់រត់មាត់
បានចូលចិត្តច្បាស់លាស់ បានយល់ត្រូវល្អ ដោយទិដ្ឋិ គឺបញ្ញា ។

៣- ឧភយានិ ខោបនស្ស បាតិមោក្ខានិ វិត្ថា-
រេន ស្វាគតានិ ហោន្តិ សុវិភត្តានិ សុប្បវត្តីនិ សុវិនិច្ឆិ-
តានិ សុត្តសោ អនុព្យញ្ជនសោ បាតិមោក្ខទាំងពីរ ភិក្ខុនោះ
បានបេះចាំដោយពិស្តារ បានចែកដោយល្អ ស្ទាត់ជំនាញ បានវិនិច្ឆ័យ
ដោយល្អ ដោយសុត្តៈ គឺប្រយោគ ឬ ឧទាហរណ៍ ដែលគួរទាញ
យកមកអំពីខន្ធកៈនិងបរិវារៈ បានវិនិច្ឆ័យដោយល្អ ដោយអនុព្យញ្ជនៈ
គឺអក្ខរៈនិងបទដែលបរិបូណ៌មិនវិបរិត ។

៤- កល្យាណវាចោ ហោតិ កល្យាណវាក្ក-
រណោ ជាអ្នកមានវាចាពីរោះ មានសំឡេងពីរោះ ។

៥- យេភុយ្យេន ភិក្ខុនីនំ បិយោ ហោតិ មនាបោ ជាទីស្រឡាញ់ ជាទីគាប់ចិត្ត នៃភិក្ខុនីទាំងឡាយដោយច្រើន ។

៦- បដិពលោ ហោតិ ភិក្ខុនិយោ ឱវទិតុំ អាចដើម្បីទូន្មាននូវភិក្ខុនីទាំងឡាយបាន ។

៧- ន ខោ បនេតំ ភគវន្តំ ឧទ្ទិស្ស បព្វជិតាយ កាសាយវត្ថវសនាយ គរុធម្មំ អជ្ឈាបន្នបុព្វោ ហោតិ មិនធ្លាប់ប្រព្រឹត្តកន្លងនូវគរុធម៌ ដោយស្ត្រីដែលស្លៀកសំពត់ជ្រលក់ទឹកអម្ចត់ ដែលបួសឧទ្ទិសព្រះមានព្រះភាគនេះ គឺជាក្នុងកាលនៃខ្លួនជាគ្រហស្ថ មិនដែលចាប់ពាល់កាយភិក្ខុនី ឬមិនដែលសេពមេថុនធម្មនឹងសិក្ខមានា ឬសាមណេរីឡើយ ។

៨- វីសតិវស្សោ វា ហោតិ អតិរេកវីសតិវស្សោ វា មានវស្សា ២០ ឬមានវស្សាច្រើនជាង ២០ ។

ភិក្ខុប្រកបដោយអង្គ ៨ នេះ ទើបគួរសន្មតឲ្យជាអ្នកទូន្មានភិក្ខុនី ។

ការសន្មតិនូវភិក្ខុឲ្យជាអ្នកទូន្មានភិក្ខុនី ដូចបាននិយាយមកនេះ ហៅថា សម្មតិក្នុងញត្តិចតុត្ថកម្មកថានេះ ។

ខាង ការឲ្យ ៗ ឲ្យក្នុងទីនេះ សំដៅយក បរិវាសខាង "ការឲ្យនូវបរិវាស" នឹង មានត្តខាង "ការឲ្យនូវមានត្ត ដល់ភិក្ខុដែលគួរដល់បរិវាសនឹងមានត្ត" ។

បរិវាសនោះមាន ៣ យ៉ាងគឺ បដិច្ឆន្នបរិវាសោ បរិវាសដែលសង្ឃគប្បីឲ្យដោយអាបត្តិដែលភិក្ខុបិទបាំងទុក ១ សុទ្ធន្តបរិវាសោ បរិវាសដែលសង្ឃគប្បីឲ្យតាមកំណត់កាលដែលមានបរិសុទ្ធជាទីបំផុត ១ សមោធានបរិវាសោ បរិវាសដែលសង្ឃគប្បីឲ្យដោយការប្រជុំអាបត្តិ ១ ។ បដិច្ឆន្នបរិវាសនោះ មានប្រភេទច្រើនទៀត បើអាបត្តិដែលភិក្ខុបិទបាំង ១ ថ្ងៃ ហៅថា ឯកាហបរិវាស, បិទបាំង ២ ថ្ងៃ ហៅថា ទ្វិហបរិវាស, បិទបាំង ៣ ថ្ងៃ ហៅថា តិហបរិវាស ។ល។

ឯអាការដែលបិទបាំងនោះមាន ១០ តែទៅជាគូ ៗ មាន ៤ គូគឺ អាបត្តិ ច ហោតិ អាបត្តិសញ្ញី ច អាបត្តិ ១ ភិក្ខុមានសេចក្តីសំគាល់ថាអាបត្តិ ១ ; សេចក្តីថា អាបត្តិនោះ សំដៅយកអាបត្តិដែលភិក្ខុនោះត្រូវ ភិក្ខុនោះដឹងច្បាស់ថាខ្លួនត្រូវអាបត្តិនោះហើយបិទបាំងទុកមិនប្រាប់គេ ហៅថា បិទបាំង, បើសំគាល់ថា មិនមានអាបត្តិទេ មិនឈ្មោះថាបិទបាំងឡើយ ; បើមិនមានអាបត្តិទេ តែបិទបាំងដោយសំគាល់ថាអាបត្តិក៏ដោយ មិនមានអាបត្តិក៏ដោយ ក៏ឈ្មោះថាមិនបិទបាំងដែរ ។ ភិក្ខុបិទបាំងលហុកាបត្តិដោយសំគាល់ថាគរុកាបត្តិក្តី បិទបាំងគរុកាបត្តិដោយសំគាល់ថាលហុកាបត្តិក្តី គ្រាន់តែតាំងនៅក្នុងចំណែកនៃអលជ្ជី តែមិនឈ្មោះថា បិទបាំងអាបត្តិឡើយ ។ ភិក្ខុសំគាល់នូវគរុកាបត្តិ ថាជាលហុកាបត្តិ ហើយសំដែងអាបត្តិនោះ ៗ មិនឈ្មោះថា

សំដែងទេ គឺមិនដាច់ ប៉ុន្តែមិនឈ្មោះថាបិទបាំងឡើយ[១] ។ ភិក្ខុដឹងនូវគរុកាបត្តិថាជាគរុកាបត្តិមែន ហើយបិទបាំងទុក ដោយគិតថា អាត្មាអញបិទបាំងអាបត្តិ អាបត្តិនោះឈ្មោះថា បិទបាំងហើយ ។

បកតត្តោ ច ហោតិ បកតត្តសញ្ញី ច ភិក្ខុជាបកតត្ត ១ សំគាល់ខ្លួនថាជាបកតត្ត ១; សេចក្តីថា ភិក្ខុជាបកតត្តនោះ សំដៅយកភិក្ខុដែលសង្ឃមិនបានធ្វើ ឧក្ខេបនីយកម្ម ៣ យ៉ាងគឺ ឧក្ខេបនីយកម្ម ព្រោះមិនឃើញអាបត្តិ ១ មិនសំដែងអាបត្តិ ១ មិនលះបង់ទិដ្ឋិអាក្រក់ ១ បើភិក្ខុនោះសំគាល់ខ្លួនថាជាបកតត្ត ហើយបិទបាំងអាបត្តិទុក អាបត្តិនោះឈ្មោះថា បិទបាំងហើយ ។ ភិក្ខុដឹងថា សង្ឃធ្វើកម្មដល់អាត្មាអញហើយ សំគាល់ខ្លួនថាមិនមែនជាបកតត្ត ហើយលាក់អាបត្តិទុក អាបត្តិនោះមិនឈ្មោះថាលាក់ទេ ។ ភិក្ខុមិនមែនជាបកតត្ត ទោះសំគាល់ខ្លួនថាជាបកតត្តក្តី មិនមែនជាបកតត្តក្តី ហើយលាក់អាបត្តិទុក អាបត្តិនោះក៏មិនឈ្មោះថាលាក់ដែរ ។

អនន្តរាយិកោ ច ហោតិ អនន្តរាយិកសញ្ញី ច ភិក្ខុគ្មានសេចក្តីអន្តរាយ ១ សំគាល់ខ្លួនថា គ្មានសេចក្តីអន្តរាយ ១ ;

---

១ សេចក្តីក្នុងប្រយោគនេះ ដែលអ្នកប្រាជ្ញអំពីបុរាណ ប្រើផ្ទឹសំដែងអាបត្តិថា សព្វា គរុលហុកា អាបត្តិយោ អារោចេមិ "ខ្ញុំសូមប្រាប់នូវគរុកាបត្តិនឹងលហុកាបត្តិទាំងអស់" ។

សេចក្ដីថា បណ្ដាអន្តរាយទាំង១០យ៉ាង[១] សូម្បីអន្តរាយតែ១ក៏គ្មានដល់ភិក្ខុណា បើភិក្ខុនោះសំគាល់ខ្លួនថាគ្មានអន្តរាយទេ ហើយលាក់អាបត្តិទុក អាបត្តិនោះឈ្មោះថាលាក់ហើយ ។ បើភិក្ខុនោះជាអ្នកខ្លាចច្រើន សំគាល់ខ្លួនថាមានអន្តរាយ ព្រោះខ្លាចខ្មោចនឹងម្រឹគកាចក្នុងពេលងងឹតហើយលាក់អាបត្តិទុក អាបត្តិនោះមិនឈ្មោះថាលាក់ទេ ។ ភិក្ខុណានៅក្នុងវត្តលើភ្នំ ទោះបីផ្លូវជ្រោះភ្នំក៏ដោយ ផ្លូវព្រៃក៏ដោយផ្លូវស្ទឹងក៏ដោយ គួរទៅប្រាប់អាបត្តិកុំខាន ។ ទោះបីមានភ័យអំពីខ្មោចកាចសាហាវជាដើមនៅពាក់កណ្ដាលផ្លូវ ឬមានពស់ថ្លាន់នៅកណ្ដាលផ្លូវឬស្ទឹងពេញពោរដោយទឹកដំ

---

១ អន្តរាយ១០យ៉ាងនោះគឺ

១- រាជន្តរាយោ អន្តរាយអំពីព្រះរាជា គឺមានស្ដេចយាងចូលមក

២- ចោរន្តរាយោ អន្តរាយអំពីចោរ គឺមានចោរចូលមកលុកលុយ

៣- អគ្យន្តរាយោ អន្តរាយអំពីភ្លើង គឺមានភ្លើងព្រៃឆេះរាលមក ឬភ្លើងផ្ទះជាដើមកើតឡើង

៤- ឧទកន្តរាយោ អន្តរាយអំពីទឹក គឺមានភ្លៀងខ្លាំងឬជំនន់ហូរមក

៥- មនុស្សន្តរាយោ អន្តរាយអំពីមនុស្ស គឺមានមនុស្សច្រើនចូលមក

៦- អមនុស្សន្តរាយោ អន្តរាយអំពីអមនុស្ស គឺខ្មោចចូលភិក្ខុ

៧- វាឡន្តរាយោ អន្តរាយអំពីសត្វសាហាវ

៨- សិរិសបន្តរាយោ អន្តរាយអំពីសត្វទីឃជាតិ គឺពួកសត្វលូនវារ

៩- ជីវិតន្តរាយោ អន្តរាយដល់ជីវិត គឺមានភិក្ខុកើតជម្ងឺស្លាប់ ឬមានមនុស្សជាសត្រូវបង
សម្លាប់ភិក្ខុ

១០- ព្រហ្មចរិយន្តរាយោ អន្តរាយដល់ព្រហ្មចារ្យ គឺមានមនុស្សមកចាប់ភិក្ខុផ្សឹក ។

( ឧបោសថក្ខន្ធកៈ )

ននំ, កាលបើមានហេតុយ៉ាងនេះ ភិក្ខុសំគាល់ថាមានអន្តរាយហើយលាក់អាបត្តិទុក អាបត្តិនោះមិនឈ្មោះថាលាក់ឡើយ ។ ភិក្ខុមានអន្តរាយពិត ៗ ហើយលាក់អាបត្តិដោយស្មានថា គ្មានអន្តរាយទៅវិញ អាបត្តិនោះក៏មិនឈ្មោះថាលាក់ដែរ ។

បហុ ច ហោតិ បហុសញ្ញី ច ភិក្ខុអាច ១ មានសេចក្តីសំគាល់ថាអាច ១ ; សេចក្តីថា ភិក្ខុណាអាចដើម្បីទៅកាន់សំណាក់ភិក្ខុផងគ្នាបានផង ដើម្បីប្រាប់ភិក្ខុផងគ្នាបានផង បើភិក្ខុនោះសំគាល់ខ្លួនថាអាចហើយលាក់អាបត្តិទុក អាបត្តិនោះឈ្មោះថាលាក់ហើយ ។ បើមានកើតបូសបន្តិចបន្តួចត្រង់មុខនៃភិក្ខុនោះ ឬឈឺថ្គាមឬក៏ឈឺធ្មេញ ឬពុំនោះបានចង្ហាន់តិចមិនល្មមផ្អែត ហេតុតែប៉ុណ្ណោះមិនមែនជាមិនអាចដើម្បីប្រាប់មិនមែនជាមិនអាចដើម្បីទៅឡើយ បើសំគាល់ខ្លួនថាមិនអាចទេ ភិក្ខុនេះឈ្មោះថាអាច ប៉ុន្តែសំគាល់ខ្លួនថាមិនអាចទៅវិញ បើលាក់អាបត្តិដោយហេតុនេះ អាបត្តិនោះឈ្មោះថាមិនលាក់ទេ ។ ភិក្ខុមិនអាចដើម្បីប្រាប់ក្តីមិនអាចដើម្បីទៅក្តី ទោះបីសំគាល់ថាអាចក៏ដោយ ថាមិនអាចក៏ដោយហើយលាក់អាបត្តិទុកមិនប្រាប់គេ អាបត្តិនោះមិនឈ្មោះថាលាក់ឡើយ ។

ឆាទេតុកាមោ ច ហោតិ ឆាទេតិ ច ភិក្ខុមានបំណងនឹងលាក់អាបត្តិ ១ លាក់អាបត្តិ ១ ; សេចក្តីថា ភិក្ខុណាមានបំណងនឹងលាក់បំបិទបំបាំងអាបត្តិ បើភិក្ខុនោះឥតមានអន្តរាយអ្វីទេ ឥត

មានទំនាស់អ្វីទេ ហើយលាក់បំបិទបំបាំងអាបត្តិតាមបំណងនោះ អាបត្តិនោះឈ្មោះថាលាក់ហើយ ។ បើភិក្ខុណាដាក់ធុរៈថានឹងលាក់បាំងអាបត្តិ លុះដល់មកពេលមុនភត្តក្តី ក្រោយភត្តក្តី ឬពេលបឋមយាមជាដើមក្តី ក៏ស្រាប់តែកើតលជ្ជីធម៌ឡើង បែរទៅជាប្រាប់អាបត្តិ ក្នុងខាងក្នុងនៃអរុណ គឺក្នុងពេលអរុណមិនទាន់រះ ភិក្ខុនេះឈ្មោះថាមានបំណងនឹងលាក់ ប៉ុន្តែបែរជាមិនលាក់ទៅវិញ ។ ភិក្ខុណានៅក្នុងទីដែលគ្មានភិក្ខុ ហើយត្រូវគរុ-អាបត្តិ ក៏បង្អង់រង់ចាំមើលភិក្ខុជាសភាគៈ ឬមកកាន់សំណាក់ភិក្ខុជាសភាគៈ កន្លងកាលទៅចំនួនកន្លះខែក្តី មួយខែក្តី ភិក្ខុនេះឈ្មោះថាគ្មានបំណងនឹងលាក់ទេ តែត្រឡប់ទៅជាលាក់ ប៉ុន្តែអាបត្តិនេះមិនឈ្មោះថាលាក់ឡើយ ។ ភិក្ខុណាត្រូវអាបត្តិក្តាម ៗ ប្រញាប់ប្រញាល់ទៅកាន់សំណាក់ នៃសភាគភិក្ខុប្រាប់អាបត្តិក្តាម ៗ ប្រៀបដូចបុរសជាន់ភ្លើង ភិក្ខុនេះឈ្មោះថាគ្មានបំណងដើម្បីលាក់ផងមិនលាក់ផង ។ បើបានជួបនឹងសភាគភិក្ខុហើយ តែមិនបានប្រាប់អាបត្តិព្រោះអៀនខ្មាសថា ភិក្ខុនេះជាឧបជ្ឈាយ៍ឬអាចារ្យរបស់ខ្លួន, ហេតុដែលនាំឲ្យអាក់ខានប្រាប់អាបត្តិកើតអំពីឧបជ្ឈាយ៍ឬអា-ចារ្យជាដើម យកជាប្រមាណក្នុងរឿងនេះពុំបានឡើយ, បើដំណើរដែលភិក្ខុមិនមែនជាសត្រូវផង ជាសភាគៈផង ទើបយកជាប្រមាណបាន, ព្រោះហេតុនោះ ត្រូវប្រាប់អាបត្តិក្នុងសំណាក់នៃភិក្ខុមិនមែនជាសត្រូវនឹងភិក្ខុជាសភាគៈ ជាការគួរ ។ ភិក្ខុណាមួយជាសភាគៈ មានបំណងដើម្បី-

ប្រកាសទោស ព្រោះឮដំណឹងថា ត្រូវអាបត្តិ , មិនត្រូវប្រាប់អាបត្តិដល់ភិក្ខុថែបនោះឡើយ ទោះបីជាឧបជ្ឈាយ៍ក៏ដោយ ៗ បើត្រូវអាបត្តិក្នុងពេលមុន ភត្តក្តី ក្រោយភត្តក្តី ពេលថ្ងៃក្តី យប់ក្តី ត្រូវប្រាប់អាបត្តិឲ្យឆាប់ ៗ កុំឲ្យអរុណថ្មីរះឡើងទាន់ បើអរុណរះឡើងហើយ អាបត្តិនោះឈ្មោះថាបិទបាំងហើយ ភិក្ខុត្រូវអាបត្តិទុក្កដទៀតផង ព្រោះហេតុបិទបាំងអាបត្តិ ៗ ការប្រាប់អាបត្តិក្នុងសំណាក់ភិក្ខុដែលត្រូវអាបត្តិសង្ឃាទិសេសដូចគ្នាពុំគួរឡើយ ប៉ុន្តែបើប្រាប់ក៏ឈ្មោះថាបានប្រាប់អាបត្តិហើយស្រេច មិនឈ្មោះថាលាក់អាបត្តិទេ តែគង់មិនរួចអំពីអាបត្តិទុក្កដ ព្រោះហេតុនោះគួរប្រាប់អាបត្តិក្នុងសំណាក់ភិក្ខុដែលបរិសុទ្ធ ៗ ភិក្ខុដែលប្រាប់អាបត្តិ ប្រាប់ថា តុយ្ហំ សន្តិកេ ឯកំ អាបត្តឹ អាវិ-ករោមិ "ខ្ញុំធ្វើឲ្យជាក់ច្បាស់នូវអាបត្តិ ១ ក្នុងសំណាក់នៃលោក" ដូច្នេះក៏បាន តុយ្ហំ សន្តិកេ ឯកំ អាបត្តឹ អាចិក្ខាមិ "ខ្ញុំប្រាប់នូវអាបត្តិ ១ ក្នុងសំណាក់នៃលោក" ដូច្នេះក៏បាន តុយ្ហំ សន្តិកេ ឯកំ អាបត្តឹ អារោចេមិ "ខ្ញុំផ្ដៀងនូវអាបត្តិ ១ ក្នុងសំណាក់នៃលោក" ដូច្នេះក៏បាន; មម ឯកំ អាបត្តឹ អាបន្ន-ភាវំ ធារេហិ "ចូរលោកដឹងនូវដំណើរនៃខ្ញុំត្រូវអាបត្តិ ១" ដូច្នេះក៏បាន; ឯកំ គរុកាបត្តឹ អាវិករោមិ "ខ្ញុំធ្វើឲ្យជាក់ច្បាស់នូវគរុកាបត្តិ ១" ដូច្នេះក៏បាន ៗ កាលបើបានប្រាប់ដូច្នេះហើយ ឈ្មោះថា

មិនបិទបាំងអាបត្តិទេ ។ បើប្រាប់ថា លហុកាបត្តឹ អាវិករោមិ "ខ្ញុំធ្វើឲ្យជាក់ច្បាស់នូវលហុកាបត្តិ" ដូច្នេះ ឈ្មោះថាបិទបាំងអាបត្តិ ។ ប្រាប់វត្ថុក៏បាន ប្រាប់អាបត្តិក៏បាន ប្រាប់ទាំងវត្ថុទាំងអាបត្តិក៏បាន ទាំង៣យ៉ាងនេះ ឈ្មោះថាបានប្រាប់អាបត្តិហើយ ។ វិនយធរអ្នកឲ្យនូវបដិច្ឆន្នបរិវាស ត្រូវពិចារណានូវហេតុទាំង ១០ ជាមុន ត្រូវស្គាល់ការបិទបាំងអាបត្តិជាមុន តពីនោះមកត្រូវរាប់ថ្ងៃដែលបិទបាំងព្រមទាំងរាប់ចំនួនអាបត្តិ បើអាបត្តិមួយបិទបាំងមួយថ្ងៃ ត្រូវសូត្រថា អហំ ភន្តេ ឯកំ អាបត្តឹ អាបជ្ជឹ សញ្ចេតនិកំ សុក្កវិស្សដ្ឋឹ ឯកាហប្បដិច្ឆន្នំ "បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំព្រះករុណាត្រូវហើយនូវអាបត្តិមួយ ឈ្មោះសញ្ចេតនិកសុក្កវិស្សដ្ឋិ បិទបាំងមួយថ្ងៃ" ។ ហើយឲ្យបរិវាសដោយសូត្រកម្មវាចាតាមទំនងពាក្យសុំ ។ បើបិទបាំងពីរថ្ងៃ ត្រូវសូត្រដាក់ពាក្យខាងចុងថា ទ្វិហាប្បដិច្ឆន្នំ, បីថ្ងៃថា តិហាប្បដិច្ឆន្នំ, បួនថ្ងៃថា ចតុហាប្បដិច្ឆន្នំ, ប្រាំថ្ងៃថា បញ្ចាហប្បដិច្ឆន្នំ ។ល។ ១៤ ថ្ងៃថា ចុទ្ទសាហប្បដិច្ឆន្នំ, ១៥ ថ្ងៃថា បក្ខប្បដិច្ឆន្នំ, តាំងពី ១៦ ថ្ងៃទៅដល់២៩ថ្ងៃ ត្រូវដាក់ពាក្យខាងចុងថា អតិរេកបក្ខប្បដិច្ឆន្នំ, មួយខែថា មាសប្បដិច្ឆន្នំ, ជាងមួយខែថា អតិរេកមាសប្បដិច្ឆន្នំ, ពីរខែថា ទ្វេមាសប្បដិច្ឆន្នំ, ជាងពីរខែថា អតិរេកទ្វេមាសប្បដិច្ឆន្នំ ។ល។ ជាង១១ខែ

ថា អតិរេកឯកាទសមាសប្បដិច្ឆន្នំ, មួយនាំថា សំវច្ឆរប្បដិច្ឆន្នំ ជាន់មួយនាំថា អតិរេកសំវច្ឆរប្បដិច្ឆន្នំ ។

បើអាបត្តិពីរថា ទ្វេ អាបត្តិយោ, បើអាបត្តិបីថា តិស្សោ អាបត្តិយោ, តាំងអំពីបួនអាបត្តិទៅត្រូវថា សម្ពហុលា ជាដរាប ។ បើអាបត្តិមានវត្ថុផ្សេងគ្នា ត្រូវឲ្យសូត្រសូមថា អហំ ភន្តេ សម្ពហុលា សង្ឃាទិសេសា អាបត្តិយោ អាបជ្ជឹ ឯកំ សុក្កវិស្សដ្ឋឹ ឯកំ កាយសំសគ្គំ ឯកំ ទុដ្ឋុល្លវាចំ ឯកំ អត្តកាមំ ឯកំ សញ្ចរិត្តំ ឯកាហប្បដិច្ឆន្នាយោ "បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំព្រះករុណាត្រូវហើយនូវអាបត្តិសង្ឃាទិសេសជាច្រើន អាបត្តិមួយឈ្មោះ សុក្កវិស្សដ្ឋិ-កាយសំសគ្គ-ទុដ្ឋុល្លវាចា-អត្តកាម, អាបត្តិមួយឈ្មោះ "សញ្ចរិត្ត" ថាដូច្នេះហៅថារាប់ចំនួនវត្ថុឲ្យឃើញថាផ្សេងៗគ្នា ។ អហំ ភន្តេ សម្ពហុលា សង្ឃាទិសេសា អាបត្តិយោ អាបជ្ជឹ នានាវត្ថុកាយោ ឯកាហប្បដិច្ឆន្នាយោ "បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំព្រះករុណាត្រូវអាបត្តិសង្ឃាទិសេសជាច្រើន មានវត្ថុផ្សេងៗគ្នា បិទបាំងមួយថ្ងៃ", ថាដូច្នេះគ្រាន់តែប្រកាសប្រាប់វត្ថុថាផ្សេងៗគ្នាប៉ុណ្ណោះ គ្មានរាយឈ្មោះវត្ថុៗ អហំ ភន្តេ សម្ពហុលា សង្ឃាទិសេសា អាបត្តិយោ អាបជ្ជឹ ឯកាហប្បដិច្ឆន្នាយោ "បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំព្រះ

ករុណាត្រូវហើយនូវអាបត្តិសង្ឃាទិសេសជាច្រើន បិទបាំងមួយថ្ងៃ"; ថា ដូច្នេះគ្រាន់តែបង្អួលប្រាប់នាមនៃអាបត្តិ; នាមនោះមាន ២ យ៉ាងគឺ សជាតិសាធារណនាម ឈ្មោះដែលទូទៅដោយជាតិស្មើគ្នា១ សព្វសាធារណនាម ឈ្មោះដែលទូទៅដល់អាបត្តិទាំងអស់ ១ ៗ ពាក្យថា សង្ឃាទិសេស ជា សជាតិសាធារណនាម, ពាក្យថា អាបត្តិ ជា សព្វសាធារណនាម ព្រោះហេតុនោះវិធីធ្វើបរិវាសកម្ម គ្រាន់តែពោលតាមសព្វសាធារណនាមថា សម្ពហុលា អាបត្តិយោ ហើយ អាបជ្ជឹ ឯកាហប្បដិច្ឆន្នាយោ ដូច្នេះក៏សម្រេចវិនយកម្មហើយ ព្រោះការធ្វើនូវវិនយកម្មមានបរិវាសជាដើមនេះ រមែងសម្រេចដោយអាការ ៤ យ៉ាងគឺ វត្ថុ ១ គោត្រ ១ នាម ១ អាបត្តិ ១ ៗ ពាក្យថា សុក្កវិស្សដ្ឋិ ដូច្នេះ ហៅថា វត្ថុផង គោត្រផង, ពាក្យថា សង្ឃាទិសេស ដូច្នេះ ហៅថា នាមផង អាបត្តិផង ៗ ការពោលថា សុក្កវិស្សដ្ឋិ, កាយសំសគ្គ ដូច្នេះជាដើមក្តី ការពោលថា នានាវត្ថុកាយោ ដូច្នេះក្តី ហៅថា កាន់យកនូវវត្ថុនឹងគោត្រ ៗ ការពោលថា សង្ឃាទិសេសា ដូច្នេះក្តី នានាអាបត្តិយោ ដូច្នេះក្តី ហៅថា កាន់យកនូវនាមនឹងអាបត្តិ, ព្រោះហេតុនោះគួរធ្វើកម្មវាចា បណ្តាអាការទាំង៤នេះដោយអាការណាមួយក៏បាន ៗ តែក្នុងទីនេះ ប៉ងនឹងនិយាយតំពីបរិវាសទាន ប្រើពាក្យតាមសព្វសាធារណនាមផង ប្រើពាក្យ

តាមសម្ពហុលសត្ថុផង ។ បើត្រូវអាបត្តិតែមួយទេ វេលាធ្វើវិនយកម្មពោលថា សម្ពហុលា គឺអាបត្តិច្រើន អាបត្តិនោះក៏ដាច់ ព្រោះច្រើន មកពី មួយ, បើគ្មាន មួយ ទេ ច្រើនក៏គ្មានដែរ ។ បើត្រូវអាបត្តិច្រើន វេលាធ្វើវិនយកម្មពោលថា អាបត្តិមួយ អាបត្តិនោះមិនដាច់ទេ ព្រោះហេតុនោះ ក្នុងអធិការនេះ ត្រូវប្រើសម្ពហុល-សត្ថុជាដរាប ។ វិនយធរដែលឲ្យនូវបដិច្ឆន្នបរិវាស បើអាបត្តិបិទបាំងមួយថ្ងៃ ត្រូវឲ្យសូត្រសូមថា អហម្ភន្តេ សម្ពហុលា អាបត្តិយោ[១] អាបជ្ជឹ ឯកាហប្បដិច្ឆន្នាយោ សោហម្ភន្តេ សង្ឃំ សម្ពហុលានំ អាបត្តីនំ ឯកាហប្បដិច្ឆន្នានំ ឯកាហបរិវាសំ យាចាមិ ។ អហម្ភន្តេ សម្ពហុលា អាបត្តិយោ អាបជ្ជឹ ឯកាហប្បដិច្ឆន្នាយោ ទុតិយម្បិ ភន្តេ សង្ឃំ សម្ពហុលានំ អាបត្តីនំ ឯកាហប្បដិច្ឆន្នានំ ឯកាហបរិវាសំ យាចាមិ ។ អហម្ភន្តេ សម្ពហុលា អាបត្តិយោ អាបជ្ជឹ ឯកាហប្បដិច្ឆន្នាយោ តតិយម្បិ ភន្តេ សង្ឃំ សម្ពហុលានំ អាបត្តីនំ ឯកាហប្បដិច្ឆន្នានំ ឯកាហបរិវាសំ យាចាមិ បពិត្រព្រះសង្ឃដ៏ចំរើន

---

១ មិនបាច់ដាក់ សង្ខ្យាវិសេសា ដាក់តែ អាបត្តិយោ មកដូច្នេះ ហៅថា វិនយកម្មធ្វើតាមសព្វសាធារណនាម ក៏រាប់ថាជាការត្រឹមត្រូវ អាចសម្រេចប្រយោជន៍បានហើយ ។

ខ្ញុំព្រះករុណា ត្រូវហើយនូវអាបត្តិជាច្រើន បិទបាំង១ថ្ងៃ បពិត្រព្រះសង្ឃដ៏ចំរើន (ឥឡូវ) ខ្ញុំព្រះករុណាសូមនូវឯកាហបរិវាសអំពីសង្ឃ ដើម្បីអាបត្តិជាច្រើន បិទបាំង១ថ្ងៃ ។ បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំព្រះករុណាត្រូវហើយនូវអាបត្តិជាច្រើន បិទបាំង១ថ្ងៃ បពិត្រព្រះសង្ឃដ៏ចំរើន (ឥឡូវ) ខ្ញុំព្រះករុណា សូមនូវឯកាហបរិវាសអំពីសង្ឃ ដើម្បីអាបត្តិជាច្រើន បិទបាំង១ថ្ងៃ ជាគំរប់ពីរដងទៀត ។ បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំព្រះករុណាត្រូវហើយនូវអាបត្តិជាច្រើន បិទបាំង១ថ្ងៃ បពិត្រព្រះសង្ឃដ៏ចំរើន (ឥឡូវ) ខ្ញុំព្រះករុណាសូមនូវឯកាហបរិវាសអំពីសង្ឃ ដើម្បីអាបត្តិជាច្រើន បិទបាំង១ថ្ងៃ ជាគំរប់បីដងទៀត" ។

កាលបើសូត្រសូម៣ដងយ៉ាងនេះហើយ ភិក្ខុអ្នកឈ្លាសប្រតិពលត្រូវផ្តៀងសង្ឃថា:

សុណាតុ មេ ភន្តេ សង្ឃោ អយំ (ឥត្ថន្នាមោ)ភិក្ខុ សម្ពហុលា អាបត្តិយោ អាបជ្ជិ ឯកាហប្បដិច្ឆន្នាយោ សោ សង្ឃំ សម្ពហុលានំ អាបត្តីនំ ឯកាហប្បដិច្ឆន្នានំ ឯកាហបរិវាសំ យាចតិ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ (ឥត្ថន្នាមស្ស) ភិក្ខុនោ សម្ពហុលានំ អាបត្តីនំ ឯកាហប្បដិច្ឆន្នានំ ឯកាហបរិវាសំ ទទេយ្យ ឯសា ញត្តិ ។

សុណាតុ មេ ភន្តេ សង្ឃោ អយំ (ឥត្ថន្នាមោ) ភិក្ខុ សម្ពហុលា អាបត្តិយោ អាបជ្ជិ ឯកាហប្បដិច្ឆន្នាយោ សោ សង្ឃំ សម្ពហុលានំ អាបត្តីនំ ឯកាហប្បដិច្ឆន្នានំ ឯកាហបរិវាសំ យាចតិ សង្ឃោ (ឥត្ថន្នាមស្ស) ភិក្ខុនោ សម្ពហុលានំ អាបត្តីនំ ឯកាហប្បដិច្ឆន្នានំ ឯកាហបរិវាសំ ទេតិ យស្សាយស្មតោ ខមតិ (ឥត្ថន្នាមស្ស) ភិក្ខុនោ សម្ពហុលានំ អាបត្តីនំ ឯកាហប្បដិច្ឆន្នានំ ឯកាហបរិវាសស្ស ទានំ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។

ទុតិយម្បិ ឯតមត្ថំ វទាមិ ។ បេ ។

តតិយម្បិ ឯតមត្ថំ វទាមិ ។ បេ ។

ទិន្នោ សង្ឃេន (ឥត្ថន្នាមស្ស) ភិក្ខុនោ សម្ពហុលានំ អាបត្តីនំ ឯកាហប្បដិច្ឆន្នានំ ឯកាហបរិវាសោ ខមតិ សង្ឃស្ស តស្មា តុណ្ហី ឯវមេតំ ធារយាមិ ។

*"បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំ ភិក្ខុ (ឈ្មោះនេះ) នេះ ត្រូវហើយនូវអាបត្តិជាច្រើន បិទបាំង ១ ថ្ងៃ, ភិក្ខុនោះសូមនូវឯកាហបរិវាសអំពីសង្ឃ ដើម្បីអាបត្តិជាច្រើន បិទបាំង ១ ថ្ងៃ, បើ*

បរិវាសទានកម្មមានកាលដ៏សមគួរ ដល់សង្ឃហើយ សង្ឃគប្បីឲ្យនូវឯកាហបរិវាសដល់ភិក្ខុ (ឈ្មោះនេះ) ដើម្បីអាបត្តិជាច្រើន បិទបាំង ១ ថ្ងៃ នេះហៅថា ញត្តិ ។

បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំ ភិក្ខុ (ឈ្មោះនេះ) នេះ ត្រូវហើយនូវអាបត្តិជាច្រើន បិទបាំង ១ ថ្ងៃ, ភិក្ខុនោះសូមនូវឯកាហបរិវាសអំពីសង្ឃ ដើម្បីអាបត្តិជាច្រើន បិទបាំង១ ថ្ងៃ, (ឥឡូវ) សង្ឃឲ្យនូវឯកាហបរិវាសដល់ភិក្ខុ (ឈ្មោះនេះ) ដើម្បីអាបត្តិជាច្រើន បិទបាំង ១ ថ្ងៃ; ការឲ្យនូវឯកាហបរិវាស ដល់ភិក្ខុ (ឈ្មោះនេះ) ដើម្បីអាបត្តិជាច្រើន បិទបាំង ១ ថ្ងៃ គាប់ចិត្តដល់លោកអ្នកមានអាយុអង្គណា លោកអ្នកមានអាយុអង្គនោះ ត្រូវស្ងៀម មិនគាប់ចិត្តដល់លោកអ្នកមានអាយុអង្គណា លោកអ្នកមានអាយុអង្គនោះ ត្រូវនិយាយឡើង ។

ខ្ញុំពោលនូវសេចក្តីនេះជាគំរប់ពីរដងទៀត ។បេ។

ខ្ញុំពោលនូវសេចក្តីនេះជាគំរប់បីដងទៀត ។បេ។

ឯកាហបរិវាស សង្ឃបានឲ្យដល់ភិក្ខុ (ឈ្មោះនេះ) ហើយ ដើម្បីអាបត្តិជាច្រើន បិទបាំង ១ ថ្ងៃ, ការឲ្យនោះគាប់ចិត្តដល់សង្ឃ ព្រោះហេតុនោះបានជាសង្ឃស្ងៀម, ខ្ញុំចាំទុកនូវរឿងនេះដោយអាការស្ងៀមយ៉ាងនេះ" ។

ភិក្ខុណាត្រូវអាបត្តិ ត្រូវយកនាមភិក្ខុនោះសូត្រកម្មវាចា ។ កាលបើចប់កម្មវាចាហើយ ភិក្ខុត្រូវសមាទានវត្ត គង់ពេញប្តូទីសម្រាប់ធ្វើ

សង្ឃកម្មនោះថា បរិវាសំ សមាទិយាមិ វត្តំ សមាទិយាមិ “ខ្ញុំសូមសមាទាននូវបរិវាស សូមសមាទាននូវវត្ត” ថាដូច្នេះ មួយដងក៏បាន ពីរដងក៏បាន បីដងក៏បាន ។ កាលបើសមាទានវត្តរួចហើយ ត្រូវប្រាប់វត្តដល់សង្ឃថា អហម្ភន្តេ សម្ពហុលា អាបត្តិយោ អាបជ្ជឹ ឯកាហប្បដិច្ឆន្នាយោ សោហំ សង្ឃំ សម្ពហុលានំ អាបត្តីនំ ឯកាហប្បដិច្ឆន្នានំ ឯកាហបរិវាសំ យាចឹ តស្ស មេ សង្ឃោ សម្ពហុលានំ អាបត្តីនំ ឯកាហប្បដិច្ឆន្នានំ ឯកាហបរិវាសំ អទាសិ សោហំ បរិវសាមិ វេទិយាមហំ ភន្តេ វេទិយតីតិ មំ សង្ឃោ ធារេតុ “បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំព្រះករុណាត្រូវហើយនូវអាបត្តិជាច្រើន បិទបាំង ១ ថ្ងៃ, ខ្ញុំព្រះករុណានោះបានសូមហើយនូវឯកាហបរិវាសអំពីសង្ឃ ដើម្បីអាបត្តិជាច្រើន បិទបាំង ១ ថ្ងៃ, សង្ឃបានឲ្យហើយនូវឯកាហបរិវាស ដល់ខ្ញុំព្រះករុណានោះ ដើម្បីអាបត្តិជាច្រើន បិទបាំង ១ ថ្ងៃ, (ឥឡូវ) ខ្ញុំព្រះករុណានោះប្រព្រឹត្តបរិវាស, បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំព្រះករុណាសូមប្រាប់វត្ត, សូមព្រះសង្ឃចាំទុកនូវខ្ញុំថា ភិក្ខុនេះបានប្រាប់វត្ត” ។

ការប្រាប់វត្តនេះ បើចាប់យកសេចក្តីនេះបានហើយ នឹងប្រាប់ដោយភាសាណាមួយក៏បាន ។ បើប្រាប់រួចហើយត្រូវការនឹងដាក់វត្តចេញត្រូវដាក់ដូច្នេះ

បរិវាសំ និក្ខិបាមិវត្តំ និក្ខិបាមិ "ខ្ញុំដាក់ចុះនូវបរិវាស ដាក់ចុះនូវវត្ត" ។ ជាដូច្នេះមួយដងក៏បាន ពីរដងក៏បាន បីដងក៏បាន ។ ចាប់ដើមតាំងអំពីដាក់វត្តរួចហើយ ភិក្ខុនោះតាំងនៅជាបកតត្ត ដូចជាភិក្ខុធម្មតា ។ កាលបើភិក្ខុទាំងឡាយនិមន្តចេញអំពីពេលសម្រាប់ធ្វើសង្ឃកម្មអស់ហើយ នឹងដាក់វត្តក្នុងសំណាក់នៃភិក្ខុមួយរូបក៏បាន ។ កាលបើចេញអំពីពេលសម្រាប់ធ្វើសង្ឃកម្មទៅហើយ បើនឹកឃើញថានឹងដាក់វត្ត គប្បីដាក់វត្តក្នុងសំ-ណាក់នៃភិក្ខុដែលដើរទៅជាមួយគ្នា ។ បើភិក្ខុនោះចេញបាត់ទៅហើយ នៅសល់ភិក្ខុណាមួយ ដែលមិនទាន់បានប្រាប់ក្នុងពេលសម្រាប់ធ្វើសង្ឃកម្ម ត្រូវទៅប្រាប់ភិក្ខុនោះកុំខាន ។ បើប្រាប់ភិក្ខុមួយរូប ត្រូវដាក់ពាក្យខាងចុងថា វេទិយតីតិ មំ អាយស្មា ធារេតុ "សូមលោកអ្នកមានអាយុចាំទុកនូវខ្ញុំថា ភិក្ខុនេះបានប្រាប់វត្ត" ។ បើប្រាប់ភិក្ខុពីររូប ត្រូវដាក់ពាក្យខាងចុងថា វេទិយតីតិ មំ អាយស្មន្តា ធារេន្តុ "សូមលោកអ្នកមានអាយុទាំងឡាយចាំទុកនូវខ្ញុំថាភិក្ខុនេះបានប្រាប់វត្ត" ។ បើប្រាប់ភិក្ខុបីរូបថា វេទិយតីតិ មំ អាយស្មន្តោ ធារេន្តុ "សូមលោកអ្នកមានអាយុទាំងឡាយចាំទុកនូវខ្ញុំថាភិក្ខុនេះបានប្រាប់វត្ត" ។ បើអាវាសមានភិក្ខុតិច ភិក្ខុដែលនៅក្នុងអាវាសទាំងប៉ុន្មាន សុទ្ធតែជាសភាគៈត្រូវលទ្ធិគ្នាព្រមព្រៀងគ្នាមិនបាច់ដាក់វត្តក៏បាន គួរនៅប្រព្រឹត្តវត្តតែក្នុងអាវាស រាប់រាត្រីឲ្យបានគ្រប់គ្រាន់ចុះ ។ បើមានភិក្ខុខ្លះជាវិស-

ភាគៈ មិនអាចនឹងជម្រះបរិវាសឲ្យបរិសុទ្ធបានទេ ត្រូវតែដាក់វត្តចេញ ចាំដល់ពេលជិតបច្ចូសសម័យ សឹមចេញអំពីអាវាស ទៅជាមួយនឹងភិក្ខុជាបកតត្ត ១ រូប ចេញទៅឲ្យផុត ២ លេឌ្ឌុបាត[(១)] គិតអំពីរបងអាវាសទៅ, បើអាវាសគ្មានរបងទេ ត្រូវគិតស្មានយកកន្លែងណាដែលគួរនឹងធ្វើរបង គិតអំពីកន្លែងនោះ ចេញឲ្យផុតចំនួន ២ លេឌ្ឌុបាតទៅ គេចចេញអំពីផ្លូវធំ អង្គុយពួនសម្ងំបិទបាំងខ្លួននឹងគុម្ពឈើក្តី របងក្តី សមាទានវត្ត ប្រាប់វត្តខាងក្នុងអរុណ គឺពេលអរុណមិនទាន់រះ ។ ការប្រាប់វត្តនោះ បើភិក្ខុជាបកតត្តនោះខ្ចីជាង ត្រូវពោលថា អាវុសោ ជាប ។ បើកំពុងប្រព្រឹត្តវត្ត មានភិក្ខុណាមួយដទៃដើរមកកាន់ទីនោះដោយកិច្ចអ្វីមួយ បើឃើញភិក្ខុនោះ ឬគ្រាន់តែឮសំឡេង ត្រូវប្រាប់វត្តដល់ភិក្ខុនោះ បើមិនប្រាប់ទេ ជារត្តិច្ឆេទផង ជាវត្តភេទផង; រត្តិច្ឆេទ គឺដាច់រាត្រី ឬខាតរាត្រី រាប់យកជាការពុំបាន ទុកថាជាអសារឥតការ, វត្តភេទ គឺត្រូវអាបត្តិទុក្កដ ព្រោះធ្លាយវត្ត ព្រោះមិនបានប្រាប់វត្ត ។ បើភិក្ខុអ្នកប្រព្រឹត្តបរិវាសមិនបានដឹង ភិក្ខុដទៃដើរចូលមកកាន់ទីឧបចារៈ ចំនួន ១២ ហត្ថ ហើយដើរហួសទៅ យ៉ាងនេះគ្រាន់តែជា រត្តិច្ឆេទ មិនជាវត្តភេទទេ ។ កាលបើអរុណរះឡើងហើយ ត្រូវ

---

១ មជ្ឈិមបុរសឈរត្រង់របងវត្ត កាន់ដុំដីចោលចេញទៅ ដុំដីធ្លាក់ត្រង់ណាត្រង់នោះ ហៅថា មួយលេឌ្ឌុបាត ចោលពីរដង ហៅថា ពីរលេឌ្ឌុបាត ចេញឲ្យហួស ២ លេឌ្ឌុបាត អំពីរបងវត្តទៅ ។

ដាក់វត្តចេញ ។ បើភិក្ខុជាបកតត្តនោះមានកិច្ចចេញទៅហើយ បារិវា-
សិកភិក្ខុនោះឃើញភិក្ខុណាដទៃមុនគេបង្អស់ ត្រូវប្រាប់វត្ត ដល់ភិក្ខុនោះ
ហើយដាក់វត្តចេញ ឬដើរចូលទៅកាន់អាវាស ឃើញភិក្ខុណាមុនគេ
ត្រូវប្រាប់វត្តដល់ភិក្ខុនោះ ហើយដាក់វត្តចេញៗ នេះជាបរិហារនៃ និក្ខិត្ត-
វត្តភិក្ខុ គឺភិក្ខុអ្នកប្រព្រឹត្តបរិវាសដាក់វត្តចេញ ។ បារិវាសិកភិក្ខុនោះ
បិទបាំងអាបត្តិប៉ុន្មានថ្ងៃ ត្រូវប្រព្រឹត្តបរិវាសប៉ុណ្ណោះថ្ងៃដែរ ឬលើសនោះ
ទៅទៀតក៏ជាការល្អ ដើម្បីបន្ទោបង់សេចក្ដីសង្ស័យ, កាលបើឃើញ
ថាគ្រប់គ្រាន់ល្មមហើយ ត្រូវចូលទៅរកសង្ឃ សមាទានវត្តហើយសូម
មានត្ត អំពីសង្ឃ ។ ភិក្ខុនេះ កាលបើបានសមាទានវត្តរួចហើយ ទើប
បានឈ្មោះថា មានត្តារហភិក្ខុ គឺជាភិក្ខុគួរដល់មានត្ត ព្រោះ
ខ្លួនជា និក្ខិត្តវត្ត បានប្រព្រឹត្តបរិវាសគ្រប់គ្រាន់ហើយ ។ ចំណែក
អនិក្ខិត្តវត្តភិក្ខុ គឺភិក្ខុអ្នកប្រព្រឹត្តបរិវាស មិនដាក់វត្តចេញ គ្មាន
វិធីសមាទានវត្តញឹកញយឡើយ ព្រោះភិក្ខុនោះ កាលបើបាន
ប្រព្រឹត្តបរិវាសគ្រប់ថ្ងៃដែលបិទបាំងហើយ បានឈ្មោះថា មានត្តារ-
ហភិក្ខុ តែម្ដង សង្ឃត្រូវឲ្យ មានត្ត ដល់ភិក្ខុនោះតែម្ដង ។
កាលដែលឲ្យមានត្តនោះ ត្រូវឲ្យសូត្រសូមដូច្នេះ អហម្ភន្តេ សម្ព-
ហុលា អាបត្តិយោ អាបជ្ជឹ ឯកាហប្បដិច្ឆន្នាយោ សោ-
ហំ សង្ឃំ សម្ពហុលានំ អាបត្តីនំ ឯកាហប្បដិច្ឆន្នានំ

ឯកាហបរិវាសំ យាចិ តស្ស មេ សង្ឃោ សម្ពហុ-
លានំ អាបត្តីនំ ឯកាហប្បដិច្ឆន្នានំ ឯកាហបរិវាសំ
អទាសិ សោហំ ភន្តេ បរិវុត្ថបរិវាសោ សង្ឃំ សម្ព-
ហុលានំ អាបត្តីនំ ឯកាហប្បដិច្ឆន្នានំ ឆារត្តំ មានត្តំ
យាចាមិ ។ អហម្ភន្តេ ។ បេ ។ សោហំ ភន្តេ
បរិវុត្ថបរិវាសោ ទុតិយម្បិ ភន្តេ សង្ឃំ សម្ពហុ-
លានំ អាបត្តីនំ ឯកាហប្បដិច្ឆន្នានំ ឆារត្តំ មានត្តំ
យាចាមិ ។ អហម្ភន្តេ ។ បេ ។ សោហំ ភន្តេ បរិវុត្ថ-
បរិវាសោ តតិយម្បិ ភន្តេ សង្ឃំ សម្ពហុលានំ អាប-
ត្តីនំ ឯកាហប្បដិច្ឆន្នានំ ឆារត្តំ មានត្តំ យាចាមិ ។

*“បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំព្រះករុណា ត្រូវហើយនូវអាបត្តិជាច្រើន បិទ
បាំងមួយថ្ងៃ, ខ្ញុំព្រះករុណានោះ បានសូមហើយនូវឯកាហបរិវាសអំពី
សង្ឃ ដើម្បីអាបត្តិជាច្រើន បិទបាំង១ថ្ងៃ, សង្ឃបានឲ្យហើយនូវឯកាហ-
បរិវាសដល់ខ្ញុំព្រះករុណានោះ ដើម្បីអាបត្តិជាច្រើន បិទបាំង១ថ្ងៃ, បពិត្រ
ព្រះសង្ឃដ៏ចំរើន ខ្ញុំព្រះករុណានោះ បានប្រព្រឹត្តបរិវាសគ្រប់គ្រាន់
ហើយ, (ឥឡូវ) សូមនូវមានត្ត ៦ រាត្រីអំពីសង្ឃ ដើម្បីអាបត្តិជាច្រើន
បិទបាំង១ថ្ងៃ ។ បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំព្រះករុណា ។ បេ ។
បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំព្រះករុណានោះ បានប្រព្រឹត្តបរិវាសគ្រប់*

គ្រាន់ហើយ, បពិត្រព្រះសង្ឃដ៏ចំរើន (ឥឡូវ) ខ្ញុំព្រះករុណាសូមនូវមានត្ត ៦ រាត្រី អំពីសង្ឃ ដើម្បីអាបត្តិជាច្រើន បិទបាំង១ថ្ងៃ ជាគំរប់ពីរដងទៀត ។ បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំព្រះករុណា ។ បេ ។ បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំព្រះករុណានោះ បានប្រព្រឹត្តបរិវាសគ្រប់គ្រាន់ហើយ បពិត្រព្រះសង្ឃដ៏ចំរើន (ឥឡូវ) ខ្ញុំព្រះករុណាសូមនូវមានត្ត ៦ រាត្រី អំពីសង្ឃ ដើម្បីអាបត្តិជាច្រើន បិទបាំង ១ ថ្ងៃ ជាគំរប់បីដងទៀត” ។ កាលបើសូត្រសូមបីដងដូច្នេះហើយ ភិក្ខុអ្នកឈ្លាសប្រតិពល ត្រូវផ្ដៀងសង្ឃថា:

សុណាតុ មេ ភន្តេ សង្ឃោ អយំ (ឥត្ថន្នាមោ) ភិក្ខុ សម្ពហុលា អាបត្តិយោ អាបជ្ជិ ឯកាហប្បដិច្ឆន្នាយោ សោ សង្ឃំ សម្ពហុលានំ អាបត្តីនំ ឯកាហប្បដិច្ឆន្នានំ ឯកាហបរិវាសំ យាចិ សង្ឃោ (ឥត្ថន្នាមស្ស) ភិក្ខុនោ សម្ពហុលានំ អាបត្តីនំ ឯកាហប្បដិច្ឆន្នានំ ឯកាហបរិវាសំ អទាសិ សោ បរិវុត្ថបរិវាសោ សង្ឃំ សម្ពហុលានំ អាបត្តីនំ ឯកាហប្បដិច្ឆន្នានំ ឆារត្តំ មានត្តំ យាចតិ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ (ឥត្ថន្នាមស្ស) ភិក្ខុនោ សម្ពហុលានំ អាបត្តីនំ ឯកាហប្បដិច្ឆន្នានំ ឆារត្តំ មានត្តំ ទទេយ្យ ឯសា ញត្តិ ។

"បារិវាសិក គឺភិក្ខុជាអ្នកប្រព្រឹត្តនូវបរិវាស បិទបាំងអាបត្តិមួយរយដប់ដង គឺ ១ ០០០ អាបត្តិ ចំនួន ១០០ រាត្រី នៅបរិវាសត្រឹមតែ ១០ រាត្រីក៏អាចរួចចាកអាបត្តិបាន" ។ នេះហៅថា អគ្ឃសមោធាន ដែរ ។

ឯលក្ខណៈនៃការសូត្រសូម នឹងការឲ្យនូវអគ្ឃសមោធាននោះដូច្នេះ ប្រសិនបើភិក្ខុណាមួយត្រូវអាបត្តិហើយ អាបត្តិខ្លះ បិទបាំង ១ ថ្ងៃ, ខ្លះ ២ ថ្ងៃ, ខ្លះ ៣ ថ្ងៃ, ខ្លះ ៤ ថ្ងៃ, ខ្លះ ៥ ថ្ងៃ, ខ្លះ ៦ ថ្ងៃ, ខ្លះ ៧ ថ្ងៃ, ខ្លះ ៨ ថ្ងៃ, ខ្លះ ៩ ថ្ងៃ, អាបត្តិខ្លះ បិទបាំង ១០ ថ្ងៃ ភិក្ខុនោះត្រូវចូលទៅរកសង្ឃ ដណ្ដប់ទុក្ខពសន្តៈឆៀងស្មាម្ខាង ថ្វាយបង្គំបាទានៃភិក្ខុចាស់ ។

អង្គុយប្រហោងផ្គងអញ្ជលីឡើង សូត្រសូមសមោធានបរិវាសថា៖ អហម្ភន្តេ សម្ពហុលា អាបត្តិយោ អាបជ្ជឹ ឯកច្ចា អាបត្តិយោ ឯកាហប្បដិច្ឆន្នាយោ ឯកច្ចា ទ្វិហប្បដិច្ឆន្នាយោ ឯកច្ចា តិហប្បដិច្ឆន្នាយោ ឯកច្ចា ចតុហប្បដិច្ឆន្នាយោ ឯកច្ចា បញ្ចាហប្បដិច្ឆន្នាយោ ឯកច្ចា ឆាហប្បដិច្ឆន្នាយោ ឯកច្ចា សត្តាហប្បដិច្ឆន្នាយោ ឯកច្ចា អដ្ឋាហប្បដិច្ឆន្នាយោ ឯកច្ចា នវាហប្បដិច្ឆន្នាយោ ឯកច្ចា ទសាហប្បដិច្ឆន្នាយោ សោហម្ភន្តេ សង្ឃំ តាសំ អាបត្តីនំ យា អាបត្តិយោ ទសាហប្បដិច្ឆន្នាយោ តាសំ អគ្គេន សមោធានបរិវាសំ យាចាមិ "បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំព្រះករុណាបានត្រូវហើយនូវអាបត្តិជាច្រើន អាបត្តិខ្លះបិទបាំង ១ ថ្ងៃ ខ្លះបិទបាំង ២ ថ្ងៃ ខ្លះបិទបាំង ៣ ថ្ងៃ ខ្លះបិទបាំង ៤ ថ្ងៃ ខ្លះបិទបាំង ៥ ថ្ងៃ ខ្លះបិទបាំង ៦ ថ្ងៃ ខ្លះបិទបាំង ៧ ថ្ងៃ ខ្លះបិទបាំង ៨ ថ្ងៃ ខ្លះបិទបាំង ៩ ថ្ងៃ អាបត្តិខ្លះបិទបាំង ១០ ថ្ងៃ, បពិត្រព្រះសង្ឃដ៏ចំរើន បណ្ដាអាបត្តិទាំងឡាយនោះ អាបត្តិទាំងឡាយណាដែលបិទបាំង ១០ ថ្ងៃ ខ្ញុំព្រះករុណានោះ សូមនូវសមោធានបរិវាសអំពីសង្ឃ តាមតម្លៃនៃអាបត្តិទាំងឡាយនោះ" (សូត្រ ៣ ដង) ។

ភិក្ខុអ្នកឈ្លាស ប្រតិពល ត្រូវផ្តៀងសង្ឃថា៖

សុណាតុ មេ ភន្តេ សង្ឃោ អយ (ឥត្ថន្នាមោ) ភិក្ខុ សម្ពហុលា អាបត្តិយោ អាបជ្ជិ ឯកច្ចា អាបត្តិយោ ឯកាហបដិច្ឆន្នាយោ ឯកច្ចា ទ្វីហបដិច្ឆន្នាយោ ឯកច្ចា តីហបដិច្ឆន្នាយោ ឯកច្ចា ចតូហបដិច្ឆន្នាយោ ឯកច្ចា បញ្ចាហបដិច្ឆន្នាយោ ឯកច្ចា ឆាហបដិច្ឆន្នាយោ ឯកច្ចា សត្តាហបដិច្ឆន្នាយោ ឯកច្ចា អដ្ឋាហបដិច្ឆន្នាយោ ឯកច្ចា នវាហបដិច្ឆន្នាយោ ឯកច្ចា ទសាហបដិច្ឆន្នាយោ សោ សង្ឃំ តាសំ អាបត្តីនំ យា អាបត្តិយោ ទសាហបដិច្ឆន្នាយោ តាសំ អគ្គេន សមោធានបរិវាសំ យាចតិ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ (ឥត្ថន្នាមស្ស) ភិក្ខុនោ តាសំ អាបត្តីនំ យា អាបត្តិយោ ទសាហបដិច្ឆន្នាយោ តាសំ អគ្គេន សមោធានបរិវាសំ ទទេយ្យ ឯសា ញត្តិ ។

សុណាតុ មេ ភន្តេ សង្ឃោ អយំ (ឥត្ថន្នាមោ) ភិក្ខុ សម្ពហុលា អាបត្តិយោ អាបជ្ជិ ឯកច្ចា អាបត្តិយោ ឯកាហបដិច្ឆន្នាយោ ។បេ។ ឯកច្ចា ទសាហបដិច្ឆន្នាយោ សោ សង្ឃំ តាសំ អាបត្តីនំ យា អាបត្តិយោ ទសាហបដិច្ឆន្នាយោ តាសំ អគ្គេន សមោធានបរិវាសំ

យាចតិ សង្ឃោ (ឥត្ថន្នាមស្ស) ភិក្ខុនោ តាសំ អាបត្តីនំ យា អាបត្តិយោ ទសាហប្បដិច្ឆន្នាយោ តាសំ អគ្ឃេន សមោធានបរិវាសំ ទេតិ យស្សាយស្មតោ ខមតិ (ឥត្ថន្នាមស្ស) ភិក្ខុនោ តាសំ អាបត្តីនំ យា អាបត្តិយោ ទសាហប្បដិច្ឆន្នាយោ តាសំ អគ្ឃេន-សមោធានបរិវាសស្ស ទានំ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។

ទុតិយម្បិ ឯតមត្ថំ វទាមិ ។បេ។

តតិយម្បិ ឯតមត្ថំ វទាមិ ។បេ។

ទិន្នោ សង្ឃេន (ឥត្ថន្នាមស្ស) ភិក្ខុនោ តាសំ អាបត្តីនំ យា អាបត្តិយោ ទសាហប្បដិច្ឆន្នាយោ តាសំ អគ្ឃេន សមោធានបរិវាសោ ខមតិ សង្ឃស្ស តស្មា តុណ្ហី ឯវមេតំ ធារយាមិ ។

“បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំ, ភិក្ខុ (ឈ្មោះនេះ) នេះ ត្រូវហើយនូវអាបត្តិជាច្រើន អាបត្តិខ្លះបិទបាំង១ថ្ងៃ ខ្លះបិទបាំង២ថ្ងៃ ខ្លះបិទបាំង៣ថ្ងៃ ខ្លះបិទបាំង៤ថ្ងៃ ខ្លះបិទបាំង៥ថ្ងៃ ខ្លះបិទបាំង៦ថ្ងៃ ខ្លះបិទបាំង៧ថ្ងៃ ខ្លះបិទបាំង៨ថ្ងៃ ខ្លះបិទបាំង៩ថ្ងៃ ខ្លះបិទបាំង១០ថ្ងៃ; បណ្តាអាបត្តិទាំងឡាយនោះ អាបត្តិទាំងឡាយណា ដែល

បិទបាំង១០ថ្ងៃ ភិក្ខុនោះសូមសមោធានបរិវាសអំពីសង្ឃតាមតម្លៃនៃអាបត្តិទាំងឡាយនោះ ។ បើបរិវាសតានកម្ម មានកាលដ៏សមគួរដល់សង្ឃហើយ បណ្តាអាបត្តិទាំងឡាយនោះ អាបត្តិទាំងឡាយណាដែលបិទបាំង ១០ ថ្ងៃ សង្ឃគប្បីឲ្យនូវសមោធានបរិវាស ដល់ភិក្ខុ (ឈ្មោះនេះ) តាមតម្លៃនៃអាបត្តិទាំងឡាយនោះ, នេះហៅថា ញត្តិ ។

បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំ, ភិក្ខុ (ឈ្មោះនេះ) នេះ ត្រូវហើយនូវអាបត្តិជាច្រើន អាបត្តិខ្លះបិទបាំង១ថ្ងៃ ។ល។ ខ្លះបិទបាំង ១០ ថ្ងៃ, បណ្តាអាបត្តិទាំងឡាយនោះ អាបត្តិទាំងឡាយណា ដែលបិទបាំង ១០ ថ្ងៃ ភិក្ខុនោះសូមនូវសមោធានបរិវាសអំពីសង្ឃ តាមតម្លៃនៃអាបត្តិទាំងឡាយនោះ; បណ្តាអាបត្តិទាំងឡាយនោះ អាបត្តិទាំងឡាយណា ដែលបិទបាំង១០ ថ្ងៃ (ឥឡូវ) សង្ឃឲ្យនូវសមោធានបរិវាស ដល់ភិក្ខុ (ឈ្មោះនេះ) តាមតម្លៃនៃអាបត្តិទាំងឡាយនោះ; បណ្តាអាបត្តិទាំងឡាយនោះ អាបត្តិទាំងឡាយណា ដែលបិទបាំង១០ ថ្ងៃ ការឲ្យនូវសមោធានបរិវាស ដល់ភិក្ខុ (ឈ្មោះនេះ) តាមតម្លៃនៃអាបត្តិទាំងឡាយនោះ គាប់ចិត្តដល់លោកអ្នកមានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ ត្រូវស្ងៀម មិនគាប់ចិត្តដល់លោកដ៏មានអាយុអង្គណា លោកអ្នកមានអាយុអង្គនោះត្រូវនិយាយឡើង ។

ខ្ញុំពោលនូវសេចក្តីនេះ ជាគំរប់ពីរដងទៀត ។ បេ ។

ខ្ញុំពោលនូវសេចក្តីនេះ ជាគំរប់បីដងទៀត ។ បេ ។

បណ្តាអាបត្តិទាំងឡាយនោះ អាបត្តិទាំងឡាយណាដែលបិទបាំង១០ថ្ងៃ សមោធានបរិវាស សង្ឃបានឲ្យហើយ ដល់ភិក្ខុ (ឈ្មោះនេះ) តាមតម្លៃនៃអាបត្តិទាំងឡាយនោះ, ការឲ្យនោះគាប់ចិត្តដល់សង្ឃ ព្រោះហេតុនោះបានជាសង្ឃស្ងៀម, ខ្ញុំចាំទុកនូវរឿងនេះ ដោយអាការស្ងៀមយ៉ាងនេះ"។

កាលបើចប់កម្មវាចាហើយ ភិក្ខុទាំងពួងមានសមាទានវត្តជាដើម មានចំនួនបែបបទដូចបាននិយាយខាងដើមរួចហើយ ។ ភិក្ខុនោះ លុះសមាទានរួចហើយ ត្រូវប្រាប់វត្តដូច្នេះ អហម្ភន្តេ សម្ពហុលា អាបត្តិយោ អាបជ្ជឹ ឯកច្ចា អាបត្តិយោ ឯកាហប្បដិច្ឆន្នាយោ ។បេ។ ឯកច្ចា ទសាហប្បដិច្ឆន្នាយោ សោហំ សង្ឃំ តាសំ អាបត្តីនំ យា អាបត្តិយោ ទសាហប្បដិច្ឆន្នាយោ តាសំ អគ្គេន សមោធានបរិវាសំ យាចឹ តស្ស មេ សង្ឃោ តាសំ អាបត្តីនំ យា អាបត្តិយោ ទសាហប្បដិច្ឆន្នាយោ តាសំ អគ្គេន សមោធានបរិវាសំ អទាសិ សោហំ បរិវសាមិ វេទិយាមហំ ភន្តេ វេទិយតីតិ មំ សង្ឃោ ធារេតុ "បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំព្រះករុណាបានត្រូវហើយនូវអាបត្តិជាច្រើន អាបត្តិខ្លះបិទបាំង១ថ្ងៃ ។បេ។ ខ្លះបិទបាំង១០ថ្ងៃ,

បណ្ដាអាបត្តិទាំងឡាយនោះ អាបត្តិទាំងឡាយណា ដែលបិទបាំង១០ថ្ងៃ ខ្ញុំព្រះករុណានោះបានសូមហើយនូវសមោធានបរិវាសអំពីសង្ឃ តាមតម្លៃអាបត្តិទាំងឡាយនោះ; បណ្ដាអាបត្តិទាំងឡាយនោះ អាបត្តិទាំងឡាយណា ដែលបិទបាំង១០ថ្ងៃ សង្ឃបានឲ្យហើយនូវសមោធានបរិវាស ដល់ខ្ញុំព្រះករុណានោះ តាមតម្លៃនៃអាបត្តិទាំងឡាយនោះ (ឥឡូវ)ខ្ញុំព្រះករុណានោះប្រព្រឹត្តបរិវាស, បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំព្រះករុណាសូមប្រាប់វត្ត សូមព្រះសង្ឃចាំទុកនូវខ្ញុំព្រះករុណាថា ភិក្ខុនេះបានប្រាប់វត្ត” ។

លុះភិក្ខុនោះបានប្រព្រឹត្តបរិវាសគ្រប់គ្រាន់ហើយ សង្ឃត្រូវឲ្យមានត្តដល់ភិក្ខុនោះ ត្រូវឲ្យភិក្ខុនោះសូត្រសូមមានត្តដូច្នេះ អហម្ភន្តេ សម្ពហុលា អាបត្តិយោ អាបជ្ជឹ ឯកច្ចា អាបត្តិយោ ឯកាហប្បដិច្ឆន្នាយោ ។បេ។ ឯកច្ចា ទសាហប្បដិច្ឆន្នាយោ សោហំ សង្ឃំ តាសំ អាបត្តីនំ យា អាបត្តិយោ ទសាហប្បដិច្ឆន្នាយោ តាសំ អគ្ឃេន សមោធានបរិវាសំ យាចឹ តស្ស មេ សង្ឃោ តាសំ អាបត្តីនំ យា អាបត្តិយោ ទសាហប្បដិច្ឆន្នាយោ តាសំ អគ្ឃេន សមោធានបរិវាសំ អទាសិ សោហម្ភន្តេ បរិវុត្ថបរិវាសោ សង្ឃំ តាសំ អាបត្តីនំ មានត្តំ យាចាមិ “បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំព្រះករុណាបានត្រូវហើយនូវអាបត្តិជាច្រើន អាបត្តិខ្លះបិទបាំង១ថ្ងៃ

។បេ។ ខ្លះបិទបាំង១០ថ្ងៃ បណ្ដាអាបត្តិទាំងឡាយនោះ អាបត្តិទាំងឡាយណា ដែលបិទបាំង ១០ ថ្ងៃ ខ្ញុំព្រះករុណានោះបានសូមហើយនូវសមោធានបរិវាសអំពីសង្ឃ តាមតម្លៃនៃអាបត្តិទាំងឡាយនោះ, បណ្ដាអាបត្តិទាំងឡាយនោះ អាបត្តិទាំងឡាយណាដែលបិទបាំង១០ថ្ងៃ សង្ឃបានឲ្យហើយនូវសមោធានបរិវាស ដល់ខ្ញុំព្រះករុណានោះ តាមតម្លៃនៃអាបត្តិទាំងឡាយនោះ, បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំព្រះករុណានោះបានប្រព្រឹត្តបរិវាសគ្រប់គ្រាន់ហើយ (ឥឡូវ) សូមនូវមានត្ត ៦ រាត្រី អំពីសង្ឃ ដើម្បីអាបត្តិទាំងឡាយនោះ" (សូត្រ ៣ ដង) ។

ភិក្ខុអ្នកឈ្លាស ប្រតិពល ត្រូវផ្ទៀងសង្ឃថា:

សុណាតុ មេ ភន្តេ សង្ឃោ អហំ (ឥត្ថន្នាមោ) ភិក្ខុ សម្ពហុលា អាបត្តិយោ អាបជ្ជិំ ឯកច្ចា អាបត្តិយោ ឯកាហប្បដិច្ឆន្នាយោ ។បេ។ ឯកច្ចា ទសាហប្បដិច្ឆន្នាយោ សោ សង្ឃំ តាសំ អាបត្តីនំ យា អាបត្តិយោ ទសាហប្បដិច្ឆន្នាយោ តាសំ អគ្ឃេន សមោធានបរិវាសំ យាចិ សង្ឃោ (ឥត្ថន្នាមស្ស) ភិក្ខុនោ តាសំ អាបត្តីនំ យា អាបត្តិយោ ទសាហប្បដិច្ឆន្នាយោ តាសំ អគ្ឃេន សមោធានបរិវាសំ អទាសិ សោ បរិវុត្ថបរិវាសោ សង្ឃំ តាសំ អាបត្តីនំ ឆារត្តំ មានត្តំ យាចតិ យទិ

សង្ឃស្ស បត្តកល្លំ សង្ឃោ (ឥត្ថន្នាមស្ស) ភិក្ខុនោ តាសំ អាបត្តីនំ ឆារត្តំ មានត្តំ ទទេយ្យ ឯសា ញត្តិ ។

សុណាតុ មេ ភន្តេ សង្ឃោ អយំ (ឥត្ថន្នាមោ) ភិក្ខុ សម្ពហុលា អាបត្តិយោ អាបជ្ជិ ឯកច្ចា អាបត្តិយោ ឯកាហប្បដិច្ឆន្នាយោ ។បេ។ ឯកច្ចា ទសាហប្បដិច្ឆន្នាយោ សោ សង្ឃំ តាសំ អាបត្តីនំ យា អាបត្តិយោ ទសាហប្បដិច្ឆន្នាយោ តាសំ អគ្ឃេន សមោធានបរិវាសំ យាចិ សង្ឃោ (ឥត្ថន្នាមស្ស) ភិក្ខុនោ តាសំ អាបត្តីនំ យា អាបត្តិយោ ទសាហប្បដិច្ឆន្នាយោ តាសំ អគ្ឃេន សមោធានបរិវាសំ អទាសិ សោ បរិវុត្ថបរិវាសោ សង្ឃំ តាសំ អាបត្តីនំ ឆារត្តំ មានត្តំ យាចិ សង្ឃោ (ឥត្ថន្នាមស្ស) ភិក្ខុនោ តាសំ អាបត្តីនំ ឆារត្តំ មានត្តំ ទេតិ យស្សាយស្មតោ ខមតិ (ឥត្ថន្នាមស្ស) ភិក្ខុនោ តាសំ អាបត្តីនំ ឆារត្តំ មានត្តស្ស ទានំ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។

ទុតិយម្បិ ឯតមត្ថំ វទាមិ ។ បេ ។

តតិយម្បិ ឯតមត្ថំ វទាមិ ។ បេ ។

ទិន្នំ សង្ឃេន (ឥត្ថន្នាមស្ស) ភិក្ខុនោ តាសំ អាបត្តីនំ

ឆារត្តំ មានត្តំ ខមតិ សង្ឃស្ស តស្មា តុណ្ហី ឯវមេតំ ធារយាមិ “បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំ, ភិក្ខុ (ឈ្មោះនេះ) នេះ ត្រូវហើយនូវអាបត្តិជាច្រើន អាបត្តិខ្លះបិទបាំង១ថ្ងៃ ៗ បេ ៗ ខ្លះបិទបាំង១០ថ្ងៃ; បណ្តាអាបត្តិទាំងឡាយនោះ អាបត្តិទាំងឡាយណា ដែលបិទបាំង ១០ ថ្ងៃ ភិក្ខុនោះបានសូមហើយនូវសមោធានបរិវាសអំពីសង្ឃ តាមតម្លៃនៃអាបត្តិទាំងឡាយនោះ; បណ្តាអាបត្តិទាំងឡាយនោះ អាបត្តិទាំងឡាយណា ដែលបិទបាំង១០ថ្ងៃ សង្ឃបានឲ្យហើយនូវសមោធានបរិវាសដល់ភិក្ខុ (ឈ្មោះនេះ) តាមតម្លៃនៃអាបត្តិទាំងឡាយនោះ ភិក្ខុនោះ បានប្រព្រឹត្តបរិវាសគ្រប់គ្រាន់ហើយ សូមនូវមានត្ត ៦ រាត្រីអំពីសង្ឃ ដើម្បីអាបត្តិទាំងឡាយនោះ; បើមានត្តទានកម្ម មានកាលដ៏សមគួរដល់សង្ឃហើយ សង្ឃគប្បីឲ្យនូវមានត្ត ៦ រាត្រីដល់ភិក្ខុ (ឈ្មោះនេះ) ដើម្បីអាបត្តិទាំងឡាយនោះ; នេះហៅថា ញត្តិ ៗ

បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំ, ភិក្ខុ (ឈ្មោះនេះ) នេះ ត្រូវហើយនូវអាបត្តិជាច្រើន អាបត្តិខ្លះបិទបាំង ១ ថ្ងៃ ៗបេៗ ខ្លះបិទបាំង ១០ថ្ងៃ; បណ្តាអាបត្តិទាំងឡាយនោះ អាបត្តិទាំងឡាយណា ដែលបិទបាំង ១០ថ្ងៃ ; ភិក្ខុនោះបានសូមហើយនូវសមោធានបរិវាសអំពីសង្ឃ តាមតម្លៃនៃអាបត្តិទាំងឡាយនោះ; បណ្តាអាបត្តិទាំងឡាយនោះ; អាបត្តិទាំងឡាយ

ណា ដែលបិទបាំង១០ថ្ងៃ សង្ឃបានឲ្យហើយនូវសមោធានបរិវាស ដល់ភិក្ខុ (ឈ្មោះនេះ) តាមតម្លៃនៃអាបត្តិទាំងឡាយនោះ ភិក្ខុនោះបាន ប្រព្រឹត្តបរិវាសគ្រប់គ្រាន់ហើយ សូមនូវមានត្ត ៦ រាត្រីអំពីសង្ឃ ដើម្បីអា-បត្តិទាំងឡាយនោះ(ឥឡូវ) សង្ឃឲ្យនូវមានត្ត ៦ រាត្រីដល់ភិក្ខុ (ឈ្មោះនេះ) ដើម្បីអាបត្តិទាំងឡាយនោះ, ការឲ្យនូវមានត្ត៦រាត្រីដល់ភិក្ខុ (ឈ្មោះនេះ) ដើម្បីអាបត្តិទាំងឡាយនោះ គាប់ចិត្តដល់លោកអ្នកមានអាយុអង្គណា លោកអ្នកមានអាយុអង្គនោះត្រូវស្ងៀម មិនគាប់ចិត្តដល់លោកអ្នកមាន អាយុអង្គណា លោកអ្នកមានអាយុអង្គនោះត្រូវនិយាយឡើង ។

ខ្ញុំពោលនូវសេចក្តីនេះ ជាគំរប់ពីរដងទៀត ។បេ។

ខ្ញុំពោលនូវសេចក្តីនេះ ជាគំរប់បីដងទៀត ។បេ។

មានត្ត ៦ រាត្រី សង្ឃបានឲ្យហើយដល់ភិក្ខុ (ឈ្មោះនេះ) ដើម្បីអាបត្តិទាំងឡាយនោះ, ការឲ្យនោះគាប់ចិត្តដល់សង្ឃ ព្រោះហេតុនោះ បានជាសង្ឃស្ងៀម, ខ្ញុំចាំទុកនូវរឿងនេះ ដោយអាការស្ងៀមយ៉ាងនេះ” ។

កាលបើចប់កម្មវាចាហើយ កិច្ចទាំងពួងមានសមាទានវត្តជាដើម មានទំនងបែបបទដូចបាននិយាយខាងដើមរួចហើយ ។ លុះសមាទានវត្តរួចហើយ ត្រូវប្រាប់វត្តដូច្នេះ អហម្ភន្តេ សម្ពហុលា អាបត្តិយោ អាបជ្ជឹ ឯកច្ចា អាបត្តិយោ ឯកាហប្បដិច្ឆន្នាយោ ។បេ។ ឯកច្ចា ទសាហប្បដិច្ឆន្នាយោ សោហំ សង្ឃំ

តាសំ អាបត្តីនំ យា អាបត្តិយោ ទសាហប្បដិច្ឆន្នាយោ តាសំ អគ្ឃេន សមោធានបរិវាសំ យាចិំ តស្ស មេ សង្ឃោ តាសំ អាបត្តីនំ យា អាបត្តិយោ ទសាហប្បដិច្ឆន្នាយោ តាសំ អគ្ឃេន សមោធានបរិវាសំ អទាសិ សោហំ បរិវុត្ថបរិវាសោ សង្ឃំ តាសំ អាបត្តីនំ ឆារត្តំ មានត្តំ យាចិំ តស្ស មេ សង្ឃោ តាសំ អាបត្តីនំ ឆារត្តំ មានត្តំ អទាសិ សោហំ មានត្តំ ចរាមិ វេទិយាមហំ ភន្តេ វេទិយតីតិ មំ សង្ឃោ ធារេតុ "បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំព្រះករុណាត្រូវហើយនូវអាបត្តិជាច្រើន អាបត្តិខ្លះបិទបាំង ១ ថ្ងៃ ។ល។ ខ្លះបិទបាំង១០ថ្ងៃ បណ្ដាអាបត្តិទាំងឡាយនោះ អាបត្តិទាំងឡាយណា ដែលបិទបាំង១០ថ្ងៃ ខ្ញុំព្រះករុណានោះបានសូមហើយនូវសមោធានបរិវាសអំពីសង្ឃ តាមតម្លៃនៃអាបត្តិទាំងឡាយនោះ, បណ្ដាអាបត្តិទាំងឡាយនោះ អាបត្តិទាំងឡាយណា ដែលបិទបាំង១០ថ្ងៃ សង្ឃបានឲ្យហើយនូវសមោធានបរិវាស ដល់ខ្ញុំព្រះករុណានោះ តាមតម្លៃនៃអាបត្តិទាំងឡាយនោះ ខ្ញុំព្រះករុណានោះបានប្រព្រឹត្តបរិវាសគ្រប់គ្រាន់ហើយ បានសូមហើយ នូវមានត្ត៦រាត្រីអំពីសង្ឃ ដើម្បីអាបត្តិទាំងឡាយនោះ សង្ឃបានឲ្យហើយនូវមានត្ត ៦ រាត្រី ដល់ខ្ញុំព្រះករុណានោះ ដើម្បីអាបត្តិទាំងឡាយនោះ, (ឥឡូវ) ខ្ញុំព្រះករុណានោះប្រព្រឹត្តមានត្ត, បពិត្រព្រះសង្ឃដ៏ចំរើន

ខ្ញុំព្រះករុណាសូមប្រាប់វត្ត សូមព្រះសង្ឃចាំទុកនូវខ្ញុំព្រះករុណាថាភិក្ខុនេះ បានប្រាប់វត្ត" (សូត្រសូម ៣ ដង) ។

លុះភិក្ខុនោះបានប្រព្រឹត្តមានត្តសព្វគ្រប់ហើយ សង្ឃត្រូវធ្វើអព្ភានកម្ម ដល់ភិក្ខុនោះ តែក្នុងទីនេះ មិនទាន់បាននិយាយអំពីអព្ភានកម្មទេ នឹងនិយាយដល់ទៅកម្មលក្ខណៈខាងចុង ។

មិស្សកសមោធានបរិវាស គឺបរិវាសដែលសង្ឃត្រូវឲ្យដោយប្រជុំអាបត្តិដែលប្រឡូកប្រឡំគ្នា គឺអាបត្តិដែលមានវត្ថុផ្សេង ១ គ្នា មានឈ្មោះថា សុក្កវិស្សដ្ឋិ កាយសំសគ្គៈ នឹង ទុដ្ឋុល្លវាចា ជាដើម ។ ភិក្ខុដែលត្រូវអាបត្តិមានសភាពយ៉ាងនេះ វេលាដែលធ្វើបរិវាស ត្រូវសូត្រសូមបរិវាសដូច្នេះ អហម្ភន្តេ សម្ពហុលា សង្ឃាទិសេសា អាបត្តិយោ អាបជ្ជឹ ឯកំ សុក្កវិស្សដ្ឋិំ ឯកំ កាយសំសគ្គំ ឯកំ ទុដ្ឋុល្លវាចំ ឯកំ អត្តកាមំ ឯកំ សញ្ចរិត្តំ ឯកំ កុដិការំ(១) ឯកំ វិហារការំ ឯកំ ទុដ្ឋទោសំ ឯកំ អញ្ញភាគិយំ ឯកំ សង្ឃភេទំ ឯកំ ភេទានុវត្តកំ ឯកំ ទុព្វចំ ឯកំ កុលទូសកំ សោហម្ភន្តេ សង្ឃំ តាសំ អាបត្តីនំ សមោធានបរិវាសំ យាចាមិ "បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំព្រះករុណាបានត្រូវហើយ នូវអាបត្តិសង្ឃាទិសេសជា

---

១ បា កុដិការំ ក៏មាន ។

ច្រើន អាបត្តិមួយឈ្មោះសុក្កវិស្សដ្ឋិ មួយឈ្មោះកាយសំសគ្គៈ មួយឈ្មោះទុដ្ឋុល្លវាចា មួយឈ្មោះអត្តកាមៈ មួយឈ្មោះសញ្ចរិត្តៈ មួយឈ្មោះកុដិការៈ មួយឈ្មោះវិហារការៈ មួយឈ្មោះទុដ្ឋទោសៈ មួយឈ្មោះអញ្ញភាគិយៈ មួយឈ្មោះសង្ឃភេទៈ មួយឈ្មោះភេទានុវត្តកៈ មួយឈ្មោះទុព្វចៈ មួយឈ្មោះកុលទូសកៈ បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំព្រះករុណានោះ សូមនូវសមោធាន-បរិវាសអំពីសង្ឃ ដើម្បីអាបត្តិទាំងឡាយនោះ ” សូត្រ ៣ ដង ។

វិនយធរគប្បីលៃលកប្រកបចងកម្មវាចា ឲ្យត្រូវតាមទំនងពាក្យសូមនេះ ផ្ដើវិនយកម្មដល់ភិក្ខុដែលត្រូវអាបត្តិបែបនេះ ទាំងមានត្តទាំងអព្ភាន ក៏ត្រូវរៀបរៀងឲ្យត្រូវតាមទំនងពាក្យសូមនេះដែរ ។

មួយទៀត បើអាបត្តិដែលមិនបិទបាំងទេ សង្ឃមិនបាច់ឲ្យបរិវាសឡើយ ត្រូវឲ្យតែមានត្ត ៦ រាត្រី ហើយឲ្យអព្ភានទៅ ក៏អាចនឹងរួចចាកអាបត្តិបាន តាមពុទ្ធានុញ្ញាត ។ ឯវិធីដែលធ្វើមានត្តនោះ ត្រូវឲ្យសូមដូច្នេះ

អហម្ភន្តេ សម្ពហុលា អាបត្តិយោ អាបជ្ជឹ អប្បដិច្ឆន្នាយោ សោហម្ភន្តេ សង្ឃំ សម្ពហុលានំ អាបត្តីនំ អប្បដិច្ឆន្នានំ ឆារត្តំ មានត្តំ យាចាមិ ។ អហម្ភន្តេ ។ បេ ។ ទុតិយម្បិ ភន្តេ សង្ឃំ សម្ពហុលានំ អាបត្តីនំ អប្បដិច្ឆន្នានំ ឆារត្តំ មានត្តំ យាចាមិ ។ អហម្ភន្តេ ។បេ។ តតិយម្បិ ភន្តេ សង្ឃំ សម្ពហុលានំ អាបត្តីនំ អប្បដិច្ឆន្នានំ ឆារត្តំ

មានត្តំ យាចាមិ[១] "បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំព្រះករុណាត្រូវហើយ នូវអាបត្តិជាច្រើន មិនបានបិទបាំងទេ, បពិត្រព្រះសង្ឃដ៏ចំរើន (ឥឡូវ) ខ្ញុំព្រះករុណានោះសូមនូវមានត្ត ៦ រាត្រីអំពីសង្ឃ ដើម្បីអាបត្តិជាច្រើន ដែលមិនបិទបាំង ។ បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំព្រះករុណា ។បេ។ បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំព្រះករុណាសូមនូវមានត្ត ៦ រាត្រីអំពីសង្ឃ ដើម្បីអាបត្តិជាច្រើន ដែលមិនបិទបាំង ជាគំរប់ពីរដងទៀត ។ បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំព្រះករុណា ។បេ។ បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំព្រះករុណាសូមនូវមានត្ត ៦ រាត្រីអំពីសង្ឃ ដើម្បីអាបត្តិជាច្រើនដែលមិនបិទបាំង ជាគំរប់បីដងទៀត"។

ភិក្ខុអ្នកឈ្លាស ប្រតិពល ត្រូវផ្តៀងសង្ឃថា៖

សុណាតុ មេ ភន្តេ សង្ឃោ អយំ (ឥត្ថន្នាមោ) ភិក្ខុ សម្ពហុលា អាបត្តិយោ អាបជ្ជិ អប្បដិច្ឆន្នាយោ សោ សង្ឃំ សម្ពហុលានំ អាបត្តីនំ អប្បដិច្ឆន្នានំ ឆារត្តំ មានត្តំ យាចតិ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ (ឥត្ថន្នាមស្ស) ភិក្ខុនោ សម្ពហុលានំ អាបត្តីនំ អប្បដិច្ឆន្នានំ ឆារត្តំ មានត្តំ ទទេយ្យ ឯសា ញត្តិ ។

សុណាតុ មេ ភន្តេ សង្ឃោ អយំ (ឥត្ថន្នាមោ) ភិក្ខុ

១ វិធីសូត្រសូមបរិវាសនឹងមានត្ត ដែលនិយាយដោយសង្ខេបទាំងប៉ុន្មាន ត្រូវនិយមតាមបែបនេះទាំងអស់ ។

បណ្ណាល័យ LIBRARY BUDDHIST INSTITUTE

សម្ពហុលា អាបត្តិយោ អាបជ្ជិ អប្បដិច្ឆន្នាយោ សោ សង្ឃំ សម្ពហុលានំ អាបត្តីនំ អប្បដិច្ឆន្នានំ ឆារត្តំ មានត្តំ យាចតិ សង្ឃោ (ឥត្ថន្នាមស្ស) ភិក្ខុនោ សម្ពហុលានំ អាបត្តីនំ អប្បដិច្ឆន្នានំ ឆារត្តំ មានត្តំ ទេតិ យស្សាយស្មតោ ខមតិ (ឥត្ថន្នាមស្ស) ភិក្ខុនោ សម្ពហុលានំ អាបត្តីនំ អប្បដិច្ឆន្នានំ ឆារត្តំ មានត្តស្ស ទានំ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។

ទុតិយម្បិ ឯតមត្ថំ វទាមិ ។ បេ ។

តតិយម្បិ ឯតមត្ថំ វទាមិ ។ បេ ។

ទិន្នំ សង្ឃេន (ឥត្ថន្នាមស្ស) ភិក្ខុនោ សម្ពហុលានំ អាបត្តីនំ អប្បដិច្ឆន្នានំ ឆារត្តំ មានត្តំ ខមតិ សង្ឃស្ស តស្មា តុណ្ហី ឯវមេតំ ធារយាមិ ។

"បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំ, ភិក្ខុ (ឈ្មោះនេះ) នេះ ត្រូវហើយនូវអាបត្តិជាច្រើន មិនបានបិទបាំងទេ ភិក្ខុនោះសូមនូវមានត្ត ៦ រាត្រីអំពីសង្ឃ ដើម្បីអាបត្តិជាច្រើន ដែលមិនបិទបាំង បើមានត្តទានកម្ម មានកាលដ៏សមគួរដល់សង្ឃហើយ សង្ឃគប្បីឲ្យនូវមានត្ត៦ រាត្រី ដល់ភិក្ខុ (ឈ្មោះនេះ) ដើម្បីអាបត្តិជាច្រើន ដែលមិនបិទបាំង នេះហៅថា ញត្តិ ។

បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំ ភិក្ខុ (ឈ្មោះនេះ) នេះ ត្រូវហើយនូវអាបត្តិជាច្រើន មិនបានបិទបាំងទេ ភិក្ខុនោះសូមនូវមានត្ត៦រាត្រីអំពីសង្ឃ ដើម្បីអាបត្តិជាច្រើន ដែលមិនបិទបាំង (ឥឡូវ) សង្ឃឲ្យនូវមានត្ត៦រាត្រី ដល់ភិក្ខុ (ឈ្មោះនេះ) ដើម្បីអាបត្តិជាច្រើន ដែលមិនបិទបាំង; ការឲ្យនូវមានត្ត៦រាត្រី ដល់ភិក្ខុ (ឈ្មោះនេះ) ដើម្បីអាបត្តិជាច្រើន ដែលមិនបិទបាំង គាប់ចិត្តដល់លោកអ្នកមានអាយុអង្គណា លោកអ្នកមានអាយុអង្គនោះត្រូវស្ងៀម មិនគាប់ចិត្តដល់លោកអ្នកមានអាយុអង្គណា លោកអ្នកមានអាយុអង្គនោះត្រូវនិយាយឡើង ។

ខ្ញុំពោលនូវសេចក្តីនេះ ជាគំរប់ពីរដងទៀត ។ បេ ។

ខ្ញុំពោលនូវសេចក្តីនេះ ជាគំរប់បីដងទៀត ។ បេ ។

មានត្ត ៦ រាត្រី សង្ឃបានឲ្យហើយ ដល់ភិក្ខុ (ឈ្មោះនេះ) ដើម្បីអាបត្តិជាច្រើន ដែលមិនបិទបាំង; ការឲ្យនោះគាប់ចិត្តដល់សង្ឃ ព្រោះហេតុនោះបានជាសង្ឃស្ងៀម, ខ្ញុំចាំទុកនូវរឿងនេះ ដោយអាការស្ងៀមយ៉ាងនេះ" ។

កាលបើចប់កម្មវាចាហើយ កិច្ចទាំងពួងគឺសមាទានវត្តក្តី ដាក់វត្តក្តី ការប្រព្រឹត្តិមានត្តក្តី គប្បីដឹងតាមរបៀបដូចបាននិយាយខាងដើម រួចមកហើយ ។ ភិក្ខុនោះលុះសមាទានវត្តរួចហើយ ត្រូវប្រាប់វត្តដូច្នេះ អហម្ភន្តេ សម្ពហុលា អាបត្តិយោ អាបជ្ជឹ អប្បដិច្ឆន្នា-យោ សោហំ សង្ឃំ សម្ពហុលានំ អាបត្តីនំ អប្បដិច្ឆ

ន្នានំ ឆារត្តំ មានត្តំ យាចិ តស្ស មេ សង្ឃោ សម្ពហុលានំ អាបត្តីនំ អប្បដិច្ឆន្នានំ ឆារត្តំ មានត្តំ អទាសិ សោហំ មានត្តំ ចរាមិ វេទិយាមហំ ភន្តេ វេទិយតីតិ មំ សង្ឃោ ធារេតុ “បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំព្រះករុណាត្រូវហើយនូវអាបត្តិជាច្រើន មិនបានបិទបាំងទេ ខ្ញុំព្រះករុណានោះ បានសូមហើយនូវមានត្ត៦រាត្រីអំពីសង្ឃ ដើម្បីអាបត្តិជាច្រើន ដែលមិនបិទបាំង សង្ឃបានឲ្យហើយនូវមានត្ត៦រាត្រី ដល់ខ្ញុំព្រះករុណានោះ ដើម្បីអាបត្តិជាច្រើន ដែលមិនបិទបាំង (ឥឡូវ) ខ្ញុំព្រះករុណានោះប្រព្រឹត្តមានត្ត, បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំព្រះករុណាសូមប្រាប់វត្ត សូមព្រះសង្ឃចាំទុកនូវខ្ញុំព្រះករុណាថាភិក្ខុនេះបានប្រាប់វត្ត” ។

លុះភិក្ខុនោះបានប្រព្រឹត្តមានត្តគ្រប់ ៦ រាត្រីហើយ សង្ឃមានគណៈ ២០ រូប ត្រូវធ្វើអព្ភានកម្មចំពោះភិក្ខុនោះ តែអព្ភាន មិនទាន់បាននិយាយក្នុងទីនេះទេ នឹងនិយាយដល់ទៅកម្មលក្ខណៈខាងចុង ដែលតអំពីនេះទៅទៀត ។ ការឲ្យនូវបរិវាសនឹងការឲ្យមានត្តដូចបាននិយាយមកនេះ ហៅថា ឋាន ក្នុងញត្តិចតុត្ថកម្មកថានេះ ។

និគ្គហៈ ការសង្កត់សង្កិន ។ សង្កត់សង្កិនក្នុងទីនេះសំដៅយកមូលាយបដិកស្សនកម្ម គឺការទាញត្រឡប់មកដាក់ក្នុងមូលាបត្តិវិញ ។ សេចក្តីថា ភិក្ខុត្រូវអាបត្តិសង្ឃាទិសេសបិទបាំងប៉ុន្មានថ្ងៃ សង្ឃឲ្យបរិវាស

តាមកំណត់ថ្ងៃដែលបិទបាំង ភិក្ខុនោះកំពុងប្រព្រឹត្តបរិវាស ក៏ត្រូវអាបត្តិសង្ឃាទិសេសទៀត បិទបាំងទៀត តែអាបត្តិក្រោយបិទបាំងតិចថ្ងៃជាងអាបត្តិមុន ឬស្មើថ្ងៃគ្នា ភិក្ខុនោះត្រូវសូមនូវមូលាយបដិកស្សនកម្មអំពីសង្ឃ សង្ឃត្រូវឲ្យនូវមូលាយបដិកស្សនកម្មដល់ភិក្ខុនោះ ដោយញត្តិចតុត្ថកម្មវាចា ឈ្មោះថាបានទាញភិក្ខុនោះមកដាក់ក្នុងមូលាបត្តិហើយ ត្រូវឲ្យភិក្ខុនោះសូមនូវសមោធានបរិវាស សង្ឃបានឲ្យសមោធានបរិវាស គឺប្រជុំអាបត្តិមុននឹងក្រោយធ្វើជាមួយគ្នា ថ្ងៃដែលបានប្រព្រឹត្តបរិវាសហើយទាំងប៉ុន្មាន ត្រូវលុបចោលទាំងអស់ ត្រូវប្រព្រឹត្តសាជាថ្មីទៀត យកត្រឹមតែកំណត់ថ្ងៃអាបត្តិមុនប៉ុណ្ណោះ បរិវាសក្រោយនេះ ហៅថា ឱធានសមោធានបរិវាស ។ ត្រង់ពាក្យថា សង្ឃឲ្យនូវមូលាយបដិកស្សនកម្មដល់ភិក្ខុនោះ ហៅថា និគ្គហៈ ការសង្កត់សង្កិន ក្នុងញត្តិចតុត្ថកម្មកថានេះ ។

ប៉ុន្តែក្នុងទីនេះ មិនបានស្រង់យកញត្តិនោះមកនិយាយទេ ព្រោះបាននិយាយខាងដើមត្រង់ ឱធានសមោធានបរិវាស រួចហើយ ។

សមនុភាសនា ការសូត្រសមនុភាសនកម្ម ហាមប្រាមនូវភិក្ខុឬភិក្ខុនីដែលប្រព្រឹត្តមិនសមគួរ ក្នុងព្រះពុទ្ធសាសនា ឲ្យលះបង់នូវអំពើអាក្រក់នោះចោលចេញទៅ បើមិនលះបង់ទេ ត្រូវអាបត្តិសង្ឃាទិសេសក៏មាន ថុល្លច្ច័យក៏មាន បាចិត្តិយៈក៏មាន ទុក្កដក៏មាន បារាជិកក៏មាន។ ក៏ឯវិធីសូត្រសមនុភាសនកម្មនោះ មាន ១១ សិក្ខាបទ ដែលលោកទាញមកបង្អុល

បង្ហាញក្នុងញត្តិបត្តកម្មកថានេះ គឺភិក្ខុវិភង្គមាន ៥ សិក្ខាបទ ភិក្ខុនីវិភង្គមាន ៦ សិក្ខាបទ ត្រូវជា ១១ សិក្ខាបទ ។

សូមអធិប្បាយសិក្ខាបទទាំង ១១ ដោយសង្ខេប ដូចតទៅនេះ៖

១-សង្ឃភេទសិក្ខាបទ ជាសិក្ខាបទទី ១០ ក្នុងសង្ឃាទិសេស-កណ្ឌ មានរឿងថា កាលព្រះមានព្រះភាគ គង់នៅក្នុងវត្តវេឡុវ័នកលន្ទក-និវាបស្ថាន នាក្រុងរាជគ្រឹះ កាលនោះ ទេវទត្តភិក្ខុព្យាយាមដើម្បីបំបែកសង្ឃដែលព្រមព្រៀងគ្នា, សេចក្តីព្យាយាមនោះក៏ក្លៀវក្លាហួសប្រមាណ ។ ពួកភិក្ខុដែលមានសេចក្តីប្រាថ្នាតិច ក៏នាំគ្នាក្រាបបង្គំទូលព្រះមានព្រះភាគ, ព្រះអង្គទ្រង់បញ្ញត្តសិក្ខាបទថា យោ បន ភិក្ខុ សមគ្គស្ស សង្ឃស្ស ភេទាយ បរក្កមេយ្យ ភេទនសំវត្តនិកំ វា អធិករណំ សមាទាយ បគ្គយ្ហ តិដ្ឋេយ្យ សោ ភិក្ខុ ភិក្ខូហិ ឯវមស្ស វចនីយោ មា អាយស្មា សមគ្គស្ស សង្ឃស្ស ភេទាយ បរក្កមិ ភេទនសំវត្តនិកំ វា អធិករណំ សមាទាយ បគ្គយ្ហ អដ្ឋាសិ សមេតាយស្មា សង្ឃេន សមគ្គោ ហិ សង្ឃោ សម្មោទមានោ អវិវទមានោ ឯកុទ្ទេសោ ផាសុ វិហរតីតិ ឯវញ្ច សោ ភិក្ខុ ភិក្ខូហិ វុច្ចមានោ តថេវ បគ្គណ្ហេយ្យ សោ ភិក្ខុ ភិក្ខូហិ យាវតតិយំ សមនុភាសិតព្វោ តស្ស បដិនិស្សគ្គាយ

យាវតតិយញ្ចេ សមនុភាសិយមានោ តំ បដិនិស្ស-ជ្ជេយ្យ ឥច្ចេតំ កុសលំ នោ ចេ បដិនិស្សជ្ជេយ្យ សង្ឃាទិសេសោ "ភិក្ខុណាមួយព្យាយាម ដើម្បីបំបែកសង្ឃ ដែលព្រមព្រៀងគ្នា ឬកាន់យកទឹងផ្គងឡើងនូវអធិករណ៍ ដែលប្រព្រឹត្តទៅ ដើម្បីបែកគ្នា, ភិក្ខុទាំងឡាយគប្បីនិយាយនឹងភិក្ខុនោះយ៉ាងនេះថា លោកអ្នកមានអាយុ កុំព្យាយាមដើម្បីបំបែកសង្ឃដែលព្រមព្រៀងគ្នាឡើយ ឬកុំកាន់យកទឹងផ្គងឡើងនូវអធិករណ៍ដែលប្រព្រឹត្តទៅដើម្បីបែកគ្នាឡើយ, លោកអ្នកមានអាយុ ចូរព្រមព្រៀងគ្នាជាមួយនឹងសង្ឃទៅ ព្រោះថាសង្ឃដែលព្រមព្រៀងគ្នា រីករាយនឹងគ្នា មិនទាស់ទែងគ្នា មានឧទ្ទេសជាមួយគ្នា រមែងនៅជាសុខសប្បាយ, ភិក្ខុនោះកាលបើភិក្ខុទាំងឡាយ និយាយយ៉ាងនេះហើយក៏នៅតែផ្គងឡើងយ៉ាងនោះដដែល ភិក្ខុទាំងឡាយគប្បី (សូត្រសមនុភាសនកម្ម) ហាមប្រាមភិក្ខុនោះ ជាគំរប់បីដងជាកំណត់ ដើម្បីឲ្យលះបង់នូវអំពើនោះចេញ ភិក្ខុនោះកាលបើភិក្ខុទាំងឡាយ (សូត្រសមនុភាសនកម្ម) ហាមប្រាមជាគំរប់ ៣ ដង ក៏លះបង់នូវអំពើនោះចេញ, ការលះបង់នេះ ជាការគាប់ប្រសើរ (ឥតទោស) បើមិនលះបង់ទេ, ត្រូវអាបត្តិសង្ឃាទិសេស" ។

ត្រង់ពាក្យថា ហាមប្រាម នោះគឺសូត្រសមនុភាសនកម្មដោយញត្តិចតុត្ថកម្មវាចា ។ ភិក្ខុអ្នកឈ្លាស ប្រតិពល ត្រូវផ្ទៀងសង្ឃថា

សុណាតុ មេ ភន្តេ សង្ឃោ អយំ (ឥត្ថន្នាមោ) ភិក្ខុ សមគ្គស្ស សង្ឃស្ស ភេទាយ បរក្កមតិ សោ តំ វត្ថុំ នប្បដិនិស្សជ្ជតិ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ (ឥត្ថន្នាមំ) ភិក្ខុំ សមនុភាសេយ្យ តស្ស វត្ថុស្ស បដិនិស្សគ្គាយ ឯសា ញត្តិ ។

សុណាតុ មេ ភន្តេ សង្ឃោ អយំ (ឥត្ថន្នាមោ) ភិក្ខុ សមគ្គស្ស សង្ឃស្ស ភេទាយ បរក្កមតិ សោ តំ វត្ថុំ នប្បដិនិស្សជ្ជតិ សង្ឃោ (ឥត្ថន្នាមំ) ភិក្ខុំ សមនុភាសតិ តស្ស វត្ថុស្ស បដិនិស្សគ្គាយ យស្សាយស្មតោ ខមតិ (ឥត្ថន្នាមស្ស) ភិក្ខុនោ សមនុភាសនា តស្ស វត្ថុស្ស បដិនិស្សគ្គាយ សោ តុណ្ហាស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។

ទុតិយម្បិ ឯតមត្ថំ វទាមិ ។ បេ ។

តតិយម្បិ ឯតមត្ថំ វទាមិ ។ បេ ។

សមនុភដ្ឋោ សង្ឃេន (ឥត្ថន្នាមោ) ភិក្ខុ តស្ស វត្ថុស្ស បដិនិស្សគ្គាយ ខមតិ សង្ឃស្ស តស្មា តុណ្ហី ឯវមេតំ ធារយាមិ ។

“បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្ដាប់ពាក្យខ្ញុំ, ភិក្ខុ (ឈ្មោះនេះ)

នេះ ព្យាយាមដើម្បីបំបែកសង្ឃដែលព្រមព្រៀងគ្នា ភិក្ខុនោះមិនលះបង់នូវរឿងនោះទេ បើសមនុភាសនកម្ម មានកាលដ៏សមគួរដល់សង្ឃហើយ សង្ឃគប្បីហាមប្រាមនូវភិក្ខុ (ឈ្មោះនេះ) ដើម្បីឲ្យលះបង់នូវរឿងនោះចេញ នេះហៅថា ញត្តិ ។

បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំ, ភិក្ខុ (ឈ្មោះនេះ) នេះ ព្យាយាមដើម្បីបំបែកសង្ឃដែលព្រមព្រៀងគ្នា ភិក្ខុនោះមិនលះបង់នូវរឿងនោះទេ (ឥឡូវ) សង្ឃហាមប្រាមនូវភិក្ខុ (ឈ្មោះនេះ) ដើម្បីឲ្យលះបង់នូវរឿងនោះចេញ; ការហាមប្រាមនូវភិក្ខុ (ឈ្មោះនេះ) ដើម្បីឲ្យលះបង់នូវរឿងនោះចេញ គាប់ចិត្តដល់លោកអ្នកមានអាយុអង្គណា លោកអ្នកមានអាយុអង្គនោះត្រូវស្ងៀម មិនគាប់ចិត្តដល់លោកអ្នកមានអាយុអង្គណា លោកអ្នកមានអាយុអង្គនោះត្រូវនិយាយឡើង ។

ខ្ញុំពោលនូវសេចក្តីនេះ ជាគំរប់ពីរដងទៀត ។បេ។
ខ្ញុំពោលនូវសេចក្តីនេះ ជាគំរប់បីដងទៀត ។បេ។

ភិក្ខុ (ឈ្មោះនេះ) សង្ឃបានហាមប្រាមហើយ ដើម្បីឲ្យលះបង់នូវរឿងនោះចេញ, ការហាមប្រាមនោះគាប់ចិត្តដល់សង្ឃ ព្រោះហេតុនោះបានជាសង្ឃស្ងៀម, ខ្ញុំចាំទុកនូវរឿងនេះ ដោយអាការស្ងៀមយ៉ាងនេះ" ។

សេចក្តីក្នុងសិក្ខាបទនេះថា សង្ឃសូត្រសមនុភាសនកម្ម ចប់ញត្តិ បើមិនលះបង់ទេត្រូវអាបត្តិទុក្កដ ១ ចប់អនុស្សាវនាទី ១ ត្រូវថុល្លច្ច័យ ១

ចប់អនុសាវនាទី ២ ត្រូវថុល្លច្ច័យ ១ ទៀត, ចប់អនុសាវនាទី ៣ ត្រូវសង្ឃាទិសេស; កាលបើត្រូវសង្ឃាទិសេសហើយ អាបត្តិទុក្កដ ១ នឹងថុល្លច្ច័យ ២ ក៏រម្ងាប់ទៅឯង ។

២- ភេទានុវត្តកសិក្ខាបទ ជាសិក្ខាបទទី ១១ មានរឿងថា កាលព្រះមានព្រះភាគគង់នៅ ក្នុងវត្តវេឡុវ័នកលន្ទកនិវាបស្ថាន នាក្រុងរាជគ្រឹះ គ្រានោះ ទេវទត្តភិក្ខុព្យាយាម ដើម្បីបំបែកសង្ឃ ដើម្បីបំបែកចក្រ ។ ភិក្ខុទាំងឡាយនាំគ្នាពោលទោសថា ទេវទត្តជាអធម្មវាទី ជាអវិនយវាទី មិនសមបើព្យាយាម ដើម្បីបំបែកសង្ឃ ដើម្បីបំបែកចក្រសោះ ។ ទើប កោកាលិកភិក្ខុ កដមោរកតិស្សកភិក្ខុ ជាខណ្ឌទេវីបុត្ត នឹងសមុទ្ទទត្តភិក្ខុ និយាយទៅនឹងភិក្ខុទាំងឡាយនោះថា លោកអ្នកមានអាយុទាំងឡាយកុំពោលយ៉ាងហ្នឹងឡើយ ទេវទត្តជាធម្មវាទី ជាវិនយវាទី កាន់យកនូវសេចក្តីពេញចិត្តនឹងសេចក្តីគាប់ចិត្ត របស់យើងទាំងឡាយហើយទើបពោល ដឹងនូវសេចក្តីពេញចិត្តនឹងសេចក្តីគាប់ចិត្តរបស់យើងទាំងឡាយហើយទើបពោល អំពើនេះគាប់ចិត្ត ដល់យើងទាំងឡាយ ។ ពួកភិក្ខុដែលមានសេចក្តីប្រាថ្នាតិចក៏នាំគ្នាក្រាបបង្គំទូលព្រះមាន ព្រះភាគ, ព្រះអង្គទ្រង់បញ្ញត្តនូវភេទានុវត្តកសិក្ខាបទនេះឡើង, ឯសេចក្តីក្នុងសិក្ខាបទនេះថា បើមានភិក្ខុព្យាយាមដើម្បីបំបែកសង្ឃ ហើយមានភិក្ខុដែលត្រឹមត្រូវពោលទោសថា ជាអធម្មវាទី ជាអវិនយវាទីជាដើម មានពួកភិក្ខុ

សូម្បីតែ ១ រូបក្តី ២ រូបក្តី ៣ រូបក្តី ជាអ្នកនិយាយប្រកាន់ពួកបក្ខ ប្រព្រឹត្ត តាមភិក្ខុដែលព្យាយាមដើម្បីបំបែកសង្ឃនោះ ពោលពាក្យប្រឆាំងគ្នានឹង ពួកភិក្ខុអ្នកត្រឹមត្រូវនោះថា ម្នាលលោកអ្នកមានអាយុទាំងឡាយ លោក ទាំងឡាយកុំពោលពាក្យអ្វីនឹងភិក្ខុនុ៎ះឡើយ ព្រោះភិក្ខុនុ៎ះ ជាធម្មវាទីផង ជាវិនយវាទីផង កាន់យកនូវសេចក្តីពេញចិត្តនឹងសេចក្តីគាប់ចិត្តរបស់យើង ទាំងឡាយហើយទើបពោល ដឹងនូវសេចក្តីពេញចិត្តនឹងសេចក្តីគាប់ចិត្ត របស់យើងទាំងឡាយហើយទើបពោល ; ពួកភិក្ខុដែលត្រឹមត្រូវ គប្បី និយាយទៅភិក្ខុទាំងនោះវិញថា ម្នាលលោកអ្នកមានអាយុទាំងឡាយ លោកទាំងឡាយកុំនិយាយយ៉ាងហ្នឹងឡើយ ព្រោះភិក្ខុនុ៎ះមិនមែនជាធម្មវាទី មិនមែនជាវិនយវាទីទេ លោកអ្នកមានអាយុទាំងឡាយកុំគាប់ចិត្តនឹង សង្ឃភេទឡើយ ចិត្តរបស់លោកអ្នកមានអាយុទាំងឡាយចូរព្រមព្រៀង ជាមួយនឹងសង្ឃទៅ ព្រោះសង្ឃដែលព្រមព្រៀងគ្នា រីករាយរកគ្នា មិនទាស់ទែងគ្នា មានឧទ្ទេសជាមួយគ្នា រមែងនៅជាសុខសប្បាយ ; ពួក ភិក្ខុនោះ កាលបើពួកភិក្ខុអ្នកត្រឹមត្រូវនិយាយយ៉ាងនេះហើយ គឺនៅតែ ផ្គងឡើងដូចមុនដដែល ; ពួកភិក្ខុអ្នកត្រឹមត្រូវគប្បី (សូត្រសមនុភាសនកម្ម) ហាមប្រាមពួកភិក្ខុនោះជាគំរប់៣ដង ដើម្បីឲ្យលះបង់នូវអំពើនោះចេញ កាលបើគេហាមប្រាមហើយលះបង់អំពើនោះចេញ គឺជាការគាប់ប្រសើរ បើមិនលះបង់ទេ ត្រូវអាបត្តិសង្ឃាទិសេស ។

៣- ទុព្វចជាតិកាសិក្ខាបទ ជាសិក្ខាបទទី ១២ មានរឿងថា កាលព្រះមានព្រះភាគគង់នៅក្នុងឃោសិតារាមទៀបក្រុងកោសម្ពី គ្រានោះ ឆន្នភិក្ខុប្រព្រឹត្តអនាចារផ្សេងៗ ។ ពួកភិក្ខុបាននិយាយដាស់តឿនក្រើនរំលឹកថា កុំធ្វើអំពើយ៉ាងហ្នឹងទៀត អំពើនេះមិនគួរទេ ។ ឆន្នភិក្ខុជាមនុស្សរឹងរូសប្រដៅក្រ និយាយហាមឃាត់ថា លោកពល់គ្នាមិនត្រូវនិយាយអ្វីនឹងខ្ញុំទេ ខ្ញុំក៏មិនត្រូវនិយាយអ្វីនឹងលោកពល់គ្នាដែរ ព្រះពុទ្ធរបស់យើង ព្រះធម៌របស់យើង ព្រះអយ្យបុត្ររបស់យើងត្រាស់ដឹងធម៌ ។ ពួកភិក្ខុដែលមានសេចក្តីប្រាថ្នាតិច ក៏នាំគ្នាក្រាបបង្គំទូលព្រះមានព្រះភាគ. ព្រះអង្គទ្រង់បញ្ញត្តិទុព្វចជាតិកសិក្ខាបទនេះឡើង ឯសេចក្តីក្នុងសិក្ខាបទនេះថា ភិក្ខុជាទុព្វចជាតិកៈ គឺប្រកបដោយជាតិដែលគេប្រដៅក្រ កាលបើភិក្ខុឯទៀតនិយាយទូន្មានដោយពាក្យ ប្រកបដោយធម៌ក្នុងសិក្ខាបទទាំងឡាយដែលរាប់បញ្ចូលក្នុងឧទ្ទេស (បាតិមោក្ខ) ធ្វើខ្លួនឲ្យគេនិយាយទូន្មានមិនកើត ហាមឃាត់គេថា លោកអ្នកមានអាយុទាំងឡាយកុំនិយាយអ្វី ទោះល្អក្តី អាក្រក់ក្តី នឹងខ្ញុំឡើយ ខ្ញុំក៏មិនត្រូវនិយាយអ្វី ទោះល្អក្តី អាក្រក់ក្តីនឹងលោកអ្នកមានអាយុទាំងឡាយដែរ បពិត្រលោកអ្នកមានអាយុទាំងឡាយ លោកទាំងឡាយលែងនិយាយនឹងខ្ញុំតទៅទៀត; ភិក្ខុទាំងឡាយឯទៀតត្រូវនិយាយនឹងភិក្ខុនោះយ៉ាងនេះថា លោកអ្នកមានអាយុកុំធ្វើខ្លួនឲ្យគេនិយាយទូន្មានមិនកើតឡើយ លោកអ្នកមានអាយុចូរធ្វើខ្លួនឲ្យគួរគេនិយាយ

ទូន្មានបានទៅ លោកអ្នកមានអាយុ ចូរនិយាយនឹងភិក្ខុឯទៀត ដោយពាក្យប្រកបដោយធម៌ទៅ ចំណែកពួកភិក្ខុឯទៀត គឺនឹងនិយាយនឹងលោកអ្នកមានអាយុ ដោយពាក្យប្រកបដោយធម៌ដែរ ព្រោះបរិស័ទរបស់ព្រះមានព្រះភាគនោះលូតលាស់ចំរើនបាន ក៏ដោយសារពាក្យជាប្រយោជន៍ដល់គ្នានឹងគ្នា ដោយការញុំាងគ្នានឹងគ្នាឲ្យចេញចាកអាបត្តិ; ភិក្ខុនោះកាលដែលពួកភិក្ខុឯទៀតនិយាយយ៉ាងនេះ ក៏នៅតែផ្គងឡើងយ៉ាងនោះដដែល ពួកភិក្ខុឯទៀតត្រូវ (សូត្រសមនុភាសនកម្ម) ហាមប្រាមភិក្ខុនោះជាគំរប់បីដង ដើម្បីឲ្យលះបង់នូវអំពើនោះចេញ បើហាមប្រាមគំរប់បីដងហើយលះបង់អំពើនោះចេញ ក៏ជាការគាប់ប្រសើរ បើមិនលះបង់ទេ ត្រូវអាបត្តិសង្ឃាទិសេស ។

៤-កុលទូសកសិក្ខាបទ ជាសិក្ខាបទទី ១៣ មានរឿងថា កាលព្រះមានព្រះភាគគង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋីទៀបក្រុងសាវត្ថី គ្រានោះ ពួកអស្សជិភិក្ខុនឹងបុនព្វសុកភិក្ខុ មានអាវាសក្នុងកីដាគិរីជនបទ ជាភិក្ខុលាមកឥតមានសេចក្ដីអៀនខ្មាស ប្រព្រឹត្តអនាចារផ្សេងៗ មានដាំដើមផ្កាខ្លួនឯងខ្លះ ប្រើគេឲ្យដាំខ្លះ ស្រោចខ្លួនឯងខ្លះ ប្រើគេឲ្យស្រោចខ្លះ បេះខ្លួនឯងខ្លះ ប្រើគេឲ្យបេះខ្លះ ក្រងផ្កាខ្លួនឯងខ្លះ ប្រើគេឲ្យក្រងផ្កាខ្លះ ជាដើម ។ ពួកភិក្ខុដែលមានសេចក្ដីប្រាថ្នាតិច ក៏នាំគ្នាក្រាបបង្គំទូលព្រះមានព្រះភាគ, ព្រះអង្គទ្រង់បញ្ញត្តកុលទូសកសិក្ខាបទនេះឡើង

ឯសេចក្ដីក្នុងសិក្ខាបទនេះថា ភិក្ខុនៅអាស្រ័យនឹងស្រុកឬនិគមណាមួយ ជាអ្នកប្រទូស្តត្រកូល មានការប្រព្រឹត្តិដ៏អាក្រក់, ការប្រព្រឹត្តិដ៏អាក្រក់របស់ភិក្ខុនោះ គេតែងឃើញតែងឮជាក់ស្ដែង ទាំងត្រកូលដែលភិក្ខុនោះប្រទូស្តហើយ ក៏គេឃើញគេឮជាក់ស្ដែងដែរ; ពួកភិក្ខុឯទៀតត្រូវនិយាយនឹងភិក្ខុនោះយ៉ាងនេះថា លោកអ្នកមានអាយុជាអ្នកប្រទូស្តត្រកូល មានការប្រព្រឹត្តិដ៏អាក្រក់, ការប្រព្រឹត្តិដ៏អាក្រក់របស់លោកអ្នកមានអាយុ គេតែងឃើញតែងឮជាក់ស្ដែង ទាំងត្រកូលដែលលោកអ្នកមានអាយុប្រទូស្តហើយ ក៏គេឃើញគេឮជាក់ស្ដែងដែរ លោកអ្នកមានអាយុចូរថយចេញអំពីអាវាសនេះទៅ លោកមិនគួរនៅក្នុងអាវាសនេះទេ; ភិក្ខុនោះកាលដែលពួកភិក្ខុឯទៀតនិយាយយ៉ាងនេះហើយ ក៏និយាយតបទៅពួកភិក្ខុនោះយ៉ាងនេះថា ភិក្ខុទាំងឡាយលុះលង់ដោយសេចក្ដីស្រឡាញ់ផង លុះលង់ដោយសេចក្ដីស្អប់ផង លុះលង់ដោយសេចក្ដីល្ងង់ផង លុះលង់ដោយសេចក្ដីខ្លាចផង បណ្ដេញភិក្ខុខ្លះ មិនបណ្ដេញភិក្ខុខ្លះ ដោយអាបត្តិដូចគ្នាដែរ, ភិក្ខុទាំងឡាយត្រូវនិយាយនឹងភិក្ខុនោះយ៉ាងនេះថា លោកអ្នកមានអាយុកុំនិយាយយ៉ាងហ្នឹងឡើយ ភិក្ខុទាំងឡាយមិនមែនលុះលង់ដោយសេចក្ដីស្រឡាញ់ទេ មិនមែនលុះលង់ដោយសេចក្ដីស្អប់ទេ មិនមែនលុះលង់ដោយសេចក្ដីល្ងង់ទេ មិនមែនលុះលង់ដោយសេចក្ដីខ្លាចទេ លោកអ្នកមានអាយុទេតើ ដែលជាអ្នកប្រទូស្តត្រកូល មានការប្រព្រឹត្តិដ៏អាក្រក់; ការប្រព្រឹត្តិដ៏អាក្រក់របស់លោក

អ្នកមានអាយុ គេតែងឃើញតែងឮជាក់ស្តែង ទាំងត្រកូលដែលលោកអ្នកមានអាយុទ្រុស្តហើយ ក៏គេឃើញគេឮជាក់ស្តែងដែរ លោកអ្នកមានអាយុបូលថយចេញអំពីអាវាសនេះទៅ លោកមិនគួរនៅក្នុងអាវាសនេះទេ; ភិក្ខុនោះកាលដែលភិក្ខុទាំងឡាយ និយាយយ៉ាងនេះហើយ ក៏នៅតែផ្គងឡើងដូចមុនដដែល, ភិក្ខុទាំងឡាយគប្បី (សូត្រសមនុភាសនកម្ម) ហាមប្រាមភិក្ខុនោះគំរប់បីដង ដើម្បីឲ្យលះបង់នូវអំពើនោះចេញ, បើហាមប្រាមគំរប់បីដងហើយ លះបង់នូវអំពើនោះចេញ ក៏ជាការគាប់ប្រសើរ បើមិនលះបង់ទេ ត្រូវអាបត្តិសង្ឃាទិសេស ។

៩-អរិដ្ឋសិក្ខាបទ ជាសិក្ខាបទទី ៨ នៃសប្បាណកវគ្គបាចិត្តិយកណ្ឌ ភិក្ខុវិភង្គ មានរឿងថា កាលព្រះមានព្រះភាគគង់នៅក្នុងវត្តជេតពនរបស់អនាថបិណ្ឌិកសេដ្ឋីទៀបក្រុងសាវត្ថី គ្រានោះអរិដ្ឋភិក្ខុជាពហុស្សូតជាធម្ម-កថិក ស្គាល់នូវអន្តរាយិកធម៌ដ៏សេស តែមិនស្គាល់នូវបណ្ណត្តិវីតិក្កមន្តរាយិ-កធម៌ (គឺការប្រព្រឹត្តិកន្លងនូវបញ្ញត្តិជាធម៌ធ្វើនូវសេចក្តីអន្តរាយ) ព្រោះមិនឈ្លាសក្នុងព្រះវិន័យបានជានៅក្នុងទីស្ងាត់កើតគំនិតខុសឡើងថា ពួកគ្រ-ហស្ថគេបរិភោគកាមគុណទាំង ៥ គេបានជាសោតាបន្នបុគ្គលក៏មាន ជាសកិទាគាមីក៏មាន ជាអនាគាមីក៏មាន · ចំណែកខាងពួកភិក្ខុឃើញរូបដែលជាទីគាប់ចិត្ត ដែលគួរដឹងដោយចក្ខុវិញ្ញាណក្តី ។បេ។ ពាល់ត្រូវផោដ្ឋព្វៈដែលគួរដឹងច្បាស់ដោយកាយវិញ្ញាណក្តី ប្រើប្រាស់នូវវត្ថុមានកម្រាលទីង

សំពត់ដណ្តប់ជាដើមដែលមានសាច់ទន់ល្អិត របស់នេះសុទ្ធតែគួរទាំងអស់ ចុះហេតុអ្វីបានជារូបស្ត្រី ។បេ។ ផោដ្ឋព្វៈនៃស្ត្រី ត្រឡប់ទៅជាមិនគួរទៅវិញ? អារម្មណ៍ទាំងអម្បាលនេះប្រាកដជាគួរ ។ អរិដ្ឋភិក្ខុនោះយករសនឹងរសមកប្រៀបធៀបគ្នា យកសច្ចនុភាគបរិភោគនឹងនិច្ចនុភាគបរិភោគមកផ្គួបគ្នា ប្រៀបដូចគេយកសំបកឈើដែលជ្រុសមកតគ្នានឹងអម្បោះ ដែលឆ្មារល្អិត ពុំនោះសោតដូចគេយកគ្រាប់ស្ពៃទៅផ្គួបគ្នានឹងភ្នំព្រះសុមេរុ ញុំាងទិដ្ឋិខុសឲ្យកើតឡើងថា ព្រះអង្គបញ្ញត្តិបឋមបារាជិក ប្រៀបដូចគេទប់មហាសមុទ្រដោយព្យាយាមដ៏ធំ គ្មានទោសអ្វីត្រង់រូបស្ត្រីជាដើមនោះទេ។ អរិដ្ឋភិក្ខុនោះ មានការយល់ជាទំនាស់នឹងសព្វញ្ញុតញ្ញាណ កាត់បង់នូវសេចក្តីប្រាថ្នារបស់ភព្យបុគ្គល ឲ្យនូវប្រហារក្នុងអាណាចក្ររបស់ព្រះជិនស្រី; បានជាប្រកាសថា ខ្ញុំដឹងច្បាស់នូវធម៌ដែលព្រះមានព្រះភាគទ្រង់សំដែងហើយថា “ធ្វើនូវសេចក្តីអន្តរាយ” ធម៌នោះឥតមានអន្តរាយអ្វីដល់បុគ្គលអ្នកសេពឡើយ ។ ពួកភិក្ខុដែលមានសេចក្តីប្រាថ្នាតិច ក៏នាំគ្នាក្រាបបង្គំទូលព្រះមានព្រះភាគ ។ ទ្រង់បញ្ញត្តអរិដ្ឋសិក្ខាបទនេះឡើង, ឯសេចក្តីក្នុងសិក្ខាបទនេះថា ភិក្ខុណាមួយ ពោលថា ខ្ញុំដឹងច្បាស់ថា ធម៌ដែលព្រះមានព្រះភាគ ទ្រង់សំដែងហើយ ថាធ្វើនូវសេចក្តីអន្តរាយ ធម៌នោះឥតមានអន្តរាយអ្វីដល់បុគ្គលអ្នកសេពឡើយ; ភិក្ខុទាំងឡាយត្រូវនិយាយនឹងភិក្ខុនោះថា លោកអ្នកមានអាយុកុំនិយាយយ៉ាងនេះឡើយ កុំ

ពោលបង្អាច់ព្រះមានព្រះភាគឡើយ ការពោលបង្អាច់ព្រះមានព្រះភាគមិនល្អទេ ព្រះមានព្រះភាគមិនពោលយ៉ាងនេះទេ ម្នាលអាវុសោ ធម៌ធ្វើនូវសេចក្ដីអន្តរាយ ព្រះអង្គទ្រង់សំដែងហើយដោយអនេកបរិយាយ ធម៌នោះគួរដើម្បីអន្តរាយដល់បុគ្គលអ្នកសេពដោយពិត; ភិក្ខុនោះ កាលបើភិក្ខុទាំងឡាយនិយាយយ៉ាងនេះហើយ ក៏នៅតែផ្គងឡើងដូចមុនដដែល, ភិក្ខុទាំងឡាយត្រូវ (សូត្រសមនុភាសនកម្ម) ហាមប្រាម ភិក្ខុនោះជាគំរប់បីដង ដើម្បីឲ្យលះបង់នូវអំពើនោះចេញ; បើហាមប្រាមគំរប់បីដងហើយលះបង់នូវអំពើនោះចេញ ក៏ជាការគាប់ប្រសើរ បើមិនលះបង់ទេ ត្រូវអាបត្តិបាចិត្តិយៈ ។

សេចក្ដីក្នុងសិក្ខាបទនេះថា ចប់ញត្តិត្រូវទុក្កដ, ចប់អនុស្សាវនាទី១ ទី ២ ត្រូវទុក្កដ ២, ចប់អនុស្សាវនាទី ៣ ត្រូវបាចិត្តិយៈ ។

៦- ចណ្ឌកាលីសិក្ខាបទ ជាសិក្ខាបទទី ១០ ក្នុងសង្ឃាទិសេសកណ្ឌ ភិក្ខុនីវិភង្គ មានសេចក្ដីថា កាលព្រះពុទ្ធជាបរមសាស្ដាទ្រង់គង់នៅនាវត្តជេតពនរបស់អនាថបិណ្ឌិកសេដ្ឋីទៀបក្រុងសាវត្ថី គ្រានោះភិក្ខុនីឈ្មោះចណ្ឌកាលី ឈ្លោះគានឹងភិក្ខុនីទាំងឡាយ ហើយខឹងតូចចិត្តក៏និយាយថា ខ្ញុំសូមលាព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃនឹងសិក្ខា ភិក្ខុនីទាំងឡាយណា ជាសមណី ជាធីតានៃព្រះពុទ្ធជាសក្យៈ ភិក្ខុនីទាំងឡាយនោះនឹងហៅថា សមណីដូចម្ដេចបាន? សមណីទាំងឡាយដទៃ ដែលមាន

សេចក្ដីអៀនខ្មាស មានសេចក្ដីរង្កៀស ស្រឡាញ់ការសិក្សា ក៏មានខ្លះដែរ អញ្ញនឹងប្រព្រឹត្តព្រហ្មចារ្យក្នុងសំណាក់នៃសមណីទាំងឡាយនោះ ៗ ពួកភិក្ខុនីដែលមានសេចក្ដីប្រាថ្នាតិច ក៏នាំគ្នាពិតទូលពួកភិក្ខុៗក៏នាំគ្នាក្រាបបង្គំទូលព្រះមានព្រះភាគ, ព្រះអង្គទ្រង់បញ្ញត្តសិក្ខាបទថា យា បន ភិក្ខុនី កុបិតា អនត្តមនា ឯវំ វទេយ្យ ពុទ្ធំ បច្ចាចិក្ខាមិ ធម្មំ បច្ចាចិក្ខាមិ សង្ឃំ បច្ចាចិក្ខាមិ សិក្ខំ បច្ចាចិក្ខាមិ កិន្នុមាវ សមណិយោ យា សមណិយោ សក្យធីតរោ សន្តញ្ញាបិ សមណិយោ លជ្ជិនិយោ កុក្កុច្ចិកា សិក្ខាកាមា តាសាហំ សន្តិកេ ព្រហ្មចរិយំ ចរិស្សាមីតិ; សា ភិក្ខុនី ភិក្ខុនីហិ ឯវមស្ស វចនីយា មាយ្យេ កុបិតា អនត្តមនា ឯវំ អវច ពុទ្ធំ បច្ចាចិក្ខាមិ ។បេ។ សិក្ខំ បច្ចាចិក្ខាមិ កិន្នុមាវ សមណិយោ យា សមណិយោ សក្យធីតរោ សន្តញ្ញាបិ សមណិយោ លជ្ជិនិយោ កុក្កុច្ចិកា សិក្ខាកាមា តាសាហំ សន្តិកេ ព្រហ្មចរិយំ ចរិស្សាមីតិ; អភិរមយ្យេ ស្វាក្ខាតោ ធម្មោ ចរ ព្រហ្មចរិយំ សម្មា ទុក្ខស្ស អន្តកិរិយាយាតិ; ឯវញ្ច សា ភិក្ខុនី ភិក្ខុនីហិ វុច្ចមានា តថេវ បគ្គណ្ហេយ្យ សា ភិក្ខុនី ភិក្ខុនីហិ យាវតតិយំ សមនុភាសិតព្វា តស្ស

បដិនិស្សគ្គាយ យាវតតិយញ្ចេ សមនុភាសិយមានា តំ បដិនិស្សជ្ជេយ្យ ឥច្ចេតំ កុសលំ នោ ចេ បដិនិស្ស-ជ្ជេយ្យ អយម្បិ ភិក្ខុនី យាវតតិយកំ ធម្មំ អាបន្នា និស្សារណីយំ សង្ឃាទិសេសំ ភិក្ខុនីណាមួយខឹងតូចចិត្តនិយាយយ៉ាងនេះថា ខ្ញុំសូមលាព្រះពុទ្ធ ខ្ញុំសូមលាព្រះធម៌ ខ្ញុំសូមលាព្រះសង្ឃ សូមលាសិក្ខា ភិក្ខុនីទាំងឡាយណា ជាសមណី ជាធីតានៃព្រះពុទ្ធជាសក្យៈ ភិក្ខុនីទាំងឡាយនេះនឹងហៅថា សមណី ដូចម្តេចបាន?សមណីទាំងឡាយដទៃដែលមានសេចក្តីអៀនខ្មាស មានសេចក្តីរង្កៀសស្រឡាញ់ការសិក្សា ក៏មានខ្លះដែរ ខ្ញុំនឹងប្រព្រឹត្តព្រហ្មចារ្យ ក្នុងសំណាក់នៃសមណីទាំងឡាយនោះ ភិក្ខុនីទាំងឡាយត្រូវនិយាយនឹងភិក្ខុនីនោះថា នែលោកម្ចាស់ លោកកុំខឹងតូចចិត្ត ហើយនិយាយយ៉ាងនេះថា ខ្ញុំសូមលាព្រះពុទ្ធ ។បេ។ សូមលាសិក្ខា ភិក្ខុនីទាំងឡាយណាជាសមណី ជាធីតានៃព្រះពុទ្ធជាសក្យៈ ភិក្ខុនីទាំងឡាយនេះនឹងហៅថា សមណី ដូចម្តេចបាន? សមណីទាំងឡាយដទៃដែលមានសេចក្តីអៀនខ្មាស មានសេចក្តីរង្កៀសស្រឡាញ់ការសិក្សា ក៏មានខ្លះដែរ ខ្ញុំនឹងប្រព្រឹត្តព្រហ្មចារ្យ ក្នុងសំណាក់នៃសមណីទាំងឡាយនោះ ដូច្នេះឡើយ នែលោកម្ចាស់ ចូរលោកត្រេកអរ ព្រោះថា ធម៌ព្រះមានព្រះភាគសំដែងល្អហើយ ចូរលោកប្រព្រឹត្តព្រហ្មចារ្យដើម្បីធ្វើទីបំផុតនៃទុក្ខដោយប្រពៃចុះ ; ភិក្ខុនីនោះ កាលដែលភិក្ខុនីទាំងឡាយ

និយាយយ៉ាងនេះហើយ   ក៏នៅតែផ្គងឡើងដូចមុនដដែល   ភិក្ខុនីទាំង ឡាយ (សូត្រសមនុភាសនកម្ម) ហាមប្រាមភិក្ខុនីនោះ ជាគំរប់ ៣ ដង ដើម្បីឲ្យលះបង់នូវអំពើនោះចេញ បើហាមប្រាមគំរប់ ៣ ដងហើយលះ បង់អំពើនោះចេញ ការលះបង់ដូច្នេះនេះក៏ជាការគាប់ប្រសើរ បើមិនលះ បង់ទេ ភិក្ខុនីនេះក៏ត្រូវអាបត្តិសង្ឃាទិសេស ឈ្មោះយាវតតិយកៈ គួរដល់ការ បណ្តេញចេញចាកសង្ឃដែរ ។

ត្រង់ពាក្យថា ភិក្ខុនីទាំងឡាយត្រូវហាមប្រាមភិក្ខុនីនោះ គឺត្រូវហាម ប្រាមយ៉ាងនេះ ភិក្ខុនីអ្នកឈ្លាសប្រតិពល ត្រូវផ្តៀងភិក្ខុនីសង្ឃថា:

សុណាតុ មេ អយ្យេ សង្ឃោ អយំ (ឥត្ថន្នាមា) ភិក្ខុនី កុបិតា អនត្តមនា ឯវំ វទេតិ ពុទ្ធំ បច្ចាចិក្ខាមិ ធម្មំ បច្ចាចិក្ខាមិ សង្ឃំ បច្ចាចិក្ខាមិ សិក្ខំ បច្ចាចិក្ខាមិ កិន្នុមាវ សមណិយោ យា សមណិយោ សក្យធីតរោ សន្តញ្ញាបិ សមណិយោ លជ្ជិនិយោ កុក្កុច្ចិកា សិក្ខាកាមា តាសាហំ សន្តិកេ ព្រហ្មចរិយំ ចរិស្សាមីតិ សា តំ វត្ថុំ នប្បដិនិស្សជ្ជតិ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ (ឥត្ថន្នាមំ) ភិក្ខុនឹ សមនុភាសេយ្យ តស្ស វត្ថុស្ស បដិនិស្សគ្គាយ ឯសា ញត្តិ ។

សុណាតុ មេ អយ្យេ សង្ឃោ អយំ (ឥត្ថន្នាមា)

ភិក្ខុនី កុបិតា អនត្តមនា ឯវំ វទេតិ ពុទ្ធំ បច្ចាចិក្ខាមិ ធម្មំ បច្ចាចិក្ខាមិ សង្ឃំ បច្ចាចិក្ខាមិ សិក្ខំ បច្ចាចិក្ខាមិ កិន្នុមា វ សមណិយោ យា សមណិយោ សក្យធីតរោ សន្តញ្ញាបិ សមណិយោ លជ្ជិនិយោ កុក្កុច្ចិកា សិក្ខា-កាមា តាសាហំ សន្តិកេ ព្រហ្មចរិយំ ចរិស្សាមីតិ សា តំ វត្ថុំ នប្បដិនិស្សជ្ជតិ សង្ឃោ (ឥត្ថន្នាមំ) ភិក្ខុនឹ សមនុភាសតិ តស្ស វត្ថុស្ស បដិនិស្សគ្គាយ, យស្សា អយ្យាយ ខមតិ (ឥត្ថន្នាមាយ) ភិក្ខុនិយា សមនុ-ភាសនា តស្ស វត្ថុស្ស បដិនិស្សគ្គាយ សា តុណ្ហស្ស យស្សា នក្ខមតិ សា ភាសេយ្យ ។

ទុតិយម្បិ ឯតមត្ថំ វទាមិ ។ បេ ។

តតិយម្បិ ឯតមត្ថំ វទាមិ ។ បេ ។

សមនុភដ្ឋា សង្ឃេន (ឥត្ថន្នាមា) ភិក្ខុនី តស្ស វត្ថុស្ស បដិនិស្សគ្គាយ ខមតិ សង្ឃស្ស តស្មា តុណ្ហី ឯវមេតំ ធារយាមិ ។

“បពិត្រព្រះសង្ឃជាម្ចាស់ សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំ, ភិក្ខុនី (ឈ្មោះនេះ) នេះ ខឹងតូចចិត្ត និយាយយ៉ាងនេះថា ខ្ញុំសូមលាព្រះពុទ្ធ សូមលាព្រះធម៌ សូមលាព្រះសង្ឃ សូមលាសិក្ខា ភិក្ខុនីទាំងឡាយណា ជាសមណី

ជាធីតានៃព្រះពុទ្ធជាសក្យៈ ភិក្ខុនីទាំងឡាយនេះ នឹងហៅថា សមណី ដូចម្តេចបាន ? សមណីទាំងឡាយដទៃ ដែលមានសេចក្តីអៀនខ្មាស មានសេចក្តីរង្កៀស ស្រឡាញ់ការសិក្សា ក៏មានខ្លះដែរ ខ្ញុំនឹងប្រព្រឹត្តព្រហ្មចារ្យ ក្នុងសំណាក់នៃសមណីទាំងឡាយនោះ; ភិក្ខុនីនោះមិនលះបង់នូវរឿងនោះទេ បើសមនុភាសនកម្ម មានកាលដ៏សមគួរដល់សង្ឃហើយ សង្ឃគប្បីហាមប្រាមនូវភិក្ខុនី (ឈ្មោះនេះ) ដើម្បីឲ្យលះបង់នូវរឿងនោះ; នេះហៅថា ញត្តិ ។

បពិត្រព្រះសង្ឃជាម្ចាស់ សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំ ភិក្ខុនី (ឈ្មោះនេះ) នេះ ខឹងតូចចិត្ត និយាយយ៉ាងនេះថា ខ្ញុំសូមលាព្រះពុទ្ធ សូមលាព្រះធម៌ សូមលាព្រះសង្ឃ សូមលាសិក្ខា ភិក្ខុនីទាំងឡាយណាជាសមណីជាធីតានៃព្រះពុទ្ធជាសក្យៈ ភិក្ខុនីទាំងឡាយនេះនឹងហៅថា សមណី ដូចម្តេចបាន ? សមណីទាំងឡាយដទៃ ដែលមានសេចក្តីអៀនខ្មាស មានសេចក្តីរង្កៀស សឡាញ់ការសិក្សាក៏មានខ្លះដែរ ខ្ញុំនឹងប្រព្រឹត្តព្រហ្មចារ្យក្នុងសំណាក់នៃសមណីទាំងឡាយនោះ; ភិក្ខុនីនោះមិនលះបង់នូវរឿងនោះទេ (ឥឡូវ) សង្ឃហាមប្រាមនូវភិក្ខុនី (ឈ្មោះនេះ) ដើម្បីឲ លះបង់នូវរឿងនោះ, ការហាមប្រាមនូវភិក្ខុនី (ឈ្មោះនេះ) ដើម្បីឲ្យលះបង់នូវរឿងនោះ គាប់ចិត្តដល់លោកម្ចាស់អង្គណា លោកម្ចាស់អង្គនោះត្រូវស្ងៀម មិនគាប់ចិត្តដល់លោកម្ចាស់អង្គណា លោកម្ចាស់អង្គនោះត្រូវនិយាយឡើង ។

ខ្ញុំពោលនូវសេចក្ដីនេះ ជាគំរប់ពីរដងទៀត ។បេ។

ខ្ញុំពោលនូវសេចក្ដីនេះ ជាគំរប់បីដងទៀត ។បេ។

ភិក្ខុនី (ឈ្មោះនេះ) សង្ឃបានហាមប្រាមហើយ ដើម្បីឲ្យលះបង់នូវរឿងនោះ ការហាមប្រាមនោះគាប់ចិត្តដល់សង្ឃ ព្រោះហេតុនោះបានជាសង្ឃស្ងៀម, ខ្ញុំចាំទុកនូវរឿងនេះ ដោយអាការស្ងៀមយ៉ាងនេះ ។

៧- សិក្ខាបទ ទី ១១ មានសេចក្ដីថា កាលព្រះពុទ្ធជាបរមគ្រូទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី គ្រានោះចណ្ឌកាលីភិក្ខុនី ដែលភិក្ខុនីសង្ឃឲ្យទាញ ព្រោះអធិករណ៍ណាមួយហើយ ទឹងតូចចិត្ត ក៏និយាយយ៉ាងនេះថា ភិក្ខុនីទាំងឡាយ លុះលង់ដោយសេចក្ដីស្រឡាញ់ផង លុះលង់ដោយសេចក្ដីស្អប់ផង លុះលង់ដោយសេចក្ដីល្ងង់ផង លុះលង់ដោយសេចក្ដីខ្លាចផង ។ ពួកភិក្ខុនីដែលមានសេចក្ដីប្រាថ្នាតិច នាំគ្នាពិតទូលពួកភិក្ខុៗក៏នាំគ្នាក្រាបបង្គំទូលព្រះមានព្រះភាគ, ព្រះអង្គទ្រង់បញ្ញត្តសិក្ខាបទនេះឡើង ។ ឯសេចក្ដីក្នុងសិក្ខាបទនេះថា ភិក្ខុនីណាមួយ ដែលភិក្ខុនីសង្ឃឲ្យទាញ ព្រោះអធិករណ៍ណាមួយហើយ ទឹងតូចចិត្ត និយាយយ៉ាងនេះថា "ពួកភិក្ខុនីលុះលង់ដោយសេចក្ដីស្រឡាញ់ផង ដោយសេចក្ដីស្អប់ផង ដោយសេចក្ដីល្ងង់ផង ដោយសេចក្ដីខ្លាចផង" ភិក្ខុនីទាំងឡាយ ត្រូវនិយាយនឹងភិក្ខុនីនោះយ៉ាងនេះថា "នែលោកម្ចាស់ លោកម្ចាស់ដែលភិក្ខុនីសង្ឃឲ្យទាញ ព្រោះអធិករណ៍

ណាមួយហើយ ក៏ខឹងតូចចិត្តហើយនិយាយយ៉ាងនេះថា "ពួកភិក្ខុនីលុះលង់ដោយសេចក្ដីស្រឡាញ់ផង ដោយសេចក្ដីស្អប់ផង ដោយសេចក្ដីល្ងង់ផង ដោយសេចក្ដីខ្លាចផង" ដូច្នេះឡើយ លោកម្ចាស់ហ្នឹងឯងទេតើដែលលុះលង់ដោយសេចក្ដីស្រឡាញ់ផង ដោយសេចក្ដីស្អប់ផង ដោយសេចក្ដីល្ងង់ផង ដោយសេចក្ដីខ្លាចផង;" ភិក្ខុនីនោះកាលដែលភិក្ខុនីទាំងឡាយនិយាយយ៉ាងនេះហើយ ក៏នៅតែផ្គងឡើងដូចមុនដដែល ភិក្ខុនីទាំងឡាយត្រូវ(សូត្រសមនុភាសនកម្ម)ហាមប្រាមភិក្ខុនីនោះគំរប់ ៣ ដង ដើម្បីឲ្យលះបង់នូវអំពើនោះចេញ, កាលបើហាមប្រាមគំរប់៣ដងហើយ លះបង់នូវអំពើនោះចេញ ក៏ជាការគាប់ប្រសើរ បើមិនលះបង់ទេ ភិក្ខុនីនេះក៏ត្រូវអាបត្តិសង្ឃាទិសេសឈ្មោះយាវតតិយកៈ គួរដល់ការបណ្ដេញចេញចាកសង្ឃដែរ ។

៨ សិក្ខាបទទី ១២ មានសេចក្ដីថា កាលព្រះពុទ្ធជាបរមសា-ស្ដាទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី គ្រានោះភិក្ខុនីទាំងឡាយជាកូនសិស្សនៃថុល្លនន្ទាភិក្ខុនី ជាប់ច្រឡំដោយគ្រហស្ថ មានមារយាទអាក្រក់ មានកិត្តិសព្ទអាក្រក់ មានការចិញ្ចឹមជីវិតក៏អាក្រក់ ជាអ្នកបៀតបៀននូវភិក្ខុនីសង្ឃ បិទបាំងនូវទោសនៃភិក្ខុនីផងគ្នា។ ពួកភិក្ខុនីដែលមានសេចក្ដីប្រាថ្នាតិច នាំគ្នាពិតទូលពួកភិក្ខុៗក៏នាំគ្នាក្រាបបង្គំទូលព្រះមានព្រះភាគ, ព្រះអង្គទ្រង់បញ្ញត្តនូវសិក្ខាបទនេះឡើង ។ ឯ

សេចក្ដីក្នុងសិក្ខាបទនេះថា ភិក្ខុនីទាំងឡាយដែលជាប់ប្រឡំដោយគ្រហស្ថ មានមារយាទអាក្រក់ មានកិត្តិសព្ទអាក្រក់ មានការចិញ្ចឹមជីវិតអាក្រក់ ជាអ្នកបៀតបៀននូវភិក្ខុនីសង្ឃ បិទបាំងនូវទោសនៃភិក្ខុនីផងគ្នា; ពួកភិក្ខុនីឯទៀតត្រូវនិយាយនឹងពួកភិក្ខុនីនោះយ៉ាងនេះថា បងប្អូនទាំងឡាយជាអ្នកជាប់ប្រឡំដោយគ្រហស្ថ មានមារយាទអាក្រក់ មានកិត្តិសព្ទអាក្រក់ មានការចិញ្ចឹមជីវិតអាក្រក់ ជាអ្នកបៀតបៀននូវភិក្ខុនីសង្ឃ បិទបាំងនូវទោសនៃភិក្ខុនីផងគ្នា, នែលោកម្ចាស់ បូរលោកម្ចាស់ទាំងឡាយ ដោះដៃចេញអំពីការជាប់ប្រឡំដោយគ្រហស្ថ សង្ឃរមែងសរសើរនូវសេចក្ដីស្ងាត់របស់បងប្អូនទាំងឡាយ; ពួកភិក្ខុនីនោះ កាលដែលពួកភិក្ខុនីឯទៀតនិយាយយ៉ាងនេះហើយ ក៏នៅតែផ្គងឡើងដូចមុនដដែល ពួកភិក្ខុនីឯទៀតត្រូវ (សូត្រសមនុភាសនកម្ម) ហាមប្រាមពួកភិក្ខុនីនោះជាគំរប់ ៣ ដង ដើម្បីឲ្យលះបង់នូវអំពើនោះចេញ; កាលបើហាមប្រាមគំរប់ ៣ ដងហើយ លះបង់នូវអំពើនោះចេញ ក៏ជាការគាប់ប្រសើរ បើមិនលះបង់ទេ ភិក្ខុនីទាំងឡាយនេះ ក៏ត្រូវអាបត្តិសង្ឃាទិសេស ឈ្មោះយាវតតិយកៈ គួរដល់ការបណ្ដេញចេញចាកសង្ឃដែរ ។

៩- សិក្ខាបទទី ១៣ មានសេចក្ដីដំណាលថា កាលព្រះពុទ្ធជាបរមសាស្ដាទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី គ្រានោះ ថុល្លនន្ទាភិក្ខុនី និយាយនឹងពួកភិក្ខុនីដែលសង្ឃ

(បានសូត្រសមនុភាសនកម្ម)ហាមប្រាមហើយនោះ យ៉ាងនេះថា នែលោក
ម្ចាស់ លោកម្ចាស់ទាំងឡាយចូរជាអ្នកជាប់ច្រឡំដោយគ្រហស្ថចុះកុំបែក
ញែកអំពីគ្រហស្ថឡើយ ពួកភិក្ខុនីឯទៀត ដែលមានមារយាទយ៉ាងនេះ
មានកិត្តិសព្ទយ៉ាងនេះ មានការចិញ្ចឹមជីវិតយ៉ាងនេះ ជាអ្នកបៀតបៀននូវ
ភិក្ខុនីសង្ឃ បិទបាំងនូវទោសនៃភិក្ខុនីផងគ្នា ក៏មាននៅក្នុងសង្ឃដែរសង្ឃ
ឥតនិយាយអ្វីនឹងពួកភិក្ខុនីនោះទេ សង្ឃយកសេចក្តីមើលងាយផងអាការ
ពេបជ្រាយផង សេចក្តីមិនអត់ធន់ផង សំដីបង្គ្របផង សេចក្តីទន់ខ្សោយ
របស់លោកម្ចាស់ផង មកនិយាយនឹងលោកម្ចាស់ទាំងឡាយយ៉ាងនេះថា
"បងប្អូនទាំងឡាយជាអ្នកជាប់ច្រឡំដោយគ្រហស្ថ មានមារយាទអាក្រក់
មានកិត្តិសព្ទអាក្រក់ មានការចិញ្ចឹមជីវិតក៏អាក្រក់ជាអ្នកបៀតបៀននូវភិក្ខុនី
សង្ឃ បិទបាំងនូវទោសនៃភិក្ខុនីផងគ្នា នែលោកម្ចាស់ ចូរលោកម្ចាស់
ទាំងឡាយដោះដៃចេញអំពីការជាប់ច្រឡំដោយគ្រហស្ថ សង្ឃរមែងសរ-
សើរនូវសេចក្តីស្ងាត់របស់បងប្អូនទាំងឡាយ ៗ ពួកភិក្ខុនីដែលមានសេចក្តី
ប្រាថ្នាតិចនាំគ្នាពិតទូលពួកភិក្ខុ ។ ក៏នាំគ្នាក្រាបបង្គំទូលព្រះមានព្រះភាគ
ព្រះអង្គទ្រង់បញ្ញត្តសិក្ខាបទនេះឡើង ឯសេចក្តីក្នុងសិក្ខាបទនេះថា ភិក្ខុនី
ណាមួយនិយាយយ៉ាងនេះថា នែលោកម្ចាស់ លោកម្ចាស់ទាំងឡាយ ចូរ
ជាអ្នកជាប់ច្រឡំដោយគ្រហស្ថចុះ លោកម្ចាស់ទាំងឡាយកុំបែកញែកអំពី
គ្រហស្ថឡើយ ភិក្ខុនីទាំងឡាយឯទៀត ដែលមានមារយាទយ៉ាងនេះ

មានកិត្តិសព្ទយ៉ាងនេះ មានការចិញ្ចឹមជីវិតយ៉ាងនេះ ជាអ្នកបៀតបៀននូវភិក្ខុនីសង្ឃ បិទបាំងនូវទោសនៃភិក្ខុនីផងគ្នាក៏មាននៅក្នុងសង្ឃដែរ សង្ឃគ្មាននិយាយអ្វីនឹងពួកភិក្ខុនីនោះទេ សង្ឃយកសេចក្ដីមើលងាយផង អាការពេបជ្រាយផង សេចក្ដីមិនអត់ធន់ផង សំដីបគ្រើបផង សេចក្ដីទន់ខ្សោយរបស់លោកម្ចាស់ផង មកនិយាយនឹងលោកម្ចាស់ទាំងឡាយថា បងប្អូនទាំងឡាយជាអ្នកជាប់ច្រឡំដោយគ្រហស្ថ មានមារយាទអាក្រក់ មានកិត្តិសព្ទអាក្រក់ មានការចិញ្ចឹមជីវិតក៏អាក្រក់ ជាអ្នកបៀតបៀននូវភិក្ខុនីសង្ឃ បិទបាំងនូវទោសនៃភិក្ខុនីផងគ្នា នៃលោកម្ចាស់ លោកម្ចាស់ទាំងឡាយចូរដោះដៃចេញអំពីការជាប់ច្រឡំនោះ សង្ឃរមែងសរសើរនូវសេចក្ដីស្ងាត់របស់បងប្អូនទាំងឡាយ, ភិក្ខុនីទាំងឡាយត្រូវនិយាយនឹងភិក្ខុនីនោះយ៉ាងនេះថា នៃលោកម្ចាស់ លោកកុំនិយាយយ៉ាងនេះថា នៃលោកម្ចាស់ លោកម្ចាស់ទាំងឡាយចូរជាអ្នកជាប់ច្រឡំដោយគ្រហស្ថចុះ លោកម្ចាស់ទាំងឡាយកុំបែកខ្ញែកអំពីគ្រហស្ថឡើយ ពួកភិក្ខុនីឯទៀត ដែលមានមារយាទយ៉ាងនេះ មានកិត្តិសព្ទយ៉ាងនេះ មានការចិញ្ចឹមជីវិតយ៉ាងនេះ ជាអ្នកបៀតបៀននូវភិក្ខុនីសង្ឃ បិទបាំងនូវទោសនៃភិក្ខុនីផងគ្នា ក៏មាននៅក្នុងសង្ឃដែរ សង ឥតនិយាយអ្វីនឹងពួកភិក្ខុនីនោះទេ សង្ឃយកសេចក្ដីមើលងាយផង អាការពេបជ្រាយផង សេចក្ដីអត់ធន់ផង សំដីបគ្រើបផង សេចក្ដីទន់ខ្សោយរបស់លោកម្ចាស់ផង មកនិយាយនឹងលោកម្ចាស់ទាំងឡាយយ៉ាង

នេះថា បងប្អូនទាំងឡាយ ជាអ្នកជាប់ប្រឡំដោយគ្រហស្ថ មានមារយាទអាក្រក់ មានកិត្តិសព្ទអាក្រក់ មានការចិញ្ចឹមជីវិតក៏អាក្រក់ ជាអ្នកបៀតបៀននូវភិក្ខុនីសង្ឃ បិទបាំងនូវទោសនៃភិក្ខុនីផងគ្នា នៃលោកម្ចាស់ ចូរលោកម្ចាស់ទាំងឡាយ ដោះដៃចេញ អំពីការជាប់ប្រឡំដោយគ្រហស្ថ សង្ឃរមែងសរសើរនូវសេចក្តីស្ងាត់របស់បងប្អូនទាំងឡាយ, ភិក្ខុនីនោះកាលដែលភិក្ខុនីទាំងឡាយនិយាយយ៉ាងនេះ ក៏នៅតែផ្គងឡើងដូចមុនដដែល ភិក្ខុនីទាំងឡាយត្រូវ (សូត្រសមនុភាសនកម្ម) ហាមប្រាមភិក្ខុនីនោះគំរប់ ៣ ដង ដើម្បីឲ្យលះបង់នូវអំពើនោះចេញ, កាលបើហាមប្រាមគំរប់ ៣ ដងហើយ លះបង់នូវអំពើនោះចេញ ក៏ជាការគាប់ប្រសើរ បើមិនលះបង់ទេ ភិក្ខុនីនេះ ក៏ត្រូវអាបត្តិសង្ឃាទិសេស ឈ្មោះយាវតតិយកៈគួរដល់ការបណ្តេញចេញចាកសង្ឃដែរ ។

១០- សិក្ខាបទទី ៦ នៃតុវដ្តវគ្គ បាចិត្តិយកណ្ឌ ភិក្ខុនីវិភង្គ មានសេចក្តីដំណាលថា កាលព្រះពុទ្ធជាបរមគ្រូទ្រង់គង់នៅ ក្នុងវត្តជេតពនរបស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី គ្រានោះ ចណ្ឌកាលីភិក្ខុនីជាប់ប្រឡំដោយគ្រហស្ថ គឺគហបតីខ្លះ គហបតិបុត្រខ្លះ ។ ពួកភិក្ខុនីដែលមានសេចក្តីប្រាថ្នាតិច ក៏នាំគ្នាតិះទៀលពួកភិក្ខុ ៗ ក៏នាំគ្នាក្រាបបង្គំទូលព្រះមានព្រះភាគ ព្រះអង្គទ្រង់បញ្ញត្តសិក្ខាបទនេះឡើង ។ ឯសេចក្តីក្នុងសិក្ខាបទនេះថា ភិក្ខុនីណាមួយជាប់ប្រឡំដោយគ្រហស្ថ គឺគហបតីក្តី គហបតិបុត្រ

ក្តី ភិក្ខុនីទាំងឡាយត្រូវនិយាយនឹងភិក្ខុនីនោះយ៉ាងនេះថា នៃលោកម្ចាស់ លោកម្ចាស់កុំជាប់ច្រឡំដោយគ្រហស្ថ គឺ គហបតីខ្លះ គហបតិបុត្រខ្លះ ឡើយ នៃលោកម្ចាស់ លោកម្ចាស់ចូរដោះដៃចេញអំពីគ្រហស្ថ សង្ឃតែងសរសើរនូវសេចក្តីស្ងាត់របស់បងប្អូន, ភិក្ខុនីនោះ កាលដែលភិក្ខុនីទាំងឡាយនិយាយយ៉ាងនេះហើយ ក៏នៅតែផ្គងឡើងដូចមុនដដែល ភិក្ខុនីទាំងឡាយត្រូវ (សូត្រសមនុភាសនកម្ម) ហាមប្រាមភិក្ខុនីនោះគំរប់ ៣ ដង ដើម្បីឲ្យលះបង់នូវអំពើនោះចេញ. កាលបើហាមប្រាមគំរប់ ៣ ដង ហើយលះនូវបង់អំពើនោះចេញ ក៏ជាការគាប់ប្រសើរ បើមិនលះបង់ទេ ត្រូវអាបត្តិបាចិត្តិយៈ ។

១១- ឧក្ខិត្តានុវត្តិកាសិក្ខាបទ ជាសិក្ខាបទទី៣នៃបារាជិកកណ្ឌ ភិក្ខុនីវិភង្គ បើរាប់តាមភិក្ខុនីបាតិមោក្ខវិញ ត្រូវនៅជាសិក្ខាបទទី៧មាន សេចក្តីថា ភិក្ខុនីណាមួយប្រព្រឹត្តតាមភិក្ខុដែលសង្ឃព្រមព្រៀងគ្នាលើកវត្ត តាមធម៌តាមវិន័យ តាមពាក្យប្រៀនប្រដៅរបស់ព្រះសាស្តា ជាភិក្ខុមិនអើពើ ជាភិក្ខុដែលសង្ឃជួយជ្រោមជ្រែងមិនបាន ជាភិក្ខុមិនមានការរួបរួមជាមួយនឹងសង្ឃ ភិក្ខុនីនោះ ត្រូវភិក្ខុនីទាំងឡាយនិយាយយ៉ាងនេះថា នៃលោកម្ចាស់ ភិក្ខុនេះឯងដែលសង្ឃព្រមព្រៀងគ្នាលើកវត្ត តាមធម៌តាមវិន័យ តាមពាក្យប្រៀនប្រដៅរបស់ព្រះសាស្តា ជាភិក្ខុមិនអើពើ ជាភិក្ខុដែលសង្ឃជួយជ្រោមជ្រែងមិនបាន ជាភិក្ខុមិនមានការរួបរួមជាមួយនឹង

សង្ឃ នៃលោកម្ចាស់ លោកកុំប្រព្រឹត្តតាមភិក្ខុនេះឡើយ ភិក្ខុនីនោះកាលដែលភិក្ខុនីទាំងឡាយនិយាយឲ្យយ៉ាងនេះ នៅតែប្រកាន់យ៉ាងនោះដដែល ភិក្ខុនីនោះ ត្រូវភិក្ខុនីទាំងឡាយសូត្រសមនុភាសនកម្មជាគំរប់ ៣ ដង ដើម្បីឲ្យលះបង់វត្ថុនោះ បើភិក្ខុនីនោះ កាលត្រូវភិក្ខុនីទាំងឡាយសូត្រសមនុភាសនកម្មជាគំរប់ ៣ ដង លះបង់វត្ថុនោះបាន ការលះបង់បាននោះជាការល្អ - បើមិនលះបង់ទេ ភិក្ខុនីនេះ ក៏ត្រូវបារាជិកឈ្មោះឧក្ខិត្តានុវត្តិកៈ (ព្រោះប្រព្រឹត្តតាមភិក្ខុដែលសង្ឃលើកវត្ត) ជាស្ត្រីមិនមានសំវាស ។

ការហាមប្រាម គឺសូត្រសមនុភាសនកម្ម ដោយញត្តិចតុត្ថកម្មវាចា ដែលមានក្នុងសិក្ខាបទទាំង ១១ ដូចបាននិយាយមក ដោយសង្ខេបនេះ ហៅថា សមនុភាសនា ក្នុងញត្តិចតុត្ថកម្មកថានេះ ។

កម្មលក្ខណៈ ក្នុងទីនេះសំដៅយក ឧបសម្បទាកម្ម១ អព្ភានកម្ម១ ។

ឧបសម្បទាតិ ឧបរិភាវំ ភិក្ខុភាវំ សម្បាបនតា

ការញុំាងកុលបុត្រឲ្យដល់ព្រមនូវគុណធម៌ដ៏ខ្ពង់ខ្ពស់ គឺភិក្ខុភាវៈ ហៅថា ឧបសម្បទា ។ សេចក្តីថា ការបំបួសនូវកុលបុត្រឲ្យបានតេទនឹងគុណ-ធម៌ជាភិក្ខុ ហៅថា ឧបសម្បទាកម្ម ដែលសង្ឃត្រូវធ្វើដោយឧបសម្បទា នោះ ហៅថា ឧបសម្បទាកម្ម ។ នោះមានក្នុងមហាខន្ធកៈ ។

មានសេចក្តីដំណាលក្នុងពុទ្ធប្បវត្តិថា ក្នុងថ្ងៃពុធ១៥កើតខែពិសាខ

ឆ្នាំរកា វេលាព្រឹកព្រហាម ព្រះសិទ្ធត្ថគោតម ទ្រង់ទទួលមធុបាយាសរបស់នាងសុជាតា ក្រោមដើមជ្រៃ ទ្រង់សោយហើយបណ្តែតភាជន៍ មាសទៅក្នុងស្ទឹងនេរញ្ជរា ទ្រង់គង់សម្រាកសម្រួលព្រះអង្គ ក្នុងវេលាថ្ងៃដោយនានាសមាបត្តិ ក្នុងដងព្រៃធំក្បែរឆ្នេរស្ទឹងនេរញ្ជរានោះ វេលាថ្ងៃរសៀល ព្រះអង្គបានស្មៅស្ពា ៨ ក្តាប់អំពីសោត្ថិយព្រាហ្មណ៍ ទ្រង់ស្តេចទៅកាន់ពោធិព្រឹក្ស ទ្រង់ចាប់ត្រង់គល់ស្មៅស្ពា រលាស់ស្មៅស្ពានោះ ក៏ស្រាប់តែមានបល្ល័ង្កផុសឡើងកំពស់ ១៤ ហត្ថ អំពីទិសខាងកើតពោធិព្រឹក្ស, ជិតពោធិព្រឹក្ស ព្រះអង្គយកស្មៅស្ពាក្រាលលើបល្ល័ង្ក ទ្រង់គង់លើកម្រាលស្មៅនោះ បែរព្រះភក្ត្រចំទៅទិសខាងកើត វេលាព្រះអាទិត្យ មិនទាន់អស្តង្គត ព្រះអង្គផ្ចាញ់មារព្រមទាំងសេនារបស់មារ; វេលាបឋមយាមនៃរាត្រី ព្រះអង្គបាននូវបុព្វេនិវាសញ្ញាណ, វេលាមជ្ឈិមយាម ព្រះអង្គបាននូវចុតូបបាតញ្ញាណ, វេលាបច្ឆិមយាម ព្រះអង្គពិចារណានូវបច្ចយាការ គឺបដិច្ចសមុប្បាទធម៌, វេលាអរុណរះ ព្រះអង្គអស់អាសវៈ បាននូវសព្វញ្ញុតញ្ញាណ ត្រាស់ដឹង ជាព្រះសព្វញ្ញុពុទ្ធ ពេញទីស្មើពេលភ្លឺនឹងអរុណនោះ ។

ថ្ងៃព្រហស្បតិ៍ ១ រោច ១៤ ពិសាខ ព្រះអង្គគង់លើរតនបល្ល័ង្កនោះ ទ្រង់សោយវិមុត្តិសុខ រហូតដល់មកថ្ងៃពុធ ៧ រោច ត្រូវជា ៧ ថ្ងៃ ។

ថ្ងៃព្រហស្បតិ៍ ៨ រោច ព្រះអង្គស្តេចចុះអំពីរតនបល្ល័ង្កនោះ ទ្រង់ស្តេច

ទៅទិសឦសាននៃពោធិព្រឹក្ស ទ្រង់ប្រថាប់ឈរបើកព្រះភ័ក្ត្រទៅរករតន-បល្ល័ង្ក ទ្រង់ទតមើលបល្ល័ង្កមិនប៉ព្រិចព្រះនេត្រហូតដល់មកថ្ងៃពុធ ១៤ រោច ត្រូវជា ៧ ថ្ងៃទៀត ទីកន្លែងនោះហៅថា អនិម្មិលចេតិយ[(១)] ។

ថ្ងៃព្រហស្បតិ៍ ១៥ រោច ព្រះអង្គនិម្មិតទីចង្ក្រម១ត្រង់ទីជាចន្លោះនៃរតនបល្ល័ង្កនឹងអនិម្មិលចេតិយ ទីចង្ក្រមនោះវែងបណ្ដោយថ្ងៃ ព្រះអង្គទ្រង់ចង្ក្រមក្នុងទីនោះហូតដល់មកថ្ងៃពុធ ៦ កើតខែជេស្ឋ ត្រូវជា ៧ ថ្ងៃម្ដងទៀត ទីកន្លែងនោះហៅថា រតនចង្ក្រមចេតិយ ។

ថ្ងៃព្រហស្បតិ៍ ៧ កើតខែជេស្ឋ មានពួកទេវតាមកនិម្មិតរតនឃរៈ (រោងកែវ) ថ្វាយព្រះអង្គ ត្រង់ទិសពាយ័ព្យស្ដើរខាងជើងនៃពោធិព្រឹក្សចំពីខាងទិសពាយ័ព្យនៃរតនចង្ក្រម ព្រះអង្គគង់ក្នុងទីនោះ ពិចារណានូវព្រះអភិធម្ម ហូតដល់មកថ្ងៃពុធ ១៣ កើត ទីកន្លែងនោះហៅថា រតន-ឃរចេតិយ ។ ថ្ងៃព្រហស្បតិ៍ ១៤ កើត ព្រះអង្គស្ដេចអំពីរតនឃរចេតិយ ទ្រង់ឆ្លងស្ទឹងនេរញ្ជរា ឆ្ពោះទៅកាន់ដើមអជបាលនិគ្រោធ នាទិសខាងកើតនៃពោធិព្រឹក្ស ខាងភូមិភាគនៃសេនានិគម ទ្រង់សោយវិមុត្តិសុខ ហូតដល់មកថ្ងៃពុធ ៥ រោច ត្រូវជា ៧ ថ្ងៃ ។

ថ្ងៃព្រហស្បតិ៍ ៦ រោច ព្រះអង្គស្ដេចអំពីអជបាលនិគ្រោធ ឆ្លងស្ទឹងនេរញ្ជរាត្រឡប់មកកាន់មុចលិន្ទស្រះ ត្រង់ទិសអាគ្នេយ៍នៃពោធិព្រឹក្ស ។

---

១- ធ្លាប់ដឹងមកថា អនិមិសចេតិយ តែពិនិត្យទៅឃើញថាមិនត្រូវ ។

សម័យនោះ មានភ្លៀងខ្យល់តាំងថ្ងៃតាំងយប់ គ្រប់តាំង ៧ ថ្ងៃនោះ មាននាគរាជ ១ ឈ្មោះមុចលិន្ទ ជ្រះថ្លាស្រឡាញ់ព្រះអង្គពេក បើកពពារបាំងពីលើព្រះអង្គមិនឲ្យភ្លៀងធ្លាក់ត្រូវ យកខ្លួនពេនព័ទ្ធព្រះអង្គ ៧ ជុំ ការពារមិនឲ្យភ្លៀងខ្យល់ត្រូវព្រះអង្គ, មានដើមមុចលិន្ទ គឺដើមរាំងអន្ទក់ នៅក្បែរស្រះនោះ ព្រះអង្គគង់ក្រោមដើមរាំងនោះ ដោយហេតុនេះ ស្រះនឹងនាគរាជនោះ គេសន្មតហៅតាមដើមរាំងនោះថា មុចលិន្ទ, ព្រះអង្គទ្រង់សោយវិមុត្តិសុខក្នុងទីនោះ រហូតដល់ថ្ងៃពុធ ១២ កើត ត្រូវជា ៧ ថ្ងៃ ។

ថ្ងៃព្រហស្បតិ៍ ១៣ កើត ព្រះអង្គស្តេចចេញអំពីមុចលិន្ទស្រះ ទៅកាន់រាជាយតនព្រឹក្ស គឺដើមកែស នាទិសខាងត្បូង នៃពោធិព្រឹក្ស ព្រះអង្គគង់ក្រោមដើមកែសនោះ ទ្រង់សោយវិមុត្តិសុខ រហូតមកដល់ថ្ងៃពុធ ៥ កើតខែអាសាឍ ត្រូវជា ៧ ថ្ងៃ ។ លំដាប់នោះព្រះឥន្ទ្រាធិរាជទ្រង់នាំយកផ្លែសម៉ ជាថ្នាំបញ្ចុះមកថ្វាយព្រះអង្គ ១ ទ្រង់សោយផ្លែសម៉នោះ ទើបទ្រង់មានសរីរវលញ្ជៈ, លំដាប់នោះព្រះឥន្ទ្រយកឈើស្ទន់វល្លិមព្រៃនឹងទឹកសម្រាប់ស្រពព្រះភ័ក្ត្រ លាងជំរះព្រះទន្តអំពីអនោតត្តស្រះមកថ្វាយ, ព្រះសាស្តាទ្រង់ប្រើប្រាស់ឈើស្ទន់ ទ្រង់ស្រពព្រះភ័ក្ត្រជំរះព្រះទន្តដោយទឹកអនោតត្តស្រះ ទ្រង់គង់ក្រោមដើម កសនោះដដែល ។

សម័យនោះនាយឈ្មួញពីរនាក់ ឈ្មោះតបុស្ស ១ ភល្លិក ១ ជាបងប្អូនបង្កើតនឹងគ្នា នាំគ្នាបររទេះ ៥០០ អំពីឧក្កលជនបទទៅកាន់មជ្ឈិម

ប្រទេស ដល់ទៅជិតដើមកែសនោះ មានទេវតាជាញាតិសាលោហិតរបស់ខ្លួនខ្ចប់រទេះមិនឲ្យបរទៅរួច នាយឈ្មួញទាំងពីរនាក់គិតភ័យក្រែងមានអន្តរាយអ្វីដល់ខ្លួន ក៏បន់ស្រន់អស់ទេវតាដែលនៅតាមផ្លូវ, ទើបទេវតានោះនិម្មិតឲ្យឃើញខ្លួនប្រាកដហើយនិយាយប្រាប់ថា ព្រះពុទ្ធទើបបានត្រាស់ថ្មីៗ គង់ក្រោមដើមកែសឯណោះ បើមានវត្ថុអ្វីរួចយកទៅថ្វាយព្រះអង្គសោយផង ៗ ទើបតបុស្សនឹងភល្លិកនាំយកសត្តុវផង់នឹងសត្តុវដុំទៅថ្វាយព្រះអង្គ ៗ បាត្រដែលឃដិការមហាព្រហ្មថ្វាយក្នុងកាលដែលទ្រង់ព្រះផ្នួសនោះ ក៏បាត់ទៅតាំងពីពេលដែលទទួលមធុបា-យាសរបស់នាងសុជាតា, ហេតុនោះព្រះអង្គទ្រង់រំពឹងថា ព្រះតថាគតទាំងឡាយមិនដែលទទួលរបស់អ្វីដោយដៃឡើយ ហេតុនេះ តថាគតបានអ្វីទទួលហ្ន៎? លំដាប់នោះលោកបាលមហារាជទាំង ៤ អង្គបានជ្រាបព្រះទ័យហើយក៏នាំយកបាត្រកែវឥន្ទនិល ៤ មកថ្វាយព្រះអង្គ ៗ មិនទទួលព្រោះកែវនោះល្អពេកមិនសមគួរដល់សមណៈ មហារាជទាំងនោះក៏យកបាត្រថ្ម ៤ មានសម្បុរដូចគ្រាប់សណ្តែកបាយមកថ្វាយទៀត ទើបព្រះអង្គទទួលយកបាត្រទាំង ៤ ដោយអនុគ្រោះដល់មហារាជទាំង ៤ អង្គយកមកតម្រួតលើគ្នាទាំង ៤ អធិដ្ឋានឲ្យរលាយចូលគ្នាតែ ១ ហើយទទួលសត្តុវផង់នឹងសត្តុវដុំ ទ្រង់សោយហើយធ្វើអនុមោទនា ៗ នាយឈ្មួញទាំងពីរនាក់បានដល់នូវព្រះពុទ្ធនឹងព្រះធម៌ជាទីពឹង បានជា ទ្វេវា

ឋិតទុបាសក[១] ។ នាយឈ្មួញទាំងពីរនាក់ក្រាបទូលថា សូមព្រះអង្គទ្រង់ប្រោសប្រទាននូវរបស់អ្វីមួយដែលជាទីគោរពបូជា ដល់យើងខ្ញុំព្រះអង្គ ។ ព្រះសម្ពុទ្ធយកព្រះហស្តខាងស្តាំស្ទាបអង្អែលព្រះសិរ្ស បានព្រះកេសធាតុ ៨ សរសៃ ប្រទានដល់នាយឈ្មួញទាំងពីរនាក់ៗ ក៏យកទៅធ្វើព្រះចេតិយ តំកល់ទុកគោរពបូជា ក្នុងនគររបស់ខ្លួន ។ ឯទីដែលទ្រង់គង់ក្រោមដើមកេសនោះ ហៅថា រាជាយតនចេតិយ ។

ថ្ងៃព្រហស្បតិ៍ ៦ កើតខែអាសាឍ ព្រះអង្គស្តេចចេញអំពីរាជាយតនព្រឹក្សក្នុងស្ទឹងនេរញ្ជរាទៅកាន់អជបាលនិគ្រោធវិញ ទ្រង់ពិចារណាឃើញថាធម៌ដែលព្រះអង្គត្រាស់ដឹងនោះ ជ្រាលជ្រៅពេកណាស់ ល្អិតពេកណាស់ ពួកសត្វដែលប្រកបដោយកិលេសក្រាស់មិនអាចនឹងយល់បានទេ បើនឹងសំដែងទៅ គេមិនដឹង នាំឲ្យនឿយកាយនឿយវាចា. ហេតុនោះព្រះទ័យព្រះអង្គបង្អោនទៅដើម្បីសេចក្តីខ្វល់ខ្វាយតិច មិនបង្អោនទៅ ដើម្បីសំដែងធម៌ឡើយ[២] ។ គ្រានោះសហម្បតីព្រហ្ម មានមហាព្រហ្ម ១ ម៉ឺនជាបរិវារ នាំគ្នាចុះមកអំពីព្រហ្មលោកភ្លាម ១ រំពេចលុតជង្គង់ខាងស្តាំលើផែនដីលើកដៃប្រណម្យបង្គំអារាធនា សូមឲ្យព្រះអង្គសំដែងធម៌ប្រោសសត្វ ព្រោះពួកសត្វដែលមានកិលេសតិចក៏មានខ្លះដែរ បើមិនបានស្តាប់ធម៌ទេ រមែង

១ ព្រោះបានដល់ត្រឹមទ្វេវាចិកសរណគមន៍ គឺព្រះពុទ្ធនឹងព្រះធម៌ជាទីពឹង ដ្បិតពុំទាន់មានព្រះសង្ឃនៅឡើយ ។ ២ ក្នុងទីនោះ ទេវបុត្តមារមានចិត្តទោមនស្ស ជាខ្លាំង, មារធីតាទាំងបីព្រាណាបានយកអាសា មកប្រលោមព្រះបរមសាស្តាក្នុងទីនេះ ប៉ុន្តែពុំកើតការ ។

សាបសូន្យ បើបានស្តាប់ធម៌និងបានត្រាស់ដឹងមគ្គផលពុំខាន ។ ព្រះអង្គក៏ទទួលអារាធនា នៃសហម្បតីព្រហ្មដើម្បីសំដែងធម៌ ។

ព្រះសម្ពុទ្ធគង់ក្រោមដើមអជបាលនិគ្រោធ ៧ ថ្ងៃទៀត គិតតាំងអំពីថ្ងៃ ៦ កើតទៅដល់ថ្ងៃពុធ ១២ កើត ខែអាសាឍ, រួមទាំងអស់ឃើញថា ទ្រង់គង់ក្នុងពោធិមណ្ឌប្រទេស (សត្តមហាឋាន) បាន ៥៦ ថ្ងៃ ប៉ុន្តែសង្កេតទៅឃើញថា ថ្ងៃព្រហស្បតិ៍ ១៣ កើត ខែអាសាឍ ក៏គង់នៅក្នុងពោធិមណ្ឌប្រទេសនោះដែរ បើរាប់យកថ្ងៃ ១៣ កើតបញ្ចូលមកផងត្រូវជា ៥៧ ថ្ងៃ ។

ថ្ងៃសុក្រ ១៤ កើត ខែអាសាឍ ព្រះអង្គចេញអំពីពោធិមណ្ឌប្រទេសស្តេចទៅកាន់ទីក្រុងពារាណសី ដើម្បីជួបនឹងបញ្ចវគ្គិយភិក្ខុទាំង ៥ អង្គ ដែលមានឧបការៈច្រើនចំពោះព្រះអង្គ, ចម្ងាយផ្លូវ ១៨ យោជន៍, ទ្រង់ស្តេចទៅដល់ឥសិបតនមិគទាយវ័ន ទៀបក្រុងពារាណសីក្នុងថ្ងៃសៅរ៍ ១៥កើតខែអាសាឍ បានជួបនឹងបញ្ចវគ្គិយភិក្ខុទាំង ៥ គឺ កោណ្ឌញ្ញៈ១ វប្បៈ ១ ភទ្ទិយៈ ១ មហានាម ១ អស្សជិ ១ ទ្រង់សំដែងធម្មចក្កប្បវត្តនសូត្រ, លុះសំដែងចប់ហើយ កោណ្ឌញ្ញភិក្ខុ(១) បានសម្រេច

---

១– នាមដើមត្រឹមតែ កោណ្ឌញ្ញ ប៉ុណ្ណោះ កាលដែលចប់ធម្មចក្កប្បវត្តនសូត្រ កោណ្ឌញ្ញៈបានសម្រេចសោតាបត្តិផលហើយព្រះបរមសាស្តា ទ្រង់បន្លឺឧទានវាចាឮខ្លាំង ៗ ថា "អញ្ញាសិ វត ភោ កោណ្ឌញ្ញោ ៗ ! (ឱ! កោណ្ឌញ្ញ បានដឹងធម៌ហើយ ៗ !)" ដោយហេតុនេះ កោណ្ឌញ្ញៈ ក៏បាននាមប្រាកដថា អញ្ញាកោណ្ឌញ្ញ រៀងរហូតមក ដោយយកពាក្យអញ្ញាសិ ដែលនៅត្រឹមតែ អញ្ញា មកភ្ជាប់នឹងកោណ្ឌញ្ញ ។

សោតាបត្តិផលជាមួយនឹងព្រហ្ម ១៨ កោដិ បានជាឯហិភិក្ខុឧបសម្បទាក្នុងថ្ងៃ ១៤ កើតនោះ ។

ថ្ងៃអាទិត្យ ១ រោច វប្បភិក្ខុ បានសម្រេចសោតាបត្តិផល បានជាឯហិភិក្ខុឧបសម្បទា ។

ថ្ងៃចន្ទ ២ រោច ភទ្ទិយភិក្ខុ បានសម្រេចសោតាបត្តិផល បានជាឯហិភិក្ខុឧបសម្បទា ។

ថ្ងៃអង្គារ ៣ រោច មហានាមភិក្ខុ បានសម្រេចសោតាបត្តិផល បានជាឯហិភិក្ខុឧបសម្បទា ។

ថ្ងៃពុធ ៤ រោច អស្សជិភិក្ខុ បានសម្រេចសោតាបត្តិផល បានជាឯហិភិក្ខុឧបសម្បទា ។

ថ្ងៃព្រហស្បតិ៍ ៥ រោច ព្រះអង្គសំដែងអនត្តលក្ខណសូត្រ, បញ្ចវគ្គិយភិក្ខុ បានស្តាប់ហើយបានសម្រេចអរហត្តផលគ្រប់ទាំង ៥ អង្គ ហេតុនោះព្រះអរហន្ត ៦ អង្គ (ទាំងព្រះបរមសាស្តា) កើតមានក្នុងលោកក្នុងថ្ងៃព្រហស្បតិ៍៥ រោច ខែអាសាឍ ឆ្នាំរកា ។ តពីនោះមក ព្រះអង្គបំបួសយសកុលបុត្រ ព្រមទាំងសំឡាញ់របស់យសកុលបុត្រចំនួន ៥៤ នាក់ទៀត ឲ្យបានឯហិភិក្ខុឧបសម្បទា ព្រមទាំងបានសម្រេចអរហត្តផល បានជាព្រះអរហន្តក្នុងព្រះពុទ្ធសាសនា ។ ក្នុងវស្សានោះ មានព្រះអរហន្ត ៦០ អង្គ ជា ៦១ ទាំងព្រះសម្មាសម្ពុទ្ធផង កើតឡើងហើយក្នុងលោក ។ លុះចេញវស្សា

បវារណារួចហើយ ព្រះអង្គបញ្ជូនព្រះអរហន្តទាំង ៦០ អង្គឲ្យចេញទៅ
ប្រកាសសាសនាក្នុងប្រទេសផ្សេង ៗ ៗ ព្រះអរហន្តទាំងនោះបាននាំ
បព្វជ្ជាបេក្ខខ្លះ ឧបសម្បទាបេក្ខខ្លះ អំពីទិសផ្សេងៗ ពីជនបទផ្សេងៗ មក
កាន់សំណាក់ព្រះមានព្រះភាគ ព្រះអង្គក៏បំបួសបុគ្គលនោះៗតាមលំដាប់
មក ទើបព្រះអង្គឈ្វេងយល់ថា នាំឲ្យលំបាកដល់ពួកភិក្ខុផង ពួកបព្វជ្ជា-
បេក្ខផង ពួកឧបសម្បទាបេក្ខផង ទើបទ្រង់អនុញ្ញាតឲ្យពួកភិក្ខុបំបួសកុល
បុត្របាន មុនដំបូងឲ្យកោរសក់នឹងពុកមាត់ពុកចង្កាចេញហើយឲ្យស្លៀក
ដណ្ដប់សំពត់កាសាយៈ ឲ្យធ្វើឧត្តរាសង្គៈឆៀងស្មាម្ខាង ឲ្យថ្វាយបង្គំបាទា
នៃភិក្ខុទាំងឡាយ ឲ្យអង្គុយច្រហោងផ្គងអញ្ជលីឡើង ឲ្យថាតាមដូច្នេះថា
ពុទ្ធំ សរណំ គច្ឆាមិ, ធម្មំ សរណំ គច្ឆាមិ, សង្ឃំ សរណំ
គច្ឆាមិ; ទុតិយម្បិ ពុទ្ធំ សរណំ គច្ឆាមិ, ទុតិយម្បិ ធម្មំ
សរណំ គច្ឆាមិ, ទុតិយម្បិ សង្ឃំ សរណំ គច្ឆាមិ; តតិ-
យម្បិ ពុទ្ធំ សរណំ គច្ឆាមិ, តតិយម្បិ ធម្មំ សរណំ គច្ឆាមិ,
តតិយម្បិ សង្ឃំ សរណំ គច្ឆាមិ ខ្ញុំព្រះករុណាសូមដល់នូវព្រះពុទ្ធ
ជាទីរលឹក សូមដល់នូវព្រះធម៌ជាទីរលឹក សូមដល់នូវព្រះសង្ឃជាទីរលឹក;
សូមដល់នូវព្រះពុទ្ធជាទីរលឹក ជាគំរប់ពីរដងទៀត, សូមដល់នូវព្រះធម៌ជាទី
រលឹកជាគំរប់ពីរដងទៀត, សូមដល់នូវព្រះសង្ឃជាទីរលឹក ជាគំរប់ពីរដង
ទៀត; សូមដល់នូវព្រះពុទ្ធជាទីរលឹក ជាគំរប់បីដងទៀត, សូមដល់នូវព្រះធម៌

ជាទីរលឹកជាគំរប់បីដងទៀត, សូមដល់នូវព្រះសង្ឃជាទីរលឹក ជាគំរប់បីដង
ទៀត; ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតនូវបព្វជានិងឧបសម្បទា
ដោយសរណគមន៍ទាំង៣ នេះឯង ។ តាំងពីថ្ងៃនោះមក ពួកភិក្ខុបំបួសកុល-
បុត្រឲ្យជាសាមណេរក្តី ជាភិក្ខុក្តី ដោយត្រៃសរណគមន៍ តាមពុទ្ធានុញ្ញាត
នោះឯង ឯព្រះមានព្រះភាគ ទ្រង់បំបួសដោយឯហិភិក្ខុឧបសម្បទា ។ ភិក្ខុ
សង្ឃក្នុងព្រះពុទ្ធសាសនា ក៏កាន់តែចំរើនច្រើនឡើង ។ សម័យមួយនោះ
មានព្រាហ្មណ៍ម្នាក់ឈ្មោះរាធៈ មានបំណងចង់បួស គឺសូមផ្នួសក្នុងសំណាក់
ភិក្ខុទាំងឡាយ ឥតមានភិក្ខុណាទទួលការៈបំបួសរាធព្រាហ្មណ៍នោះ ។ ក៏
កើតទុក្ខស្គាំងស្គមសៅហ្មង ឡើងសរសៃរព័មពេញខ្លួន ។ ព្រះមានព្រះ
ភាគទ្រង់ជ្រាបហេតុនោះសព្វគ្រប់ហើយ ទ្រង់មានព្រះបន្ទូលថា ម្នាលភិក្ខុ
ទាំងឡាយ មានភិក្ខុណាមួយនឹកឃើញអធិការគុណរបស់រាធព្រាហ្មណ៍ខ្លះ
ដែរឬទេ? ព្រះសារីបុត្រក្រាបទូលថា ខ្ញុំព្រះអង្គនឹកឃើញអធិការគុណរបស់
រាធព្រាហ្មណ៍នោះ កាលដែលខ្ញុំព្រះអង្គត្រាច់ចរទៅបិណ្ឌបាតក្នុងក្រុងរាជ-
គ្រឹះ រាធព្រាហ្មណ៍នោះបានប្រគេន បង្ហាន់ ១ វែកដល់ខ្ញុំព្រះអង្គ ។ ព្រះ
អង្គទ្រង់សរសើរព្រះសារីបុត្រថា ជាអ្នកកតញ្ញកតវេទី ហើយទ្រង់បង្គាប់
ឲ្យព្រះសារីបុត្របំបួសរាធព្រាហ្មណ៍នោះ ទ្រង់អនុញ្ញាតថា យា សា
ភិក្ខវេ តីហិ សរណគមនេហិ ឧបសម្បទា អនុញ្ញាតា
តាហំ អជ្ជតគ្គេ បដិក្ខិបាមិ អនុជានាមិ ភិក្ខវេ ញត្តិ-

ចតុត្ថេន កម្មេន ឧបសម្បទំ “ម្នាលភិក្ខុទាំងឡាយ ឧបសម្បទា ណា ដែលតថាគតបានអនុញ្ញាតហើយ ដោយត្រៃសរណគមន៍នោះ ចាប់តាំងពីថ្ងៃនេះតទៅ តថាគតបញ្ឈប់នូវឧបសម្បទានោះ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតនូវឧបសម្បទា ដោយញត្តិចតុត្ថកម្ម” ។ ត្រូវឲ្យឧបសម្បទាយ៉ាងនេះ ៖

ភិក្ខុអ្នកឈ្លាស ប្រតិពល ត្រូវផ្ទៀងសង្ឃថា

សុណាតុ មេ ភន្តេ សង្ឃោ អយំ (ឥត្ថន្នាមោ[1]) (ឥត្ថន្នាមស្ស[2]) អាយស្មតោ ឧបសម្បទាបេក្ខោ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ (ឥត្ថន្នាមំ) ឧបសម្បាទេយ្យ (ឥត្ថន្នាមេន) ឧបជ្ឈាយេន ឯសា ញត្តិ ។

សុណាតុ មេ ភន្តេ សង្ឃោ អយំ (ឥត្ថន្នាមោ)(ឥត្ថន្នាមស្ស) អាយស្មតោ ឧបសម្បទាបេក្ខោ សង្ឃោ (ឥត្ថន្នាមំ) ឧបសម្បាទេតិ (ឥត្ថន្នាមេន) ឧបជ្ឈាយេន យស្សាយស្មតោ ខមតិ (ឥត្ថន្នាមស្ស) ឧបសម្បទា (ឥត្ថន្នាមេន) ឧបជ្ឈាយេន សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។

---

១-២- ត្រូវបញ្ចូលនាមឧបសម្បទាបេក្ខៈ និងនាមឧបជ្ឈាយ៍ ដូចនាមថា នាគោ តិស្សស្ស, ពុទ្ធរក្ខិតោ ធម្មរក្ខិតស្ស ជាដើម ។

ទុតិយម្បិ ឯតមត្ថំ វទាមិ ។បេ។

តតិយម្បិ ឯតមត្ថំ វទាមិ ។បេ ។

ឧបសម្បន្នោ សង្ឃេន (ឥត្ថន្នាមោ) (ឥត្ថន្នាមេន) ឧបជ្ឈាយេន ខមតិ សង្ឃស្ស តស្មា តុណ្ហី ឯវមេតំ ធារយាមិ ។

"បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំ, បុគ្គល (ឈ្មោះនេះ) នេះ ជាឧបសម្បទាបេក្ខរបស់ព្រះថេរៈអ្នកមានអាយុ (ឈ្មោះនេះ), បើឧបសម្បទាកម្ម មានកាលដ៏សមគួរដល់សង្ឃហើយ សង្ឃគប្បីញ៉ាំងបុគ្គល( ឈ្មោះនេះ ) ឲ្យដល់ព្រមនូវគុណធម៌ដ៏ខ្ពង់ខ្ពស់ ដោយមានព្រះថេរៈ (ឈ្មោះនេះ) ជាឧបជ្ឈាយ៍ នេះហៅថា ញត្តិ ។

បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំ, បុគ្គល (ឈ្មោះនេះ) នេះជាឧបសម្បទាបេក្ខរបស់ព្រះថេរៈអ្នកមានអាយុ (ឈ្មោះនេះ) (ឥឡូវ) សង្ឃញ៉ាំងបុគ្គល (ឈ្មោះនេះ) ឲ្យដល់ព្រមនូវគុណធម៌ដ៏ខ្ពង់ខ្ពស់ ដោយមានព្រះថេរៈ (ឈ្មោះនេះ) ជាឧបជ្ឈាយ៍; ការញ៉ាំងបុគ្គល (ឈ្មោះនេះ) ឲ្យដល់ព្រមនូវគុណធម៌ដ៏ខ្ពង់ខ្ពស់ ដោយមានព្រះថេរៈ (ឈ្មោះនេះ) ជាឧបជ្ឈាយ៍ គាប់ចិត្តដល់លោកអ្នកមានអាយុអង្គណា លោកអ្នកមានអាយុអង្គនោះ ត្រូវស្ងៀម មិនគាប់ចិត្តដល់លោកអ្នកមានអាយុអង្គណា លោកអ្នកមានអាយុអង្គនោះ ត្រូវនិយាយឡើង ។

ខ្ញុំពោលនូវសេចក្តីនេះ ជាគំរប់ពីរដងទៀត ។ បេ ។

ខ្ញុំពោលនូវសេចក្តីនេះ ជាគំរប់បីដងទៀត ។ បេ ។

បុគ្គល (ឈ្មោះនេះ) សង្ឃបានឲ្យដល់ព្រមនូវគុណធម៌ដ៏ខ្ពង់ខ្ពស់ ហើយ ដោយមានព្រះថេរៈ (ឈ្មោះនេះ) ជាឧបជ្ឈាយ៍; ការឲ្យដល់ព្រមនូវគុណធម៌ដ៏ខ្ពង់ខ្ពស់នោះ គាប់ចិត្តដល់សង្ឃ ព្រោះហេតុនោះបានជាសង្ឃស្ងៀម; ខ្ញុំចាំទុកនូវរឿងនេះ ដោយអាការស្ងៀមយ៉ាងនេះ" ។

ការបំបួសកុលបុត្រឲ្យបានកេទនឹងគុណធម៌ជាភិក្ខុភាវៈ ដោយញត្តិចតុត្ថកម្មវាចាតាមពុទ្ធានុញ្ញាត ដូចបាននិយាយមកនេះ ហៅថា កម្មលក្ខណៈ ក្នុងញត្តិចតុត្ថកម្មកថានេះ ។

អព្ភាន ប្រែថាការរាប់រកឬហៅរក ។ សេចក្តីថា ភិក្ខុត្រូវអាបត្តិសង្ឃាទិសេស ជាមន្ទិលសៅហ្មងក្នុងធម៌វិន័យ បើបានធ្វើបរិវាសកម្មនិងមានត្តកម្មរួចហើយ សង្ឃត្រូវរាប់រកភិក្ខុនោះ ថាជាភិក្ខុបរិសុទ្ធ ឥតមន្ទិលសៅហ្មង; ឯការរាប់រកនោះត្រូវធ្វើសង្ឃកម្ម ដែលហៅថា អព្ភានកម្ម ។ តែក្នុងទីនេះ ត្រូវនិយាយពីអព្ភានកម្ម តាមទំនងបរិវាសកម្មនិងមានត្តកម្ម ដែលបាននិយាយហើយត្រង់ទានកថាខាងដើម ។ ខាងដើមនោះបាននិយាយពីឯកាហបរិវាស ១ សុទ្ធន្តបរិវាស ១ ឧធានសមោធានបរិវាស ១ អគ្ឃសមោធានបរិវាស ១ និង អប្បដិច្ឆន្នមានត្ត គឺមានត្តព្រោះអាបត្តិដែលភិក្ខុមិនបិទបាំង ១ ។

អព្ភាន របស់ឯកាហបរិវាស មានសេចក្តីថា ភិក្ខុត្រូវអាបត្តិសង្ឃាទិ-
សេសបិទបាំង ១ ថ្ងៃ ត្រូវធ្វើឯកាហបរិវាស បើបានធ្វើឯកាហបរិវាសនឹង
មានត្ត ៦ រាត្រីរួចហើយ ត្រូវធ្វើអព្ភាន ភិក្ខុនោះត្រូវចូលទៅរកសង្ឃមាន
គណៈ ២០ រូប ជួបជុំក្នុងសីមា សូត្រសូមអព្ភានថា:

អហម្ភន្តេ សម្ពហុលា អាបត្តិយោ អាបជ្ជឹ ឯកាហ-
ប្បដិច្ឆន្នាយោ សោហំ សង្ឃំ សម្ពហុលានំ អាបត្តីនំ
ឯកាហប្បដិច្ឆន្នានំ ឯកាហបរិវាសំ យាចឹ តស្ស មេ
សង្ឃោ សម្ពហុលានំ អាបត្តីនំ ឯកាហប្បដិច្ឆន្នានំ
ឯកាហបរិវាសំ អទាសិ សោហំ បរិវុត្ថបរិវាសោ សង្ឃំ
សម្ពហុលានំ អាបត្តីនំ ឯកាហប្បដិច្ឆន្នានំ ឆារត្តំ មាន-
ត្តំ យាចឹ តស្ស មេ សង្ឃោ សម្ពហុលានំ អាបត្តីនំ ឯ-
កាហប្បដិច្ឆន្នានំ ឆារត្តំ មានត្តំ អទាសិ សោហំ ភន្តេ
ចិណ្ណមានត្តោ (១) សង្ឃំ អព្ភានំ យាចាមិ ។ អហម្ភន្តេ
។ បេ ។ សោហំ ចិណ្ណមានត្តោ ទុតិយម្បិ ភន្តេ សង្ឃំ
អព្ភានំ យាចាមិ ។ អហម្ភន្តេ ។ បេ ។ សោហំ ចិណ្ណ-
មានត្តោ តតិយម្បិ ភន្តេ សង្ឃំ អព្ភានំ យាចាមិ ។

---

១ ចិណ្ណ ចរធាតុ.ត-បច្ច័យ ផ្លាស់ តជាណ្ណ លុប រ ចោល សម្រេចរូបជា ចិណ្ណ ប្រែថា ប្រព្រឹត្តរួច តិណ្ណោ ឆ្លង, ជិណ្ណោ គ្រាំគ្រា, សំកិណ្ណោ ប្រឡូកប្រឡំ ជាដើមនោះឯង ។

“បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំព្រះករុណាត្រូវហើយនូវអាបត្តិជាច្រើន បិទបាំង ១ ថ្ងៃ ខ្ញុំព្រះករុណានោះបានសូមហើយនូវឯកាហបរិវាសអំពីសង្ឃ ដើម្បីអាបត្តិជាច្រើន បិទបាំង ១ ថ្ងៃ សង្ឃបានឲ្យហើយនូវឯកាហបរិវាស ដល់ខ្ញុំព្រះករុណានោះ ដើម្បីអាបត្តិជាច្រើន បិទបាំង ១ ថ្ងៃ ខ្ញុំព្រះករុណានោះបានប្រព្រឹត្តបរិវាសគ្រប់គ្រាន់ហើយ បានសូមហើយនូវមានត្ត ៦ រាត្រី អំពីសង្ឃ ដើម្បីអាបត្តិជាច្រើន បិទបាំង ១ ថ្ងៃ សង្ឃបានឲ្យហើយនូវមានត្ត ៦ រាត្រីដល់ខ្ញុំព្រះករុណានោះ ដើម្បីអាបត្តិជាច្រើន បិទបាំង ១ ថ្ងៃ បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំព្រះករុណានោះបានប្រព្រឹត្តមានត្តគ្រប់គ្រាន់ហើយ (ឥឡូវ)សូមនូវការរាប់រកអំពីសង្ឃ ។ បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំព្រះករុណា ។ បេ ។ ខ្ញុំព្រះករុណានោះបានប្រព្រឹត្តមានត្តគ្រប់គ្រាន់ហើយ បពិត្រព្រះសង្ឃដ៏ចំរើន (ឥឡូវ) ខ្ញុំព្រះករុណា សូមនូវការរាប់រកអំពីសង្ឃ ជាគំរប់ពីរដងទៀត ។ បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំព្រះករុណា ។បេ។ ខ្ញុំព្រះករុណានោះបានប្រព្រឹត្តមានត្តគ្រប់គ្រាន់ហើយ បពិត្រព្រះសង្ឃដ៏ចំរើន (ឥឡូវ) ខ្ញុំព្រះករុណាសូមនូវការរាប់រកអំពីសង្ឃ ជាគំរប់បីដងទៀត” ។

ភិក្ខុអ្នកឈ្លាស ប្រតិពល ត្រូវផ្ទៀងសង្ឃថា:

សុណាតុ មេ ភន្តេ សង្ឃោ អយំ (ឥត្ថន្នាមោ) ភិក្ខុ សម្ពហុលា អាបត្តិយោ អាបជ្ជិ ឯកាហប្បដិច្ឆន្នាយោ សោ សង្ឃំ សម្ពហុលានំ អាបត្តីនំ ឯកាហប្បដិច្ឆន្នានំ

ឯកាហបរិវាសំ យាចិ សង្ឃោ (ឥត្ថន្នាមស្ស) ភិក្ខុនោ សម្ពហុលានំ អាបត្តីនំ ឯកាហប្បដិច្ឆន្នានំ ឯកាហបរិវាសំ អទាសិ សោ បរិវុត្ថបរិវាសោ សង្ឃំ សម្ពហុលានំ អាបត្តីនំ ឯកាហប្បដិច្ឆន្នានំ ឆារត្តំ មានត្តំ យាចិ សង្ឃោ (ឥត្ថន្នាមស្ស) ភិក្ខុនោ សម្ពហុលានំ អាបត្តីនំ ឯកាហប្បដិច្ឆន្នានំ ឆារត្តំ មានត្តំ អទាសិ សោ ចិណ្ណមានត្តោ សង្ឃំ អព្ភានំ យាចតិ យទិ សង្ឃស្ស បត្តកល្លំ (ឥត្ថន្នាមំ) ភិក្ខុំ អព្ភេយ្យ ឯសា ញត្តិ ។

សុណាតុ មេ ភន្តេ សង្ឃោ អយំ (ឥត្ថន្នាមោ) ភិក្ខុ សម្ពហុលា អាបត្តិយោ អាបជ្ជិ ឯកាហប្បដិច្ឆន្នាយោ សោ សង្ឃំ សម្ពហុលានំ អាបត្តីនំ ឯកាហប្បដិច្ឆន្នានំ ឯកាហបរិវាសំ យាចិ សង្ឃោ (ឥត្ថន្នាមស្ស) ភិក្ខុនោ សម្ពហុលានំ អាបត្តីនំ ឯកាហប្បដិច្ឆន្នានំ ឯកាហបរិវាសំ អទាសិ សោ បរិវុត្ថបរិវាសោ សង្ឃំ សម្ពហុលានំ អាបត្តីនំ ឯកាហប្បដិច្ឆន្នានំ ឆារត្តំ មានត្តំ យាចិ សង្ឃោ (ឥត្ថន្នាមស្ស) ភិក្ខុនោ សម្ពហុលានំ អាបត្តីនំ ឯកាហប្បដិច្ឆន្នានំ ឆារត្តំ មានត្តំ អទាសិ សោ ចិណ្ណមានត្តោ សង្ឃំ អព្ភានំ យាចតិ សង្ឃោ

(ឥត្ថន្នាមំ) ភិក្ខុំ អព្ភេតិ យស្សាយស្មតោ ខមតិ (ឥត្ថន្នាមស្ស) ភិក្ខុនោ អព្ភានំ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។

ទុតិយម្បិ ឯតមត្ថំ វទាមិ ។ បេ ។

តតិយម្បិ ឯតមត្ថំ វទាមិ ។ បេ ។

អព្ភិតោ សង្ឃេន (ឥត្ថន្នាមោ) ភិក្ខុ ខមតិ សង្ឃស្ស តស្មា តុណ្ហី ឯវមេតំ ធារយាមិ ។

“បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំ, ភិក្ខុ (ឈ្មោះនេះ) នេះត្រូវហើយនូវអាបត្តិជាច្រើន បិទបាំង ១ ថ្ងៃ ភិក្ខុនោះបានសូមហើយនូវឯកាហបរិវាសអំពីសង្ឃ ដើម្បីអាបត្តិជាច្រើន បិទបាំង ១ ថ្ងៃ សង្ឃបានឲ្យហើយនូវឯកាហបរិវាសដល់ភិក្ខុ (ឈ្មោះនេះ) ដើម្បីអាបត្តិជាច្រើន បិទបាំង ១ ថ្ងៃ ភិក្ខុនោះបានប្រព្រឹត្តបរិវាសគ្រប់គ្រាន់ហើយ បានសូមហើយនូវមានត្ត ៦ រាត្រីអំពីសង្ឃ ដើម្បីអាបត្តិជាច្រើន បិទបាំង ១ ថ្ងៃ សង្ឃបានឲ្យហើយនូវមានត្ត ៦ រាត្រី ដល់ភិក្ខុ (ឈ្មោះនេះ) ដើម្បីអាបត្តិជាច្រើន បិទបាំង១ថ្ងៃ ភិក្ខុនោះបានប្រព្រឹត្តមានត្តគ្រប់គ្រាន់ហើយ សូមនូវការរាប់រកអំពីសង្ឃ; បើអព្ភានកម្ម មានកាលដ៏សមគួរដល់សង្ឃហើយ សង្ឃគប្បីរាប់រកនូវភិក្ខុ (ឈ្មោះនេះ); នេះហៅថា ញត្តិ ។

បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំ ភិក្ខុ (ឈ្មោះ

នេះ) នេះបានត្រូវហើយនូវអាបត្តិជាច្រើន បិទបាំង ១ ថ្ងៃ ភិក្ខុនោះបានសូមហើយនូវឯកាហបរិវាសអំពីសង្ឃ ដើម្បីអាបត្តិជាច្រើនបិទបាំង ១ ថ្ងៃ សង្ឃបានឲ្យហើយនូវឯកាហបរិវាសដល់ភិក្ខុ (ឈ្មោះនេះ) ដើម្បីអាបត្តិជាច្រើនបិទបាំង ១ ថ្ងៃ ភិក្ខុនោះបានប្រព្រឹត្តបរិវាសគ្រប់គ្រាន់ហើយ បានសូមហើយនូវមានត្ត ៦ រាត្រីអំពីសង្ឃ ដើម្បីអាបត្តិជាច្រើន បិទបាំង ១ ថ្ងៃ សង្ឃបានឲ្យហើយនូវមានត្ត ៦ រាត្រីដល់ភិក្ខុ (ឈ្មោះនេះ) ដើម្បីអាបត្តិជាច្រើន បិទបាំង ១ ថ្ងៃ ភិក្ខុនោះបានប្រព្រឹត្តមានត្តគ្រប់គ្រាន់ហើយ សូមនូវការរាប់រកអំពីសង្ឃ (ឥឡូវ) សង្ឃរាប់រកនូវភិក្ខុ (ឈ្មោះនេះ), ការរាប់រកនូវភិក្ខុ (ឈ្មោះនេះ) គាប់ចិត្តដល់លោកអ្នកមានអាយុអង្គណា លោកអ្នកមានអាយុអង្គនោះ ត្រូវស្ងៀម មិនគាប់ចិត្តដល់លោកអ្នកមានអាយុអង្គណា លោកអ្នកមានអាយុអង្គនោះ ត្រូវនិយាយឡើង ។

ខ្ញុំពោលនូវសេចក្តីនេះ ជាគំរប់ពីរដងទៀត បេ ។

ខ្ញុំពោលនូវសេចក្តីនេះ ជាគំរប់បីដងទៀត បេ ។

ភិក្ខុ (ឈ្មោះនេះ) សង្ឃបានរាប់រកហើយ, ការរាប់រកនោះគាប់ចិត្តដល់សង្ឃ ព្រោះហេតុនោះបានជាសង្ឃស្ងៀម, ខ្ញុំចាំទុកនូវរឿងនេះដោយអាការស្ងៀមយ៉ាងនេះ" ។

អព្ភាន របស់សុទ្ធន្តបរិវាស មានវិធីសូត្រសូមដូច្នេះ អហម្ភន្តេ សម្ពហុលា សង្ឃាទិសេសា អាបត្តិយោ អាបជ្ជឹ អាបត្តិ

បរិយន្តំ ច ជានាមិ រត្តិបរិយន្តំ ច ជានាមិ អាបត្តិបរិយន្តំ ច សរាមិ រត្តិបរិយន្តំ ច សរាមិ អាបត្តិបរិយន្តេ វេមតិកោ រត្តិបរិយន្តេ វេមតិកោ សោហំ សង្ឃំ តាសំ អាបត្តីនំ សុទ្ធន្តបរិវាសំ យាចិំ តស្ស មេ សង្ឃោ តាសំ អាបត្តីនំ សុទ្ធន្តបរិវាសំ អទាសិ សោហំ បរិវុត្ថបរិវាសោ សង្ឃំ តាសំ អាបត្តីនំ ឆារត្តំ មានត្តំ យាចិំ តស្ស មេ សង្ឃោ តាសំ អាបត្តីនំ ឆារត្តំ មានត្តំ អទាសិ សោហំ ភន្តេ ចិណ្ណមានត្តោ សង្ឃំ អព្ភានំ យាចាមិ "បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំព្រះករុណាបានត្រូវហើយនូវអាបត្តិសង្ឃាទិសេសជាច្រើន មិនដឹងនូវកំណត់អាបត្តិ មិនដឹងនូវកំណត់រាត្រី នឹកមិនឃើញនូវកំណត់អាបត្តិ នឹកមិនឃើញនូវកំណត់រាត្រី មានសេចក្តីសង្ស័យក្នុងកំណត់អាបត្តិ មានសេចក្តីសង្ស័យក្នុងកំណត់រាត្រី ខ្ញុំព្រះករុណានោះ បានសូមហើយនូវសុទ្ធន្តបរិវាសអំពីសង្ឃ ដើម្បីអាបត្តិទាំងនោះ សង្ឃបានឲ្យហើយនូវសុទ្ធន្តបរិវាស ដល់ខ្ញុំព្រះករុណានោះ ដើម្បីអាបត្តិទាំងនោះ ខ្ញុំព្រះករុណានោះ បានប្រព្រឹត្តបរិវាសគ្រប់គ្រាន់ហើយ បានសូមហើយនូវមានត្ត ៦ រាត្រីអំពីសង្ឃ ដើម្បីអាបត្តិទាំងនោះ សង្ឃបានឲ្យហើយនូវមានត្ត៦រាត្រីដល់ខ្ញុំព្រះករុណានោះ ដើម្បីអាបត្តិទាំងនោះ បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំព្រះករុណានោះ បានប្រព្រឹត្តមានត្តគ្រប់គ្រាន់ហើយ (ឥឡូវ) សូមនូវការរាប់រកអំពី

សង្ឃ" (សូត្រ ៣ ៨៩) ។

ភិក្ខុអ្នកឈ្លាស ប្រតិពល ត្រូវផ្ទៀងសង្ឃថា:

សុណាតុ មេ ភន្តេ សង្ឃោ អយំ (ឥត្ថន្នាមោ) ភិក្ខុ សម្ពហុលា សង្ឃាទិសេសា អាបត្តិយោ អាបជ្ជិ អាបត្តិបរិយន្តំ ន ជានាតិ រត្តិបរិយន្តំ ន ជានាតិ អាបត្តិបរិយន្តំ ន សរតិ រត្តិបរិយន្តំ ន សរតិ អាបត្តិបរិយន្តេ វេមតិកោ រត្តិបរិយន្តេ វេមតិកោ សោ សង្ឃំ តាសំ អាបត្តីនំ សុទ្ធន្តបរិវាសំ យាចិ សង្ឃោ (ឥត្ថន្នាមស្ស) ភិក្ខុនោ តាសំ អាបត្តីនំ សុទ្ធន្តបរិវាសំ អទាសិ សោ បរិវុត្ថបរិវាសោ សង្ឃំ តាសំ អាបត្តីនំ ឆារត្តំ មានត្តំ យាចិ សង្ឃោ (ឥត្ថន្នាមស្ស) ភិក្ខុនោ តាសំ អាបត្តីនំ ឆារត្តំ មានត្តំ អទាសិ សោ ចិណ្ណមានត្តោ សង្ឃំ អព្ភានំ យាចតិ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ (ឥត្ថន្នាមំ) ភិក្ខុំ អព្ភេយ្យ ឯសា ញត្តិ ។

សុណាតុ មេ ភន្តេ សង្ឃោ អយំ (ឥត្ថន្នាមោ) ភិក្ខុ សម្ពហុលា សង្ឃាទិសេសា អាបត្តិយោ អាបជ្ជិ អាបត្តិបរិយន្តំ ន ជានាតិ រត្តិបរិយន្តំ ន ជានាតិ អាបត្តិបរិយន្តំ ន សរតិ រត្តិបរិយន្តំ ន សរតិ អាបត្តិបរិយន្តេ វេមតិកោ

រត្តិបរិយន្តេ វេមតិកោ សោ សង្ឃំ តាសំ អាបត្តីនំ សុទ្ធន្តបរិវាសំ យាចិ សង្ឃោ (ឥត្ថន្នាមស្ស) ភិក្ខុនោ តាសំ អាបត្តីនំ សុទ្ធន្តបរិវាសំ អទាសិ សោ បរិវុត្ថបរិវាសោ សង្ឃំ តាសំ អាបត្តីនំ ឆារត្តំ មានត្តំ យាចិ សង្ឃោ (ឥត្ថន្នាមស្ស) ភិក្ខុនោ តាសំ អាបត្តីនំ ឆារត្តំ មានត្តំ អទាសិ សោ ចិណ្ណមានត្តោ សង្ឃំ អព្ភានំ យាចតិ សង្ឃោ (ឥត្ថន្នាម) ភិក្ខុំ អព្ភេតិ យស្សាយស្មតោ ខមតិ (ឥត្ថន្នាមស្ស) ភិក្ខុនោ អព្ភានំ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។

ទុតិយម្បិ ឯតមត្ថំ វទាមិ ។ បេ ។

តតិយម្បិ ឯតមត្ថំ វទាមិ ។ បេ ។

អព្ភិតោ សង្ឃេន (ឥត្ថន្នាមោ) ភិក្ខុ ខមតិ សង្ឃស្ស តស្មា តុណ្ហី ឯវមេតំ ធារយាមិ ។

"បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំ, ភិក្ខុ (ឈ្មោះនេះ) នេះ បានត្រូវហើយនូវអាបត្តិសង្ឃាទិសេសជាច្រើន មិនដឹងនូវកំណត់អាបត្តិ មិនដឹងនូវកំណត់រាត្រី នឹកមិនឃើញនូវកំណត់អាបត្តិ នឹកមិនឃើញនូវកំណត់រាត្រី មានសេចក្តីសង្ស័យក្នុងកំណត់អាបត្តិ មានសេចក្តីសង្ស័យក្នុងកំណត់រាត្រី, ភិក្ខុនោះបានសូមហើយនូវសុទ្ធន្តបរិវាសអំពីសង្ឃ

ដើម្បីអាបត្តិទាំងនោះ, សង្ឃបានឲ្យហើយនូវសុទ្ធន្តបរិវាសដល់ភិក្ខុ (ឈ្មោះនេះ) ដើម្បីអាបត្តិទាំងនោះ, ភិក្ខុនោះបានប្រព្រឹត្តបរិវាសគ្រប់គ្រាន់ហើយ បានសូមហើយនូវមានត្ត ៦ រាត្រីអំពីសង្ឃ ដើម្បីអាបត្តិទាំងនោះ សង្ឃបានឲ្យហើយនូវមានត្ត ៦ រាត្រីដល់ភិក្ខុ (ឈ្មោះនេះ) ដើម្បីអាបត្តិទាំងនោះ ភិក្ខុនោះបានប្រព្រឹត្តមានត្តគ្រប់គ្រាន់ហើយ សូមនូវការរាប់រកអំពីសង្ឃ, បើអព្ភានកម្ម មានកាលដ៏សមគួរដល់សង្ឃហើយ សង្ឃគប្បីរាប់រកនូវភិក្ខុ (ឈ្មោះនេះ); នេះហៅថា ញត្តិ ។

បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំ, ភិក្ខុ (ឈ្មោះនេះ) នេះ បានត្រូវហើយនូវអាបត្តិសង្ឃាទិសេសជាច្រើនមិនដឹងនូវកំណត់អាបត្តិ មិនដឹងនូវកំណត់រាត្រី នឹកមិនឃើញនូវកំណត់អាបត្តិ នឹកមិនឃើញនូវកំណត់រាត្រី មានសេចក្តីសង្ស័យក្នុងកំណត់អាបត្តិ មានសេចក្តីសង្ស័យក្នុងកំណត់រាត្រី, ភិក្ខុនោះបានសូមហើយនូវសុទ្ធន្តបរិវាសអំពីសង្ឃ ដើម្បីអាបត្តិទាំងនោះ សង្ឃបានឲ្យហើយនូវសុទ្ធន្តបរិវាសដល់ភិក្ខុ (ឈ្មោះនេះ) ដើម្បីអាបត្តិទាំងនោះ, ភិក្ខុនោះ បានប្រព្រឹត្តបរិវាសគ្រប់គ្រាន់ហើយ បានសូមនូវមានត្ត ៦ រាត្រីអំពីសង្ឃ ដើម្បីអាបត្តិទាំងនោះ, សង្ឃបានឲ្យហើយនូវមានត្ត ៦ រាត្រី ដល់ភិក្ខុ (ឈ្មោះនេះ) ដើម្បីអាបត្តិទាំងនោះ, ភិក្ខុនោះបានប្រព្រឹត្តមានត្តគ្រប់គ្រាន់ហើយ សូមនូវការរាប់រកអំពីសង្ឃ (ឥឡូវ) សង្ឃរាប់រកនូវភិក្ខុ (ឈ្មោះនេះ); ការរាប់រកនូវភិក្ខុ (ឈ្មោះនេះ) គាប់ចិត្ត

ដល់លោកអ្នកមានអាយុអង្គណា លោកអ្នកមានអាយុអង្គនោះត្រូវស្ងៀម មិនគាប់ចិត្តដល់លោកអ្នកមានអាយុអង្គណា លោកអ្នកមានអាយុអង្គនោះ ត្រូវនិយាយឡើង ។

ខ្ញុំពោលនូវសេចក្ដីនេះ ជាគំរប់ពីរដងទៀត ។ បេ ។

ខ្ញុំពោលនូវសេចក្ដីនេះ ជាគំរប់បីដងទៀត ។ បេ ។

ភិក្ខុ (ឈ្មោះនេះ) សង្ឃបានពប់រកហើយ, ការកប់រកនោះគាប់ចិត្តដល់ សង្ឃ ព្រោះហេតុនោះបានជាសង្ឃស្ងៀម, ខ្ញុំចាំទុកនូវរឿងនេះ ដោយ អាការស្ងៀមយ៉ាងនេះ ” ។

អព្ភាន របស់ឧធានសមោធានបរិវាស ។ កាលភិក្ខុបានប្រព្រឹត្តមានត្ត គ្រប់គ្រាន់ហើយ ត្រូវសូត្រសូមអព្ភានដូច្នេះ អហម្ភន្តេ សម្ពហុលា អាបត្តិយោ អាបជ្ជឹ បក្ខប្បដិច្ឆន្នាយោ សោហំ សង្ឃំ សម្ពហុលានំ អាបត្តីនំ បក្ខប្បដិច្ឆន្នានំ បក្ខបរិវាសំ យាចឹ តស្ស មេ សង្ឃោ សម្ពហុលានំ អាបត្តីនំ, បក្ខ-ប្បដិច្ឆន្នានំ បក្ខបរិវាសំ អទាសិ សោហំ បរិវសន្តោ អន្តរា សម្ពហុលា អាបត្តិយោ អាបជ្ជឹ បញ្ចាហប្បដិច្ឆ-ន្នាយោ សោហំ សង្ឃំ អន្តរា សម្ពហុលានំ អាបត្តីនំ បញ្ចាហប្បដិច្ឆន្នានំ មូលាយប្បដិកស្សនំ យាចឹ តម្មំ សង្ឃោ អន្តរា សម្ពហុលានំ អាបត្តីនំ បញ្ចាហប្បដិច្ឆ

ឆន្នំ មូលាយ បដិកស្សិ សោហំ សង្ឃំ អន្តរា សម្ព-
ហុលានំ អាបត្តីនំ បញ្ចាហប្បដិច្ឆន្នានំ បុរិមាសុ អាបត្តី-
សុ សមោធានបរិវាសំ យាចិ តស្ស មេ សង្ឃោ អន្តរា
សម្ពហុលានំ អាបត្តីនំ បញ្ចាហប្បដិច្ឆន្នានំ បុរិមាសុ
អាបត្តីសុ សមោធានបរិវាសំ អទាសិ សោហំ បរិវុត្ថបរិ-
វាសោ សង្ឃំ សម្ពហុលានំ អាបត្តីនំ ឆារត្តំ មានត្តំ យាចិ
តស្ស មេ សង្ឃោ សម្ពហុលានំ អាបត្តីនំ ឆារត្តំ មានត្តំ
អទាសិ សោហំ ភន្តេ ចិណ្ណមានត្តោ សង្ឃំ អព្ភានំ
យាចាមិ "បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំព្រះករុណាបានត្រូវហើយ នូវ
អាបត្តិជាច្រើន បិទបាំង ១ បក្ខ, ខ្ញុំព្រះករុណានោះបានសូមហើយ នូវបក្ខ
បរិវាសអំពីសង្ឃ ដើម្បីអាបត្តិជាច្រើន បិទបាំង ១ បក្ខ, សង្ឃបានឲ្យហើយ
នូវបក្ខបរិវាសដល់ខ្ញុំព្រះករុណានោះ ដើម្បីអាបត្តិជាច្រើន បិទបាំង ១ បក្ខ,
ខ្ញុំព្រះករុណានោះកំពុងប្រព្រឹត្តបរិវាស បានត្រូវហើយនូវអាបត្តិជាច្រើនក្នុង
ចន្លោះ បិទបាំង ៥ ថ្ងៃ, ខ្ញុំព្រះករុណានោះបានសូមហើយនូវមូលាយប្ប
ដិកស្សនៈ អំពីសង្ឃ ដើម្បីអាបត្តិជាច្រើន ក្នុងចន្លោះ បិទបាំង ៥ ថ្ងៃ, សង្ឃ
បានទាញហើយនូវខ្ញុំព្រះករុណានោះ មកដាក់ក្នុងមូលាបត្តិ ដើម្បីអាបត្តិ
ជាច្រើន ក្នុងចន្លោះ បិទបាំង ៥ ថ្ងៃ, ខ្ញុំព្រះករុណានោះ បានសូមហើយនូវ
បរិវាសប្រកបដោយការប្រមូលនូវអាបត្តិជាច្រើន ក្នុងចន្លោះបិទបាំង ៥ ថ្ងៃ

មកបញ្ចូកក្នុងអាបត្តិមុន អំពីសង្ឃ, សង្ឃបានឲ្យហើយនូវបរិវាសប្រកប ដោយការប្រមូល នូវអាបត្តិជាច្រើនក្នុងចន្លោះ បិទបាំង ៥ ថ្ងៃ មក បញ្ចូកក្នុងអាបត្តិមុន ដល់ខ្ញុំព្រះករុណានោះ, ខ្ញុំព្រះករុណានោះបានប្រ-ព្រឹត្តបរិវាសគ្រប់គ្រាន់ហើយ បានសូមហើយនូវមានត្ត ៦ រាត្រីអំពីសង្ឃ ដើម្បីអាបត្តិជាច្រើន, សង្ឃបានឲ្យហើយនូវមានត្ត ៦ រាត្រីដល់ខ្ញុំព្រះករុ-ណានោះ ដើម្បីអាបត្តិជាច្រើន, បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំព្រះករុណា នោះបានប្រព្រឹត្តមានត្តគ្រប់គ្រាន់ហើយ (ឥឡូវ) សូមនូវការរាប់រកអំពី សង្ឃ" (សូត្រ ៣ ដង) ។

ភិក្ខុអ្នកឈ្លាស ប្រតិពល ត្រូវផ្តៀងសង្ឃថា

សុណាតុ មេ ភន្តេ សង្ឃោ អយំ (ឥត្ថន្នាមោ) ភិក្ខុ សម្ពហុលា អាបត្តិយោ អាបជ្ជិ បក្ខប្បដិច្ឆន្នាយោ សោ សង្ឃំ សម្ពហុលានំ អាបត្តីនំ បក្ខប្បដិច្ឆន្នានំ បក្ខបរិវាសំ យាចិ សង្ឃោ (ឥត្ថន្នាមស្ស) ភិក្ខុនោ សម្ពហុលានំ អាបត្តីនំ បក្ខប្បដិច្ឆន្នានំ បក្ខបរិវាសំ អទាសិ សោ បរិវសន្តោ អន្តរា សម្ពហុលា អាបត្តិយោ អាបជ្ជិ បញ្ចាហប្បដិច្ឆន្នាយោ សោ សង្ឃំ អន្តរា សម្ព-ហុលានំ អាបត្តីនំ បញ្ចាហប្បដិច្ឆន្នានំ មូលាយប្បដិក-ស្សនំ យាចិ សង្ឃោ (ឥត្ថន្នាមំ) ភិក្ខុំ អន្តរា សម្ពហុលា-

នំ អាបត្តីនំ បញ្ចាហប្បដិច្ឆន្នានំ មូលាយ បដិកស្សិ
សោ សង្ឃំ អន្តរា សម្ពហុលានំ អាបត្តីនំ បញ្ចាហប្បដិ-
ច្ឆន្នានំ បុរិមាសុ អាបត្តីសុ សមោធានបរិវាសំ យាចិ
សង្ឃោ (ឥត្ថន្នាមស្ស) ភិក្ខុនោ អន្តរា សម្ពហុលានំ
អាបត្តីនំ បញ្ចាហប្បដិច្ឆន្នានំ បុរិមាសុ អាបត្តីសុ ស-
មោធានបរិវាសំ អទាសិ សោ បរិវុត្ថបរិវាសោ សង្ឃំ
សម្ពហុលានំ អាបត្តីនំ ឆារត្តំ មានត្តំ យាចិ សង្ឃោ
(ឥត្ថន្នាមស្ស) ភិក្ខុនោ សម្ពហុលានំ អាបត្តីនំ ឆារត្តំ
មានត្តំ អទាសិ សោ ចិណ្ណមានត្តោ សង្ឃំ អព្ភានំ
យាចិ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ (ឥត្ថន្នាមំ)
ភិក្ខុំ អព្ភេយ្យ ឯសា ញត្តិ ។

សុណាតុ មេ ភន្តេ សង្ឃោ អយំ (ឥត្ថន្នាមោ) ភិក្ខុ
សម្ពហុលា អាបត្តិយោ អាបជ្ជិ បក្ខប្បដិច្ឆន្នាយោ
សោ សង្ឃំ សម្ពហុលានំ អាបត្តីនំ បក្ខប្បដិច្ឆន្នានំ
បក្ខបរិវាសំ យាចិ សង្ឃោ (ឥត្ថន្នាមស្ស) ភិក្ខុនោ
សម្ពហុលានំ អាបត្តីនំ បក្ខប្បដិច្ឆន្នានំ បក្ខបរិវាសំ
អទាសិ សោ បរិវសន្តោ អន្តរា សម្ពហុលា អាបត្តិយោ
អាបជ្ជិ បញ្ចាហប្បដិច្ឆន្នាយោ សោ សង្ឃំ អន្តរា សម្ព-

ហុលានំ អាបត្តីនំ បញ្ចាហប្បដិច្ឆន្នានំ មូលាយប្បដិ-
កស្សនំ យាចិ សង្ឃោ (ឥត្ថន្នាមំ) ភិក្ខុំ អន្តរា សម្ព-
ហុលានំ អាបត្តីនំ បញ្ចាហប្បដិច្ឆន្នានំ មូលាយ បដិកា-
ស្សិ សោ សង្ឃំ អន្តរា សម្ពហុលានំ អាបត្តីនំ បញ្ចា-
ហប្បដិច្ឆន្នានំ បុរិមាសុ អាបត្តីសុ សមោធានបរិវាសំ
យាចិ សង្ឃោ (ឥត្ថនាមស្ស) ភិក្ខុនោ អន្តរា សម្ពហុ-
លានំ អាបត្តីន បញ្ចាហប្បដិច្ឆន្នានំ បុរិមាសុ អាបត្តីសុ
សមោធានបរិវាសំ អទាសិ សោ បរិវុត្ថបរិវាសោ សង្ឃំ
សម្ពហុលានំ អាបត្តីនំ ឆារត្តំ មានត្តំ យាចិ សង្ឃោ
(ឥត្ថន្នាមស្ស) ភិក្ខុនោ សម្ពហុលានំ អាបត្តីនំ ឆារត្តំ
មានត្តំ អទាសិ សោ ចិណ្ណមានត្តោ សង្ឃំ អព្ភានំ
យាចតិ សង្ឃោ (ឥត្ថន្នាមំ) ភិក្ខុំ អព្ភេតិ យស្សាយស្ម-
តោ ខមតិ (ឥត្ថន្នាមស្ស) ភិក្ខុនោ អព្ភានំ សោ តុណ្ហ-
ស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។

ទុតិយម្បិ ឯតមត្ថំ វទាមិ ។ បេ ។

តតិយម្បិ ឯតមត្ថំ វទាមិ ។ បេ ។

អព្ភិតោ សង្ឃេន (ឥត្ថន្នាមោ) ភិក្ខុ ខមតិ សង្ឃស្ស
តស្មា តុណ្ហី ឯវមេតំ ធារយាមិ ។

"បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំ, ភិក្ខុ (ឈ្មោះនេះ) នេះ បានត្រូវហើយនូវអាបត្តិជាច្រើន បិទបាំង ១ ប័ក្ខ, ភិក្ខុនោះបានសូមហើយនូវបក្ខបរិវាសអំពីសង្ឃ ដើម្បីអាបត្តិជាច្រើន បិទបាំង ១ ប័ក្ខ សង្ឃបានឲ្យហើយនូវបក្ខបរិវាស ដល់ភិក្ខុ (ឈ្មោះនេះ) ដើម្បីអាបត្តិជាច្រើន បិទបាំង ១ ប័ក្ខ, ភិក្ខុនោះកំពុងប្រព្រឹត្តបរិវាស បានត្រូវហើយនូវអាបត្តិជាច្រើន ក្នុងចន្លោះ បិទបាំង ៥ ថ្ងៃ, ភិក្ខុនោះបានសូមហើយនូវមូលាយបដិកស្សនៈ អំពីសង្ឃ ដើម្បីអាបត្តិជាច្រើន ក្នុងចន្លោះ បិទបាំង ៥ ថ្ងៃ, សង្ឃបានទាញហើយនូវភិក្ខុ (ឈ្មោះនេះ) មកដាក់ក្នុងមូលាបត្តិ ដើម្បីអាបត្តិជាច្រើន ក្នុងចន្លោះ បិទបាំង ៥ ថ្ងៃ, ភិក្ខុនោះបានសូមហើយនូវបរិវាស ប្រកបដោយការប្រមូលនូវអាបត្តិជាច្រើន ក្នុងចន្លោះ បិទបាំង ៥ ថ្ងៃ មកបញ្ច្រូកក្នុងអាបត្តិមុន អំពីសង្ឃ, សង្ឃបានឲ្យហើយនូវបរិវាសប្រកបដោយការប្រមូលនូវអាបត្តិជាច្រើន ក្នុងចន្លោះ បិទបាំង ៥ ថ្ងៃ មកបញ្ច្រូកក្នុងអាបត្តិមុន ដល់ភិក្ខុ (ឈ្មោះនេះ), ភិក្ខុនោះបានប្រព្រឹត្តបរិវាសគ្រប់គ្រាន់ហើយ បានសូមហើយនូវមានត្ត ៦ រាត្រីអំពីសង្ឃ ដើម្បីអាបត្តិជាច្រើន, សង្ឃបានឲ្យហើយនូវមានត្ត ៦ រាត្រីដល់ភិក្ខុ (ឈ្មោះនេះ) ដើម្បីអាបត្តិជាច្រើន ភិក្ខុនោះបានប្រព្រឹត្តមានត្តគ្រប់គ្រាន់ហើយ សូមនូវការរាប់រកអំពីសង្ឃ, បើអព្ភានកម្ម មានកាលដ៏សមគួរដល់សង្ឃហើយ សង្ឃគប្បីរាប់រកនូវភិក្ខុ (ឈ្មោះនេះ); នេះហៅថា ញត្តិ ។

បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំ, ភិក្ខុ (ឈ្មោះនេះ) នេះបានត្រូវហើយនូវអាបត្តិជាច្រើន បិទបាំង ១ បក្ខ ភិក្ខុនោះបានសូមហើយនូវបក្ខបរិវាសអំពីសង្ឃ ដើម្បីអាបត្តិជាច្រើន បិទបាំង ១ បក្ខ សង្ឃបានឲ្យហើយនូវបក្ខបរិវាស ដល់ភិក្ខុ (ឈ្មោះនេះ) ដើម្បីអាបត្តិជាច្រើន បិទបាំង ១ បក្ខ, ភិក្ខុនោះកំពុងប្រព្រឹត្តបរិវាស បានត្រូវហើយនូវអាបត្តិជាច្រើន ក្នុងចន្លោះ បិទបាំង ៥ ថ្ងៃ, ភិក្ខុនោះបានសូមហើយនូវមូលាយបដិកស្សនៈអំពីសង្ឃ ដើម្បីអាបត្តិជាច្រើន ក្នុងចន្លោះ បិទបាំង ៥ ថ្ងៃ, សង្ឃបានទាញហើយនូវភិក្ខុ (ឈ្មោះនេះ) មកដាក់ក្នុងមូលាបត្តិ ដើម្បីអាបត្តិជាច្រើន ក្នុងចន្លោះ បិទបាំង ៥ ថ្ងៃ. ភិក្ខុនោះបានសូមហើយនូវបរិវាសប្រកបដោយការប្រមូលនូវអាបត្តិជាច្រើន ក្នុងចន្លោះ បិទបាំង ៥ថ្ងៃ មកបញ្ជ្រាបក្នុងអាបត្តិមុន អំពីសង្ឃ, សង្ឃបានឲ្យហើយនូវបរិវាសប្រកបដោយការប្រមូល នូវអាបត្តិជាច្រើន ក្នុងចន្លោះ បិទបាំង ៥ ថ្ងៃ មកបញ្ជ្រាបក្នុងអាបត្តិមុន ដល់ភិក្ខុ (ឈ្មោះនេះ), ភិក្ខុនោះបានប្រព្រឹត្តបរិវាសគ្រប់គ្រាន់ហើយ បានសូមហើយនូវមានត្ត ៦ រាត្រី អំពីសង្ឃ ដើម្បីអាបត្តិជាច្រើន, សង្ឃបានឲ្យហើយនូវមានត្ត ៦ រាត្រី ដល់ភិក្ខុ (ឈ្មោះនេះ) ដើម្បីអាបត្តិជាច្រើន, ភិក្ខុនោះបានប្រព្រឹត្តមានត្តគ្រប់គ្រាន់ហើយ សូមនូវការរាប់គេអំពីសង្ឃ, (ឥឡូវ) សង្ឃរាប់គេនូវភិក្ខុ (ឈ្មោះនេះ), ការរាប់គេនូវភិក្ខុ (ឈ្មោះនេះ) គាប់ចិត្តដល់លោកអ្នកមានអាយុ

អង្គណា លោកអ្នកមានអាយុអង្គនោះត្រូវស្ងៀម មិនគាប់ចិត្តដល់លោក
អ្នកមានអាយុអង្គណា លោកអ្នកមានអាយុអង្គនោះត្រូវនិយាយឡើង ។

ខ្ញុំពោលនូវសេចក្តីនេះ ជាគំរប់ពីរដងទៀត ។ បេ ។

ខ្ញុំពោលនូវសេចក្តីនេះ ជាគំរប់បីដងទៀត ។ បេ ។

ភិក្ខុ (ឈ្មោះនេះ) សង្ឃបានរាប់រកហើយ, ការរាប់រកនោះ គាប់ចិត្ត
ដល់សង្ឃ ព្រោះហេតុនោះបានជាសង្ឃស្ងៀម, ខ្ញុំចាំទុកនូវរឿងនេះ
ដោយអាការស្ងៀមយ៉ាងនេះ" ។

អព្ភាន របស់អគ្ឃសមោធានបរិវាស មានវិធីសូត្រសូមដូច្នេះ

អហម្ភន្តេ សម្ពហុលា អាបត្តិយោ អាបជ្ជឹ ឯកច្ចា អាប-
ត្តិយោ ឯកាហប្បដិច្ឆន្នាយោ ឯកច្ចា ទ្វិហប្បដិច្ឆន្នា-
យោ ឯកច្ចា តិហប្បដិច្ឆន្នាយោ ឯកច្ចា ចតុហប្ប-
ដិច្ឆន្នាយោ ឯកច្ចា បញ្ចាហប្បដិច្ឆន្នាយោ ឯកច្ចា
ឆាហប្បដិច្ឆន្នាយោ ឯកច្ចា សត្តាហប្បដិច្ឆន្នាយោ
ឯកច្ចា អដ្ឋាហប្បដិច្ឆន្នាយោ ឯកច្ចា នវាហប្បដិច្ឆ-
ន្នាយោ ឯកច្ចា ទសាហប្បដិច្ឆន្នាយោ សោហំ សង្ឃំ
តាសំ អាបត្តីនំ យា អាបត្តិយោ ទសាហប្បដិច្ឆន្នាយោ
តាសំ អគ្ឃសមោធានបរិវាសំ យាចឹ តស្ស មេ
សង្ឃោ តាសំ អាបត្តីនំ យា អាបត្តិយោ ទសាហប្បដិ-

ច្ឆន្នាយោ តាសំ អគ្ឃេន សមោធានបរិវាសំ អទាសិ សោហំ បរិវុត្ថបរិវាសោ សង្ឃំ តាសំ អាបត្តីនំ ឆារត្តមានត្តំ យាចឹ តស្ស មេ សង្ឃោ តាសំ អាបត្តីនំ ឆារត្តំមានត្តំ អទាសិ សោហំ ភន្តេ ចិណ្ណមានត្តោ សង្ឃំ អព្ភានំ យាចាមិ“បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំព្រះករុណាបានត្រូវហើយនូវអាបត្តិជាច្រើន អាបត្តិពួកខ្លះបិទបាំង១ថ្ងៃ ខ្លះបិទបាំង ២ ថ្ងៃ ខ្លះបិទបាំង៣ថ្ងៃ ខ្លះបិទបាំង៤ថ្ងៃ ខ្លះបិទបាំង៥ថ្ងៃ ខ្លះបិទបាំង ៦ ថ្ងៃ ខ្លះបិទបាំង៧ថ្ងៃ ខ្លះបិទបាំង៨ថ្ងៃ ខ្លះបិទបាំង៩ថ្ងៃ ខ្លះបិទបាំង១០ថ្ងៃ,បណ្ដាអាបត្តិទាំងឡាយនោះ អាបត្តិទាំងឡាយណា ដែលបិទបាំង ១០ ថ្ងៃ ខ្ញុំព្រះករុណានោះបានសូមហើយនូវសមោធានបរិវាសអំពីសង្ឃ តាមតម្លៃនៃអាបត្តិទាំងឡាយនោះ,បណ្ដាអាបត្តិទាំងឡាយនោះ អាបត្តិទាំងឡាយណា ដែលបិទបាំង១០ថ្ងៃ សង្ឃបានឲ្យហើយនូវសមោធានបរិវាស ដល់ខ្ញុំព្រះករុណានោះ តាមតម្លៃនៃអាបត្តិទាំងឡាយនោះ ខ្ញុំព្រះករុណានោះបានប្រព្រឹត្តបរិវាសគ្រប់គ្រាន់ហើយ បានសូមហើយនូវមានត្ត ៦ រាត្រីអំពីសង្ឃ ដើម្បីអាបត្តិទាំងឡាយនោះ សង្ឃបានឲ្យហើយនូវមានត្ត ៦ រាត្រី ដល់ខ្ញុំព្រះករុណានោះដើម្បីអាបត្តិទាំងឡាយនោះ, បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំព្រះករុណានោះបានប្រព្រឹត្តមានត្តគ្រប់គ្រាន់ហើយ, (ឥឡូវ) សូមនូវការរាប់គេអំពីសង្ឃ”
(សូត្របីដង) ។

ភិក្ខុអ្នកឈ្លាស ប្រតិពល ត្រូវផ្ទៀងសង្ឃថា:

សុណាតុ មេ ភន្តេ សង្ឃោ អយំ (ឥត្ថន្នាមោ) ភិក្ខុ
សម្ពហុលា អាបត្តិយោ អាបជ្ជិ ឯកច្ចា អាបត្តិយោ
ឯកាហប្បដិច្ឆន្នាយោ ។បេ។ ឯកច្ចា ទសាហប្បដិច្ឆ-
ន្នាយោ សោ សង្ឃំ តាសំ អាបត្តីនំ យា អាបត្តិយោ
ទសាហប្បដិច្ឆន្នាយោ តាសំ អគ្ឃេន សមោធានបរិ-
វាសំ យាចតិ សង្ឃោ (ឥត្ថន្នាមស្ស) ភិក្ខុនោ តាសំ
អាបត្តីនំ យា អាបត្តិយោ ទសាហប្បដិច្ឆន្នាយោ តាសំ
អគ្ឃេន សមោធានបរិវាសំ អទាសិ សោ បរិវុត្ថបរិវា-
សោ សង្ឃំ តាសំ អាបត្តីនំ ឆារត្តំ មានត្តំ យាចតិ សង្ឃោ
(ឥត្ថន្នាមស្ស) ភិក្ខុនោ តាសំ អាបត្តីនំ ឆារត្តំ មានត្តំ
អទាសិ សោ ចិណ្ណមានត្តោ សង្ឃំ អព្ភានំ យាចតិ
យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ (ឥត្ថន្នាមំ) ភិក្ខុំ
អព្ភេយ្យ ឯសា ញត្តិ ។

សុណាតុ មេ ភន្តេ សង្ឃោ អយំ (ឥត្ថន្នាមោ) ភិក្ខុ
សម្ពហុលា អាបត្តិយោ អាបជ្ជិ ឯកច្ចា អាបត្តិយោ
ឯកាហប្បដិច្ឆន្នាយោ ។បេ។ ឯកច្ចា ទសាហប្បដិច្ឆ-
ន្នាយោ សោ សង្ឃំ តាសំ អាបត្តីនំ យា អាបត្តិយោ

ទសាហប្បដិច្ឆន្នាយោ តាសំ អគ្គេន សមោធានបរិ-
វាសំ យាចិ សង្ឃោ (ឥត្ថន្នាមស្ស) ភិក្ខុនោ តាសំ
អាបត្តីនំ យា អាបត្តិយោ ទសាហប្បដិច្ឆន្នាយោ តាសំ
អគ្គេន សមោធានបរិវាសំ អទាសិ សោ បរិវុត្ថបរិវាសោ
សង្ឃំ តាសំ អាបត្តីនំ ឆារត្តំ មានត្តំ យាចិ សង្ឃោ
(ឥត្ថន្នាមស្ស) ភិក្ខុនោ តាសំ អាបត្តីនំ ឆារត្តំ មានត្តំ
អទាសិ សោ ចិណ្ណមានត្តោ សង្ឃំ អព្ភានំ យាចតិ
សង្ឃោ (ឥត្ថន្នាមំ) ភិក្ខុំ អព្ភេតិ យស្សាយស្មតោ
ខមតិ (ឥត្ថន្នាមស្ស) ភិក្ខុនោ អព្ភានំ សោ តុណ្ហស្ស
យស្ស នក្ខមតិ សោ ភាសេយ្យ ។

ទុតិយម្បិ ឯតមត្ថំ វទាមិ ។បេ។

តតិយម្បិ ឯតមត្ថំ វទាមិ ។បេ។

អព្ភិតោ សង្ឃេន (ឥត្ថន្នាមោ) ភិក្ខុ ខមតិ សង្ឃស្ស
តស្មា តុណ្ហី ឯវមេតំ ធារយាមិ ។

“បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំ, ភិក្ខុ (ឈ្មោះនេះ)
នេះ បានត្រូវហើយនូវអាបត្តិជាច្រើន ពួកអាបត្តិខ្លះបិទបាំង ១ ថ្ងៃ ។ បេ ។
ខ្លះបិទបាំង ១០ ថ្ងៃ, បណ្ដាអាបត្តិទាំងឡាយនោះ អាបត្តិទាំងឡាយណា
ដែលបិទបាំង១០ថ្ងៃ ភិក្ខុនោះបានសូមហើយនូវសមោធានបរិវាស អំពី

សង្ឃ តាមតម្លៃនៃអាបត្តិទាំងឡាយនោះ, បណ្ដាអាបត្តិទាំងនោះ អាបត្តិទាំងឡាយណា ដែលបិទបាំង១០ ថ្ងៃ សង្ឃបានឲ្យហើយនូវសមោធានបរិវាស ដល់ភិក្ខុ (ឈ្មោះនេះ) តាមតម្លៃ នៃអាបត្តិទាំងឡាយនោះ, ភិក្ខុនោះបានប្រព្រឹត្តបរិវាសគ្រប់គ្រាន់ហើយ បានសូមហើយនូវមានត្ត ៦ រាត្រីអំពីសង្ឃ ដើម្បីអាបត្តិទាំងឡាយនោះ, សង្ឃបានឲ្យហើយនូវមានត្ត ៦ រាត្រីដល់ភិក្ខុ (ឈ្មោះនេះ) ដើម្បីអាបត្តិទាំងឡាយនោះ, ភិក្ខុនោះបានប្រព្រឹត្តមានត្តគ្រប់គ្រាន់ហើយ សូមនូវការរាប់រកអំពីសង្ឃ, បើអព្ភានកម្ម មានកាលដ៏សមគួរដល់សង្ឃហើយ សង្ឃគប្បីរាប់រកនូវភិក្ខុ (ឈ្មោះនេះ); នេះហៅថា ញត្តិ ។

បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្ដាប់ពាក្យខ្ញុំ, ភិក្ខុ (ឈ្មោះនេះ) នេះ បានត្រូវហើយនូវអាបត្តិជាច្រើន ពួកអាបត្តិខ្លះបិទបាំង ១ ថ្ងៃ ។បេ។ ខ្លះបិទបាំង១០ថ្ងៃ, បណ្ដាអាបត្តិទាំងឡាយនោះ អាបត្តិទាំងឡាយណា ដែលបិទបាំង ១០ ថ្ងៃ, ភិក្ខុនោះបានសូមហើយនូវសមោធានបរិវាស អំពីសង្ឃ តាមតម្លៃនៃអាបត្តិទាំងឡាយនោះ, បណ្ដាអាបត្តិទាំងឡាយនោះអាបត្តិទាំងឡាយណា ដែលបិទបាំង១០ថ្ងៃ, សង្ឃបានឲ្យហើយនូវសមោធានបរិវាស ដល់ភិក្ខុ (ឈ្មោះនេះ) តាមតម្លៃនៃអាបត្តិទាំងឡាយនោះ, ភិក្ខុនោះបានប្រព្រឹត្តបរិវាសគ្រប់គ្រាន់ហើយ បានសូមហើយនូវមានត្ត ៦ រាត្រីអំពីសង្ឃដើម្បីអាបត្តិទាំងឡាយនោះ, សង្ឃបានឲ្យហើយនូវមានត្ត ៦ រាត្រីដល់ភិក្ខុ (ឈ្មោះនេះ) ដើម្បីអាបត្តិទាំងឡាយនោះ, ភិក្ខុនោះបានប្រព្រឹត្ត

បរិវាសគ្រប់គ្រាន់ហើយ សូមនូវការរាប់រកអំពីសង្ឃ, (ឥឡូវ) សង្ឃរាប់រកនូវភិក្ខុ (ឈ្មោះនេះ) ការរាប់រកភិក្ខុ (ឈ្មោះនេះ) គាប់ចិត្តដល់លោកអ្នកមានអាយុអង្គណា លោកអ្នកមានអាយុអង្គនោះត្រូវស្ងៀម មិនគាប់ចិត្តដល់លោកអ្នកមានអាយុអង្គណា លោកអ្នកមានអាយុអង្គនោះត្រូវនិយាយឡើង

ខ្ញុំពោលនូវសេចក្ដីនេះ ជាគំរប់ពីរដងទៀត ។ បេ ។

ខ្ញុំពោលនូវសេចក្ដីនេះ ជាគំរប់បីដងទៀត ។ បេ ។

ភិក្ខុ (ឈ្មោះនេះ) សង្ឃបានរាប់រកហើយ, ការរាប់រកនោះគាប់ចិត្តដល់សង្ឃ ព្រោះហេតុនោះបានជាសង្ឃស្ងៀម, ខ្ញុំចាំទុកនូវរឿងនេះដោយអាការស្ងៀមយ៉ាងនេះ" ។

អព្ភាន របស់អប្បដិច្ឆន្នមានត្ត ។ សេចក្ដីថា ភិក្ខុត្រូវអាបត្តិសង្ឃាទិសេសហើយ មិនបានបិទបាំងអាបត្តិ, ព្រះពុទ្ធានុញ្ញាតថា មិនបាច់ធ្វើបរិវាសទេ គ្រាន់តែធ្វើមានត្ត ៦ រាត្រីសព្វគ្រប់ហើយ ធ្វើអព្ភានកម្មក៏រួចចាកអាបត្តិ ។ ឯអព្ភាននោះមានវិធីសូត្រសូមដូច្នេះ អហម្ភន្តេ សម្ព-ហុលា អាបត្តិយោ អាបជ្ជឹ អប្បដិច្ឆន្នាយោ សោហំ សង្ឃំ សម្ពហុលានំ អាបត្តីនំ អប្បដិច្ឆន្នានំ ឆារត្តំ មានត្តំ យាចឹ តស្ស មេ សង្ឃោ សម្ពហុលានំ អាបត្តីនំ អប្បដិច្ឆន្នានំ ឆារត្តំ មានត្តំ អទាសិ សោហម្ភន្តេ ចិណ្ណមានត្តោ សង្ឃំ អព្ភានំ យាចាមិ ។ អហម្ភន្តេ ។ បេ ។

សោហំ ចិណ្ណមានត្តោ ទុតិយម្បិ ភន្តេ សង្ឃំ អព្ភានំ យាចាមិ ។ អហម្ភន្តេ ។ បេ ។ សោហំ ចិណ្ណមានត្តោ តតិយម្បិ ភន្តេ សង្ឃំ អព្ភានំ យាចាមិ “បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំព្រះករុណាបានត្រូវហើយនូវអាបត្តិជាច្រើន មិនបានបិទបាំងទេ, ខ្ញុំព្រះករុណានោះបានសូមហើយនូវមានត្ត ៦ រាត្រី អំពីសង្ឃ ដើម្បីអាបត្តិជាច្រើន ដែលមិនបានបិទបាំង, សង្ឃបានឲ្យហើយនូវមានត្ត ៦ រាត្រីដល់ខ្ញុំព្រះករុណានោះ ដើម្បីអាបត្តិជាច្រើន ដែលមិនបានបិទបាំង, បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំព្រះករុណានោះ បានប្រព្រឹត្តមានត្តគ្រប់គ្រាន់ហើយ (ឥឡូវ) សូមនូវការរាប់រកអំពីសង្ឃ ។ បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំព្រះករុណា ។បេ។ ខ្ញុំព្រះករុណានោះបានប្រព្រឹត្តមានត្តគ្រប់គ្រាន់ហើយ បពិត្រព្រះសង្ឃដ៏ចំរើន (ឥឡូវ) ខ្ញុំព្រះករុណាសូមនូវការរាប់រកអំពីសង្ឃ ជាគំរប់ពីរដងទៀត ។ បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំព្រះករុណា ។បេ។ ខ្ញុំព្រះករុណានោះបានប្រព្រឹត្តមានត្តគ្រប់គ្រាន់ហើយ បពិត្រព្រះសង្ឃដ៏ចំរើន (ឥឡូវ) ខ្ញុំករុណាសូមនូវការរាប់រកអំពីសង្ឃ ជាគំរប់បីដងទៀត” (សូត្រ ៣ ដង) ។

ភិក្ខុអ្នកឈ្លាស ប្រតិពល ត្រូវផ្ទៀងសង្ឃថា

សុណាតុ មេ ភន្តេ សង្ឃោ អយំ (ឥត្ថន្នាមោ) ភិក្ខុ សម្ពហុលា អាបត្តិយោ អាបជ្ជិ អប្បដិច្ឆន្នាយោ សោ សង្ឃំ សម្ពហុលានំ អាបត្តីនំ អប្បដិច្ឆន្នានំ ឆារត្តំ មានត្តំ

យាចិ សង្ឃោ (ឥត្ថន្នាមស្ស) ភិក្ខុនោ សម្ពហុលានំ អាបត្តីនំ អប្បដិច្ឆន្នានំ ឆារត្តំ មានត្តំ អទាសិ សោ ចិណ្ណមានត្តោ សង្ឃំ អព្ភានំ យាចតិ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ (ឥត្ថន្នាមំ) ភិក្ខុំ អព្ភេយ្យ ឯសា ញត្តិ ។

សុណាតុ មេ ភន្តេ សង្ឃោ អយំ (ឥត្ថន្នាមោ) ភិក្ខុ សម្ពហុលា អាបត្តិយោ អាបជ្ជិ អប្បដិច្ឆន្នាយោ សោ សង្ឃំ សម្ពហុលានំ អាបត្តីនំ អប្បដិច្ឆន្នានំ ឆារត្តំ មានត្តំ យាចិ សង្ឃោ (ឥត្ថន្នាមស្ស) ភិក្ខុនោ សម្ពហុលានំ អាបត្តីនំ អប្បដិច្ឆន្នានំ ឆារត្តំ មានត្តំ អទាសិ សោ ចិណ្ណមានត្តោ សង្ឃំ អព្ភានំ យាចតិ សង្ឃោ (ឥត្ថន្នាមំ) ភិក្ខុំ អព្ភេតិ យស្សាយស្មតោ ខមតិ (ឥត្ថន្នាមស្ស) ភិក្ខុនោ អព្ភានំ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។

ទុតិយម្បិ ឯតមត្ថំ វទាមិ ។ បេ ។

តតិយម្បិ ឯតមត្ថំ វទាមិ ។ បេ ។

អព្ភិតោ សង្ឃេន (ឥត្ថន្នាមោ) ភិក្ខុ ខមតិ សង្ឃស្ស តស្មា តុណ្ហី ឯវមេតំ ធារយាមិ ។

"បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្ដាប់ពាក្យខ្ញុំ, ភិក្ខុ (ឈ្មោះ

នេះ) នេះ បានត្រូវហើយនូវអាបត្តិជាច្រើន មិនបានបិទបាំងទេ, ភិក្ខុនោះ បានសូមហើយនូវមានត្ត ៦ រាត្រីអំពីសង្ឃ ដើម្បីអាបត្តិជាច្រើន ដែលមិនបានបិទបាំង, សង្ឃបានឲ្យហើយនូវមានត្ត ៦ រាត្រីដល់ភិក្ខុ (ឈ្មោះនេះ) ដើម្បីអាបត្តិជាច្រើន ដែលមិនបានបិទបាំង, ភិក្ខុនោះបានប្រព្រឹត្តមា-នត្តគ្រប់គ្រាន់ហើយ សូមនូវការរាប់រកអំពីសង្ឃ, បើអព្ភានកម្ម មានកាលដ៏សមគួរដល់សង្ឃហើយ សង្ឃគប្បីរាប់រកនូវភិក្ខុ (ឈ្មោះនេះ) ; នេះហៅថា ញត្តិ ។

បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំ, ភិក្ខុ (ឈ្មោះនេះ) នេះ បានត្រូវហើយនូវអាបត្តិជាច្រើន មិនបានបិទបាំងទេ, ភិក្ខុនោះបានសូមហើយនូវមានត្ត ៦ រាត្រី អំពីសង្ឃ ដើម្បីអាបត្តិជាច្រើន ដែលមិនបានបិទបាំង, សង្ឃបានឲ្យហើយនូវមានត្ត ៦ រាត្រី ដល់ភិក្ខុ (ឈ្មោះនេះ) ដើម្បីអាបត្តិជាច្រើន ដែលមិនបានបិទបាំង, ភិក្ខុនោះបានប្រព្រឹត្តមានត្តគ្រប់គ្រាន់ហើយ សូមនូវការរាប់រកអំពីសង្ឃ (ឥឡូវ) សង្ឃរាប់រកនូវភិក្ខុ (ឈ្មោះនេះ), ការរាប់រកនូវភិក្ខុ (ឈ្មោះនេះ) គាប់ចិត្តដល់លោកអ្នកមានអាយុអង្គណា លោកអ្នកមានអាយុអង្គនោះត្រូវស្ងៀម មិនគាប់ចិត្តដល់លោកអ្នកមានអាយុអង្គណា លោកអ្នកមានអាយុអង្គនោះត្រូវនិយាយឡើង ។

ខ្ញុំពោលនូវសេចក្តីនេះ ជាគំរប់ពីរដងទៀត ។ បេ ។

ខ្ញុំពោលនូវសេចក្តីនេះ ជាគំរប់បីដងទៀត ។ បេ ។

ភិក្ខុ (ឈ្មោះនេះ) សង្ឃបានរាប់រកហើយ, ការរាប់រកនោះគាប់ចិត្ត ដល់សង្ឃ ព្រោះហេតុនោះបានជាសង្ឃស្ងៀម, ខ្ញុំចាំទុកនូវរឿងនេះ ដោយអាការស្ងៀមយ៉ាងនេះ " ។

អព្ភានកម្មដែលសង្ឃត្រូវធ្វើ ដោយញត្តិចតុត្ថកម្មវាចា ដូចបាន និយាយមកនេះ គឺហៅថា កម្មលក្ខណៈ ក្នុងញត្តិចតុត្ថកម្មកថានេះដែរ ។

ចប់ញត្តិចតុត្ថកម្ម ។

សង្ឃកម្ម ៤ យ៉ាង ចប់តែប៉ុណ្ណោះ ។



រោងពុម្ព មិត្តភាព
កម្ពុជា-ជប៉ុន

តម្លៃ : ២២០០ ៛